# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០២២

លេខៈ ១៧

ឆ្នាំ២០២៤

# អារម្ភកថា

សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២២ ត្រូវបានវាយតម្លៃថា មានការងើបឡើងវិញក្នុងអត្រា៥,២% ខ្ពស់ជាងការព្យាករក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចបន្ថិចក្នុងអត្រា៤,៨%។ កំណើនខ្ពស់ជាងការរំពឹងទុកធៀបនឹងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ ដោយសារការរក្សាបានស្ថិរភាពនៃតម្រូវការសកលល្អជាងការរំពឹងទុក បើទោះបីជាទទួលរងផលប៉ះពាល់ពីសង្គ្រាមរុស្ស៊ីនិងអ៊ុយក្រែន ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរបស់មហាអំណាចយ៉ាងណាក្តី ដែលការណ៍នេះបានផ្តល់ភាពល្អប្រសើរដល់វិស័យបម្រើការនាំចេញ ជាពិសេសអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ ការបើកប្រទេសឡើងវិញគួបផ្សំនឹងការដកចេញនូវរបាំងធ្វើដំណើរទាំងកម្រិតសកល តំបន់ និងកម្ពុជា បានចូលរួមចំណែកសំខាន់ដល់ការងើបឡើងវិញលឿនជាងការរំពឹងទុកនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសទេសចរណ៍ និងអនុវិស័យគាំទ្រផ្សេងទៀត។ វិស័យកសិកម្មបានកើនឡើងយឺតក្នុងអត្រាកំណើន០,៧% ដោយសារកំណើនយឺតនៃអនុវិស័យដំណាំ អនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ។ វិស័យឧស្សាហកម្មសម្រេចបានកំណើនរឹងមាំក្នុងអត្រា៨,៣% ក្នុងឆ្នាំ២០២២ ដោយសារកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ និងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដែលជំរុញដោយភាពល្អប្រសើរនៃតម្រូវការខាងក្រៅ។ រីឯវិស័យសេវាកម្មបានងើបឡើងវិញក្នុងអត្រាកំណើន៤,៦%ក្នុងឆ្នាំ២០២២ ដោយសារការងើបឡើងវិញលឿនជាងការរំពឹងទុកនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងសេវាកម្មគាំទ្រផ្សេងៗ។ ផ.ស.ស សម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី ១ ៦៥៩ ដុល្លារអាមេរិកក្នុងឆ្នាំ២០២១ ទៅ ១ ៧៨៤ ដុល្លារអាមេរិកក្នុងឆ្នាំ២០២២។ ទន្ទឹមនឹងនេះ អត្រាអតិផរណាមធ្យមឆ្នាំ២០២២បានកើនដល់ប្រមាណ៥,៣% ប៉ុន្តែទោះយ៉ាងនេះក្តី ក៏ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន និងជាកម្រិតមួយទាបជាងអតិផរណាសកល ដែលបានកើនរហូតដល់៨,៨% ស្របពេលដែលអត្រាប្តូរប្រាក់ស្ថិតក្នុងរង្វង់ប្រមាណ ៤ ០៩០រៀលក្នុងមួយដុល្លារអាមេរិក ដោយសារសម្ពាធពីការកើនឡើងថ្លៃរូបិយប័ណ្ណដុល្លារអាមេរិក ដែលជាបច្ច័យនៃគោលនយោបាយរឹតបន្តឹងរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។

រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវគោលនយោបាយសំខាន់ៗ រួមមាន៖ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២-បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន ៣-បន្តដាក់ចេញក្របខ័ណ្ឌចំណាយអន្តរាគមន៍សង្គមសេដ្ឋកិច្ច ដើម្បីទប់ទល់ និងដោះស្រាយផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ សំដៅការពារអាយុជីវិត និងសុខភាពរបស់ប្រជាជន ព្រមទាំងធានារក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេសតាមរយៈការអនុវត្ត **"យុទ្ធសាស្ត្រស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី"** ៤-បន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ជាពិសេសការកែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា ៥-បន្តអនុវត្តគោលនយោបាយអាទិភាពលើផ្នែកគាំពារសង្គម និងបង្កើនគុណភាពសេវាសុខាភិបាល ព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខភាពសាធារណៈ និងប្រព័ន្ធគាំពារសង្គម ដើម្បីអាចឆ្លើយតបនឹងគ្រោះអាសន្នជាយថាហេតុ និង

លើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ៦-បន្តតម្រង់ទិសធនធានទៅអភិវឌ្ឍវិស័យអាទិភាពក្នុងបរិការណ៍ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ដូចជា វិស័យកសិកម្ម វិស័យទេសចរណ៍ វិស័យឌីជីថល និងវិស័យកម្មន្តសាលថ្មីៗ ដើម្បីជំរុញការងើបឡើងនៃកំណើនសេដ្ឋកិច្ច និងពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ៧-បន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូចនិងមធ្យមតាមរយៈការដាក់ចេញនូវវិធានការលើកទឹកចិត្តជាក់លាក់ និងការបង្កភាពងាយស្រួលក្នុងការធ្វើធុរកិច្ច ដើម្បីធ្វើឱ្យរស់រវើកឡើងវិញនូវសកម្មភាពអាជីវកម្មក្នុងស្រុក និងការបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានកម្ចីការប្រាក់ទាប ៨-បន្តលើកកម្ពស់វិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសការធ្វើបរិវត្តកម្មឌីជីថលកម្ពុជា២០២១-២០៣៥ ៩-បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការទីផ្សារ និងប្រក្រតីភាពថ្មី ១០-បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង១១-ធានាជោគជ័យនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំ២០២២ និងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានក្នុងនាមជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាននៅឆ្នាំ២០២២។

ជាក់ស្តែងនៅក្នុងឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ បានខិតខំប្រឹងប្រែងអនុវត្តវិធានការប្រមូលចំណូលដែលនាំឱ្យចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០២២ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១២,២% ហើយបានកើនឡើង ២១,៥% ធៀបនឹងការអនុវត្តឆ្នាំ២០២១ ដោយចំណូលសារពើពន្ធឆ្នាំ២០២២ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១១,៧% ហើយបានកើនឡើង ២២,១% ធៀបនឹងការអនុវត្តឆ្នាំ២០២១ ដែលឆ្លុះបញ្ចាំងពីការងើបឡើងវិញនូវសកម្មភាពប្រើប្រាស់ផលិតផលក្នុងស្រុក និងការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាជន។ សមិទ្ធផលទាំងនេះក៏បានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងដោយតស៊ូមោះមុតប្រកបដោយការទទួលខុសត្រូវខ្ពស់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលបានអនុវត្តដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រកំណែទម្រង់និងទំនើបកម្មគយ មានវិធានការទប់ស្កាត់បទល្មើសគេចពន្ធ ប្រមូលចំណូលពន្ធគយតាមគ្រប់រូបភាពធ្វើឱ្យចំណូលគយនិងរដ្ឋាករមានកំណើនជាលំដាប់ ជាមួយនេះដែរក៏បានឆ្លុះបញ្ចាំងពីអគ្គនាយកដ្ឋានពន្ធដារបានអនុវត្តយន្តការបុរេសកម្មក្នុងការកែទម្រង់រដ្ឋបាលសារពើពន្ធលើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ ហើយបាននឹងកំពុងអនុវត្ត បច្ចេកវិទ្យាឌីជីថល ដើម្បីជួយសម្រួលដល់អ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចពន្ធ ធ្វើឱ្យការប្រមូលចំណូលសារពើពន្ធបានល្អប្រសើរ។

ចំពោះចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០២២ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១៥,៤% ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០២២ អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ២,០% និងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៤,៤%។

រីឯចំណាយសរុបថវិកាជាតិ ក្នុងឆ្នាំ២០២២ អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ៩,៨% គឺដោយសារភាពធូរស្រាលនៃស្ថានភាពវិបត្តិនៃជំងឺកូវីដ-១៩ ដែលការណ៍នេះបានសម្រួលដល់បន្ទុកចំណាយថវិកាលើកញ្ចប់ថវិកាអន្តរាគមន៍សង្គម សេដ្ឋកិច្ច។ ភាពធូរស្រាលពីវិបត្តិនៃជំងឺកូវីដ-១៩ បានជួយសម្រួលដល់សម្ពាធថវិកាមួយផ្នែកធំ និងអាចផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបង្វែរអាទិភាពថវិកា ទៅការបន្តលើកកម្ពស់ការអនុវត្តគោលនយោបាយគាំពារសង្គម ការពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ ការវិនិយោគលើមូលធនមនុស្ស ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់។

ទន្ទឹមនេះ រាជរដ្ឋាភិបាលបានទទួលការអនុញ្ញាតឱ្យធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលសម្រេចបានលទ្ធផលដូចតទៅ៖ (១)-ការអនុវត្តកម្មវិធីជំនួយសង្គមជួយជនក្រីក្រ និងងាយរងគ្រោះ (២)-ចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ (គ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ដែលងាយរងផលប៉ះទង្គិចពីសម្ពាធអតិផរណា។

លទ្ធផលទាំងនេះ បានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយមោះមុតអង់អាច ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាល ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជារដ្ឋបុរស ជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម**នៃព្រះរាជាណាចក្រកម្ពុជា និងដោយសារតែរាជរដ្ឋាភិបាលមានច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមអាទិភាពគោលនយោបាយសំខាន់ៗ។

ចំពោះចំណាយថវិការាជធានី ខេត្ត អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១១,២% ចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៣,៩% និងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ក៏អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ១៨,៨% ដែរ។

ការគ្រប់គ្រងថវិកាឆ្នាំ២០២២ គោរពបានទាំងកាលវសាន ទាំងខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានបង្ហាញឱ្យឃើញថា ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកល និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកំពុងវិវត្តឆាប់រហ័ស និងចល័តយ៉ាងលឿនពិបាកប៉ាន់ប្រមាណឱ្យបានច្បាស់លាស់ ឆ្លុះបញ្ចាំងពីការគិតគូររៀបចំ និងអនុវត្តការប្រើប្រាស់ធនធានលើការបន្តប្រយុទ្ធ និងការកសាងសមត្ថភាពរស់នៅជាមួយនឹងជំងឺកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មី ក៏ដូចជាការទ្រទ្រង់ដល់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋមិនឱ្យរាំងស្ទះ ជាពិសេសការស្តារជីវភាពប្រជាជន និងការស្តារកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជាឡើងវិញ ក៏ដូចជា ដើម្បីសម្រេចឱ្យខាងតែបាននូវអាទិភាពគោលនយោបាយសំខាន់ៗជាសារវន្តនៃ**កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣** ពិសេសការជំរុញល្បឿននៃការអនុវត្តកិច្ចការកែទម្រង់គ្រប់វិស័យរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា សំដៅកសាងមូលដ្ឋានគ្រឹះក្នុងដំណើរការឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិ មានអនាគតដ៏រុងរឿងភ្លឺស្វាង គ្រចះគ្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យនិងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។

រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយដែលបានដាក់ចេញ ព្រមជាមួយនឹងការបន្តប្រកាន់ខ្ជាប់នូវអភិក្រមការងារ៥យ៉ាងគឺ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" ដើម្បីធានាឱ្យបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ឯករាជ្យ និងអធិបតេយ្យជាតិ ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ក៏ដូចជាដើម្បីទ្រទ្រង់នូវដំណើរស្តារ និងជំរុញកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជាឡើងវិញទោះបីជាស្ថិតក្នុងស្ថានភាពលំបាកនេះ ហើយជាមួយគ្នានេះ រាជរដ្ឋាភិបាលបានត្រៀមលក្ខណៈ និងនៅតែមានមហិច្ឆតា ដើម្បីធ្វើឱ្យកម្ពុជាងើបឡើងកាន់តែខ្លាំងជាងមុនពេលមានវិបត្តិនៃជំងឺកូវីដ-១៩ នៅលើមាគ៌ាឈានឆ្ពោះទៅសម្រេចឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យ។

សរុបមក ថវិកាឆ្នាំ២០២២ ត្រូវបានសន្និដ្ឋានថា ជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាពដែលជួយឱ្យរាជរដ្ឋាភិបាលអាចបន្តគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ និងឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុងនិងក្រៅប្រទេស ហើយត្រូវបានប្រសិទ្ធនាមថាជា "**ថវិកាសម្រាប់បន្តការប្រយុទ្ធប្រឆាំង និងការកសាងសមត្ថភាពរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ**"។

តាមការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ព្រមទាំងបទប្បញ្ញត្តិគតិយុត្តនានា។

អាជ្ញាធរសវនកម្មជាតិសូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តវិធានការប្រមូលចំណូល និងគ្រប់គ្រងការចំណាយប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពឈ្លាសវៃ។ សមិទ្ធផលទាំងនេះសរបញ្ជាក់ពីភាពត្រឹមត្រូវ ពីប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងផ្លែផ្កានៃកំណែទម្រង់មុតស្រួច និងស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលសំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០២២ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធនិងល្អប្រសើរ ដែលនាំឱ្យអាជ្ញាធរសវនកម្មជាតិសម្រេចបាននូវភារកិច្ចរបស់ខ្លួន ព្រមទាំងសាធារណៈជនទាំងឡាយដែលបានសហការគាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់ដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា នឹងសម្រេចបាននូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការកែទម្រង់មុតស្រួច និងស៊ីជម្រៅលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ពិសេសលើការកែទម្រង់លើការគ្រប់គ្រង ដើម្បីចូលរួមលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រលាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២៤

**អគ្គសវនករ**



**សោម គីមសួគ៌**

# មាតិកា

ទំព័រ

**សេចក្តីសង្ខេប** ........ **១**

**១. សេចក្តីផ្តើម** ........ **៥**

១.១.លក្ខណៈទូទៅ ........ ៥

១.២.ការអនុវត្ត និងដែនកំណត់សវនកម្ម ........ ៥

១.៣. គោលបំណងនៃការផ្សព្វផ្សាយ ........ ៦

**២. ការគ្រប់គ្រងថវិកា** ........ **៦**

២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា ........ ៦

២.២.កិច្ចប្រតិបត្តិការថវិកា ........ ៧

**៣. លទ្ធផលសវនកម្ម** ........ **១១**

៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ ........ ១១

៣.១.១.សហគ្រាសចុះបញ្ជីពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនពុំទាន់បានមកធ្វើបច្ចុប្បន្នភាព ១១

៣.១.២.ការចុះបញ្ជីអាជីវកម្មដ្ឋានតាមលទ្ធផលអង្កេត ........ ១២

៣.១.៣.វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញាតប័ណ្ណមួយចំនួនមានលក្ខណៈពុំទាន់សមស្របនៅឡើយ ........ ១២

៣.១.៤.ភាពយឺតយ៉ាវក្នុងការចុះបញ្ជីម៉ាក ........ ១៤

៣.១.៥.ការមិនមានរបាយការណ៍ ឬកំណត់ហេតុក្នុងការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក ........ ១៥

៣.១.៦.ការប្រមូលចំណូលសេវាសាធារណៈរបស់ភ្នាក់ងារប្រមូលពុំមានលិខិតបង្គាប់ការច្បាស់លាស់ ១៦

៣.១.៧.ការរៀបចំបញ្ជីបេឡាថវិការជ្ជទេយ្យបុរេប្រទានកម្មវិធី ........ ១៧

៣.១.៨.ភាពយឺតយ៉ាវក្នុងការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង ........ ១៧

៣.១.៩.ប័ណ្ណប៉ាតង់ពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងតម្លៃ ........ ១៨

៣.១.១០.ការពុំដាក់ការផ្តត់ផ្គង់ឯកសណ្ឋាន និងសញ្ញាស័ក្តិបញ្ចូលក្នុងផែនការលទ្ធកម្ម ........ ១៩

៣.១.១១.កង្វះខាតក្នុងការបិទផ្សាយរបាយការណ៍ជាសាធារណៈ ស្តីពីវត្តមានរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៅតាមអង្គភាព ........ ២០

៣.១.១២.កង្វះខាតក្នុងការបំពេញព្រឹត្តិបត្រការងារប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល ........ ២១

៣.១.១៣.ការទូទាត់ចំណាយឆ្លងឆ្នាំ ........ ២១

៣.១.១៤.ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការ ........ ២២

៣.១.១៥.អង្គភាពអនុវត្តគម្រោងពុំមាឧបករណ៍បំពេញការងារគ្រប់គ្រាន់ ........ ២៣

៣.១.១៦.ភាពយឺតយ៉ាវក្នុងការចេញលិខិតដកប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនក្រុមហ៊ុន ........ ២៣

៣.១.១៧.ការចំណាយថវិការជ្ជទេយ្យបុរេប្រទានពុំទាន់បានត្រឹមត្រូវតាមនីតិវិធី ........ ២៤

៣.១.១៨.ការផ្សព្វផ្សាយតាមរយៈសារព័ត៌មានលើការងារបោះពុម្ពពុំទាន់បានពេញលេញ ........ ២៥

៣.១.១៩.កង្វះខាតក្នុងការភ្ជាប់ប៉ាន់គំរូ ឬកាតាឡុក....................................................................................២៥
៣.១.២០.ការវាយតម្លៃនិងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដេញថ្លៃឈ្នះដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់២៦
៣.១.២១.ការពុំមានវិធានការណ៍លើក្រុមហ៊ុនដែលបំពានកិច្ចសន្យា.................................................. ២៧
៣.១.២២.ការបំបែកប័ណ្ណចំណាយដោយពុំធ្វើនីតិវិធីលទ្ធកម្ម ......................................................................២៨
៣.១.២៣.កង្វះខាតក្នុងការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម.........................................................២៩
៣.១.២៤.ការចំណាយ និងការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកា
ថវិការបស់រដ្ឋ ........................................................................................................................................២៩
៣.១.២៥.ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត .......................................... ៣៣
៣.១.២៦.ការទូទាត់ប្រាក់រង្វាន់ឆ្លងឆ្នាំ ................................................................................................... ៣៣
៣.១.២៧.ភាពយឺតយ៉ាវក្នុងការរៀបចំគោលនយោបាយគណនេយ្យ ..............................................................៣៤
៣.១.២៨.កង្វះខាតក្នុងការអនុវត្តគម្រោងតាមផែនការលទ្ធកម្ម....................................................................៣៥
៣.១.២៩.ការមិនបានបែងចែកភារកិច្ចរវាងអធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ...............................................៣៥
៣.១.៣០.ការពុំទាន់រៀបចំគម្រោងជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ.......................................................................៣៥
៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ........................................................................................៣៦
៣.២.១.ការពុំបានធ្វើការត្រួតពិនិត្យលើការងាររបស់រដ្ឋទេយ្យករចំណូល ...................................................៣៦
៣.២.២.ការពុំបានអនុវត្តតាមសៀវភៅបន្ទុកឱ្យបានពេញលេញ.................................................................... ៣៧
៣.២.៣.ការទូទាត់ពុំសមស្របតាមកិច្ចសន្យា........................................................................................ ៣៧
៣.២.៤.កង្វះខាតក្នុងការចេញវិញ្ញាបនបត្របញ្ចប់ការងារជូនអ្នកទទួលការ...................................................៣៨
៣.២.៥.ការរក្សាទុកឯកសារដែលអង្គភាពរដ្ឋទទួលការមិនបានពេញលេញ ..................................................៣៩
៣.២.៦.កង្វះខាតក្នុងការទុកពេលវេលាសម្រាប់បណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម ............................................. ៤០
៣.២.៧.កង្វះខាតក្នុងការបញ្ចូលទ្រព្យសម្បត្តិរដ្ឋទៅក្នុងបញ្ជីសារពើភណ្ឌ ............................................... ៤១
**៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម ...........................៤២**
៤.១.ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២២ ............................................................................៤៣
៤.២.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន ...................................៤៣
៤.៣. វិធីសាស្ត្រសវនកម្ម................................................................................................................. ៤៤
៤.៤.ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន ...................................................... ៤៤
៤.៥.ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ ........................................... ៤៥
៤.៦.ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ......................................................................................... ៤៦
៤.៧.ការរក្សាសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២២........................................................................ ៤៦
៤.៨.ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើមដែលទទួលបាន
ការអនុគ្រោះព្យួរ ឬលើកលែងពន្ធអាករនៅមានកម្រិត.................................................................៤៧
៤.៩.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ ............................................................ ៤៨

៤.១០.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ..................... ៤៩
៤.១១.ការទូទាត់ និងការកត់ត្រាចំណាយ ..................... ៤៩
៤.១២.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ..................... ៥០
៤.១៣.អង្គភាពថវិកាមួយចំនួនពុំបានធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ ..................... ៥២
៤.១៤.កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ ..................... ៥៣
៤.១៥.ភាពមិនទាន់ពេញលេញនៃការបង្កើតរបាយការណ៍ចេញពីប្រព័ន្ធFMISសម្រាប់ប្រើប្រាស់ ..................... ៥៣
៤.១៦.ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ ..................... ៥៤
៤.១៧.កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងការងារជួសជុល ថែទាំ អគារ និងប្រាសាទ ..................... ៥៥
៤.១៨.ការពុំបានគ្រោងក្នុងផែនការលទ្ធកម្ម ..................... ៥៥
៤.១៩.ការគ្រប់គ្រងស្ថានីយប្រេងឥន្ទនៈ ឧស្ម័នឥន្ទនៈ និងស្ថានីយរួមប្រេងនៅមានកម្រិត ..................... ៥៦
៤.២០.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព ..................... ៥៧
៤.២១.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ..................... ៥៨
៤.២២.ភាពយឺតយ៉ាវនិងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ ..................... ៥៩
**៥. សេចក្តីសន្និដ្ឋាន ..................... ៦០**

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២២

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **៣២ ២៩៩ ៣៣០,៩លានរៀល** ស្មើនឹង **២៦,៧០%** នៃផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៥,៧%** ហើយកើនឡើង **២០,០%** ធៀបនឹងការអនុវត្តឆ្នាំ២០២១។ ចំណូលថវិកានេះគឺជាសមិទ្ធផលដ៏ត្រចះត្រចង់ជាច្រើនឆ្នាំជាប់ៗគ្នាក្នុងការប្រមូលចំណូលពន្ធអាករ អាចសម្រេចទៅបានដោយសារ៖ (១)-ការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងការអនុវត្តការងារប្រកបដោយវិជ្ជាជីវៈ (២)-ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវផែនការសកម្មភាពប្រចាំឆ្នាំនៃយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រធនធានមនុស្សឆ្នាំ២០១៩-២០២៣របស់អគ្គនាយកដ្ឋានពន្ធដារ (៣)-ការបន្តផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធតាមរយៈការធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍប្រព័ន្ធ និងកម្មវិធីថ្មីៗ ដើម្បីលើកកម្ពស់គុណភាពសេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែល្អប្រសើរ រហ័ស សាមញ្ញ និងងាយស្រួល។ ស្របគ្នានេះដែរ អាជ្ញាធរសវនកម្មជាតិក៏កត់សម្គាល់ឃើញថា ស្ថិតក្នុងបរិការណ៍ដែលជំងឺកូវីដ-១៩នៅបន្តមានឥទ្ធិពលមកលើសង្គម សេដ្ឋកិច្ចនៅឡើយ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលលោក។ ដោយមានការដឹកនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងមន្ត្រីក្រោមឱវាទ តស៊ូមោះមុតពុះពាររាល់ការលំបាកឧបសគ្គនានា និងតាមរយៈកិច្ចខិតខំប្រឹងប្រែងអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២៣ យុទ្ធសាស្ត្រកំណែទម្រង់និងទំនើបកម្មគយ ២០១៩-២០២៣ និងឯកសារគោលនយោបាយពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ជាពិសេសប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅ

ជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ជាមួយគ្នានឹងការបន្តពង្រឹងអភិបាលកិច្ចក្នុងអង្គភាពគយ និងរដ្ឋាករ បន្តពង្រឹងយន្តការកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការសម្រួលបែបបទបញ្ចេញទំនិញពីគយ និងការលើកទឹកចិត្តពន្ធអាករជាដើម បានធ្វើឱ្យការប្រមូលចំណូលគយ និងរដ្ឋាករមានភាពកាន់តែល្អប្រសើរ មានការកើនឡើងជាលំដាប់ ដោយគួបផ្សំនឹងវិធានការទប់ស្កាត់បទល្មើសគេចពន្ធ និងការប្រមូលពន្ធបានគ្រប់ជ្រុងជ្រោយធ្វើឱ្យការប្រមូលចំណូលអនុវត្តបានល្អបើធៀបនឹងការអនុវត្តឆ្នាំ២០២១។

ដោយឡែក ចំណូលមិនមែនសារពើពន្ធ ទោះបីជាមានការរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ ជាពិសេសពាក់ព័ន្ធនឹងវិស័យទេសចរណ៍ វិស័យអាកាសចរណ៍ ចំណូលពីលិខិតឆ្លងដែន និងទិដ្ឋាការ និងចំណូលពីកាតព្វកិច្ចកាស៊ីណូ ប៉ុន្តែមានការបំពេញជំនួសវិញពីប្រភពចំណូលសំខាន់ៗ ដូចជា ប្រាក់ចំណេញពីសហគ្រាសសាធារណៈ ប្រាក់ចំណេញពីធនាគារជាតិនៃកម្ពុជា ដែលជាចំណូលម្តងម្កាល ចំណូលវិស័យទូរគមនាគមន៍ កម្រៃនៃការថែទាំ អាជ្ញាប័ណ្ណក្នុងស្រុក លក់ឯកសារ លតាប័ត្រ លិខិតបោះពុម្ពផ្សេងៗ និងចំណូលផ្សេងៗមួយចំនួនទៀតផងដែរ។

តាមលទ្ធផលនៃការធ្វើសវនកម្មលើចំណូលបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតមានជាអាទិ៍៖ សហគ្រាសចុះបញ្ជីពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនពុំទាន់បានមកធ្វើបច្ចុប្បន្នភាព, ការចុះបញ្ជីអាជីវកម្មដ្ឋានតាមលទ្ធផលអង្កេត, វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញាតប័ណ្ណមួយចំនួនមានលក្ខណៈពុំទាន់សមស្របនៅឡើយ, ភាពយឺតយ៉ាវក្នុងការចុះបញ្ជីម៉ាក, ការមិនមានរបាយការណ៍ឬកំណត់ហេតុក្នុងការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក, ការប្រមូលចំណូលសេវាសាធារណៈរបស់ភ្នាក់ងារប្រមូលពុំមានលិខិតបង្គាប់ការច្បាស់លាស់, ការរៀបចំបញ្ជីបេឡាចវិការជ្ជទេយ្យបុរេប្រទានកម្មវិធី, ភាពយឺតយ៉ាវក្នុងការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង, ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២២, ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួងស្ថាប័ន, វិធីសាស្ត្រសវនកម្ម, ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន, ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ, ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ, ការរក្សាសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២២, ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើម ដែលទទួលបានកាអនុគ្រោះព្យួរ ឬលើកលែងពន្ធអាករនៅមានកម្រិត, ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ, និងការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **២៩ ៨៥០ ៨៤៧,២** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៩,៨%** ហើយស្មើនឹង**២៤,៦៧%** នៃផ.ស.ស ហើយបានថយចុះ**៦,៧%** ធៀបនឹងការអនុវត្តឆ្នាំ២០២១។ ចំណាយថវិកានេះ គឺដោយសារភាពធូរស្រាលពីវិបត្តិនៃជំងឺកូវីដ-១៩ បានជួយសម្រួលដល់សម្ពាធថវិកាមួយផ្នែកធំ និងអាចផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបង្វែរអាទិភាពថវិកា ទៅការបន្តលើកកម្ពស់ការអនុវត្តគោលនយោបាយគាំពារសង្គម ការពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ ការវិនិយោគលើមូលធនមនុស្ស ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់។

ទន្ទឹមនេះ រាជរដ្ឋាភិបាលបានទទួលការអនុញ្ញាតឱ្យធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលសម្រេចបានលទ្ធផលដូចតទៅ៖ (១)-ការអនុវត្តកម្មវិធីជំនួយសង្គមជួយជនក្រីក្រ និងងាយរងគ្រោះ (២)-ចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ (គ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ដែលងាយរងផលប៉ះទង្គិចពីសម្ពាធអតិផរណា និងបានបន្តអនុវត្តនូវគោលនយោបាយសំខាន់ៗ រួមមាន៖ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២-បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន ៣-បន្តដាក់ចេញក្របខ័ណ្ឌចំណាយអន្តរាគមន៍សង្គមសេដ្ឋកិច្ច ដើម្បីទប់ទល់ និងដោះស្រាយផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ សំដៅការពារអាយុជីវិត និងសុខភាពរបស់ប្រជាជន ព្រមទាំងធានារក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេសតាមរយៈការអនុវត្ត **"យុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី"** ៤-បន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ជាពិសេសការកែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា ៥-បន្តអនុវត្តគោលនយោបាយអាទិភាពលើផ្នែកគាំពារសង្គម និងបង្កើនគុណភាពសេវាសុខាភិបាល ព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខភាពសាធារណៈ និងប្រព័ន្ធគាំពារសង្គម ដើម្បីអាចឆ្លើយតបនឹងគ្រោះអាសន្នជាយថាហេតុ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ៦-បន្តតម្រង់ទិសធនធានទៅអភិវឌ្ឍវិស័យអាទិភាពក្នុងបរិការណ៍ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ដូចជា វិស័យកសិកម្ម វិស័យទេសចរណ៍ វិស័យឌីជីថល និងវិស័យកម្មន្តសាលថ្មីៗ ដើម្បីជំរុញការងើបឡើងនៃកំណើនសេដ្ឋកិច្ច និងពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ៧-បន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូចនិងមធ្យមតាមរយៈការដាក់ចេញនូវវិធានការលើកទឹកចិត្តជាក់លាក់ និងការបង្កភាពងាយស្រួលក្នុងការធ្វើធុរកិច្ច ដើម្បីធ្វើឱ្យរស់រវើកឡើងវិញនូវសកម្មភាពអាជីវកម្មក្នុងស្រុក និងការបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានកម្ចីការប្រាក់ទាប ៨-បន្តលើកកម្ពស់វិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់ហេដ្ឋារចនាសម្ព័ន្ធបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសការធ្វើបរិវត្តកម្មឌីជីថលកម្ពុជា២០២១-២០៣៥ ៩-បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការទីផ្សារ និងប្រក្រតីភាពថ្មី ១០-បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង១១-ធានាជោគជ័យនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២ និងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានក្នុងនាមជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាននៅឆ្នាំ២០២២។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា៖ ប័ណ្ណប៉ាតង់ពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ, ការពុំដាក់ការផ្គត់ផ្គង់ឯកសណ្ឋាននិងសញ្ញាស័ក្តិបញ្ចូលក្នុងផែនការលទ្ធកម្ម, កង្វះខាតក្នុងការបិទផ្សាយរបាយការណ៍ជាសាធារណៈស្តីពីវត្តមានរបស់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យានៅតាមអង្គភាព, កង្វះខាតក្នុងការបំពេញព្រឹត្តិបត្រការងារប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល, ការទូទាត់ចំណាយឆ្លងឆ្នាំ, ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការ, អង្គភាពអនុវត្តគម្រោងពុំមានឧបករណ៍បំពេញការងារគ្រប់គ្រាន់, ភាពយឺតយ៉ាវក្នុងការចេញលិខិតដកប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនក្រុមហ៊ុន, ការចំណាយថវិការជូនទេយ្យបុរេប្រទានពុំទាន់បានត្រឹមត្រូវតាមនីតិវិធី, ការផ្សព្វផ្សាយតាមរយៈសារព័ត៌មានលើការងារបោះពុម្ពពុំទាន់បានពេញលេញ, កង្វះខាតក្នុងការភ្ជាប់ប៉ាន់គំរូ ឬកាតាឡុក, ការវាយតម្លៃនិងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដេញថ្លៃឈ្នះដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, ការពុំមានវិធានការណ៍លើក្រុមហ៊ុនដែលបំពានកិច្ចសន្យា, ការបំបែកប័ណ្ណចំណាយដោយពុំធ្វើនីតិវិធីលទ្ធកម្ម, កង្វះខាតក្នុងការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម, ការចំណាយនិងការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ, ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត, ការទូទាត់ប្រាក់រង្វាន់ឆ្លងឆ្នាំ, ភាពយឺតយ៉ាវក្នុងការរៀបចំគោលនយោបាយគណនេយ្យ, កង្វះខាតក្នុងការអនុវត្តគម្រោងតាមផែនការលទ្ធកម្ម, ការមិនបានបែងចែកភារកិច្ចរវាងអធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង, ការទូទាត់និងការកត់ត្រាចំណាយ, ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់, អង្គភាពថវិកាមួយចំនួនពុំបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ, កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ, ភាពមិនទាន់ពេញលេញនៃការបង្កើតរបាយការណ៍ចេញពីប្រព័ន្ធFMISសម្រាប់ប្រើប្រាស់, ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ, កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងការងារជួសជុលថែទាំអគារ និងប្រាសាទ, ការពុំបានគ្រោងក្នុងផែនការលទ្ធកម្ម, និងការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈនិងស្ថានីយរួមប្រេងនៅមានកម្រិត។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុបស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន**៥ ៦០៤ ៥៣៤,៤** លានរៀល ស្មើនឹង **៩៦,៤%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន**៥ ៨១៣ ៤៨៤,០** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន **២០៨ ៩៤៩,៦** លានរៀល។

### ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**៣ ៣០៨ ៧២០,២** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**១៥,៤%** និងចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្ត អនុវត្តបានចំនួន**៣ ១៨៩ ៩៣៦,៥** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**១១,២%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តចំនួន**៥៨៥ ៥៥៦,០** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**២,០%** និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន**៥៧៤ ១៥៩,២** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៣,៩%**។ រីឯចំណូល

ចវិការរបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តចំនួន១ ១៣៣ ៧៩៣,៥ លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៤,៤% និងចំណាយថវិការបស់រដ្ឋបាលឃុំសង្កាត់ អនុវត្តបានចំនួន៨៨១ ៨៨៣,៤លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ១៨,៨%។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ ការពុំបានធ្វើការត្រួតពិនិត្យលើការងាររបស់រដ្ឋទេយ្យករចំណូល, ការពុំបានអនុវត្តតាមសៀវភៅបន្ទុកឱ្យបានពេញលេញ, ការទូទាត់ពុំសមស្របតាមកិច្ចសន្យា, កង្វះខាតក្នុងការចេញវិញ្ញាបនបត្របញ្ចប់ការងារជូនអ្នកទទួលការ, ការរក្សាទុកឯកសារដែលអង្គភាពរដ្ឋទទួលការមិនបានពេញលេញ, កង្វះខាតក្នុងការទុកពេលវេលាសម្រាប់បណ្ដឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម, កង្វះខាតក្នុងការបញ្ចូលទ្រព្យសម្បត្តិរដ្ឋទៅក្នុងបញ្ជីសារពើភណ្ឌ, និងភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ។

# ១. សេចក្ដីផ្ដើម

## ១.១. លក្ខណៈទូទៅ

ច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជិកាគណនេយ្យ គណនីប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្ដាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្ដាអង្គការផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្ដល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

## ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្ដាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបចំនួន៨២ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះសំដៅធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០២២ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០២២ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២២ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូល** | **៣០ ៥៤៤ ៣៦៦,០** | **៣២ ២៩៩ ៣៣០,៨** | **១០៥,៧%** |
| -ចំណូលចរន្ត | ២២ ១៥៧ ៣៤៣,០ | ២៤ ៨៦០ ៨៦៥,៨ | ១១២,២% |
| -ចំណូលមូលធន | ២ ៥៧៣ ៥៣៩,០ | ១ ៨៣៣ ៩៣០,៦ | ៧១,៣% |
| +ចំណូលមូលធនក្នុងប្រទេស | ១ ៣០៥ ២៥៩,០ | ១១៦ ០៣១,៧ | ៨,៩% |
| +ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | ១ ២៦៨ ២៨០,០ | ១ ៧១៧ ៨៩៨,៩ | ១៣៥,៥% |
| -ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៥ ៨១៣ ៤៨៤,០ | ៥ ៦០៤ ៥៣៤,៤ | ៩៦,៤% |
| **II. សរុបចំណាយ** | **៣៣ ០៧៩ ២៦៦,០** | **២៩ ៨៥០ ៤៤៧,២** | **៩០,២%** |
| -ចំណាយចរន្ត | ១៩ ១១១ ៧០៤,០* | ១៧ ៨៨៨ ៣១២,៦ | ៩៣,៦% |
| -ចំណាយមូលធន | ៨ ១៥៤ ០៧៨,០ | ៦ ៣៥៧ ៦០០,២ | ៧៨,០% |
| +វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៦ ៦៧៦ ៤២១,០ | ៤ ៩០៥ ៦៥៤,១ | ៧៣,៥% |
| +ការទូទាត់ការខ្ចី | ១ ៤៧៧ ៦៥៧,០ | ១ ៤៥១ ៩៤៦,១ | ៩៨,៣% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៥ ៨១៣ ៤៨៤,០ | ៥ ៦០៤ ៥៣៤,៤ | ៩៦,៤% |

**<u>កំណត់សំគាល់:</u>** កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២២ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

(*)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន៥០២ ៤០០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

## ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| **បរិយាយ** | **ឆ្នាំ២០២២** | | |
|---|---|---|---|
| | **ច្បាប់ហិរញ្ញវត្ថុ** | **អនុវត្ត** | **ភាគរយ** |
| | *1* | *2* | *3 = (2/1)* |
| I. **សរុបចំណូលថវិកា** | **២ ៨៦៧ ៤២១,៦*** | **៣ ៣០៨ ៧២០,២** | **១១៥,៤%** |
| -ចំណូលចរន្ត | ១ ៨៣១ ៨៧០,០ | ២ ៣១១ ០៩៩,៧ | ១២៦,២% |
| •ចំណូលសារពើពន្ធ | ១ ៥៨៤ ១២៧,០ | ២ ០០៨ ៥៩១,៤ | ១២៦,៨% |
| •ចំណូលពុំមែនសារពើពន្ធ | ២៤៧ ៧៤៣,០ | ៣០២ ៥០៨,៣ | ១២២,១% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៧៦៦ ៨៩២,៦ | ៧៣៤ ៦៦៣,៥ | ៩៥,៨% |
| -ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ២៦៨ ៦៥៩,០ | ២៦២ ៩៥៧,០ | ៩៧,៩% |
| II. **សរុបចំណាយថវិកា** | **២ ៨៦៧ ៤២០,៦**** | **៣ ១៨៩ ៩៣៦,៥** | **១១១,២%** |
| -ចំណាយចរន្ត | ២ ៤៣៤ ២៤២,៦ | ២ ៧៥៦ ៥៩៦,៣ | ១១៣,២% |
| -ចំណាយមូលធន | ៤៣៣ ១៧៨,០ | ៤៣៣ ៣៤០,២ | ១០០,០% |

***កំណត់សំគាល់:*** កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២២ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

* តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមដល់រដ្ឋបាលរាជធានី ខេត្តចំនួន៧ ៧៦៩,៥៦លានរៀល ក្នុងនោះ៖ ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត ចំនួន១ ៤៣០លានរៀល សម្រាប់ផ្តល់ជូនសាលាខេត្តសៀមរាប (មូលនិធីអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ) និងការប្រគល់មុខងារសុខាភិបាលចំនួន៦ ៣៣៩,៥៦លានរៀល ផ្តល់ជូនមន្ទីរសុខាភិបាលរាជធានី ខេត្តចំនួន១០។

** តួលេខនេះបូកបញ្ចូលឥណទានថវិកានិយ័តកម្មថ្នាក់ជាតិផ្តល់ជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ) ចំនួន១ ៤៣០លានរៀល និងប្រកាសបន្ថែមឥណទានថវិកាចំនួន៦ ៣៣៩,៥៦លានរៀល ផ្តល់ជូនមន្ទីរសុខាភិបាលរាជធានី ខេត្តចំនួន១០ សម្រាប់ចំណាយបន្ទុកបុគ្គលិក។

### ខ.៧/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២២ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | 1 | 2 | 3 = (2/1) |
| **I. សរុបចំណូលថវិកា** | **៥៩៧ ៧២៣,៥** | **៥៨៥ ៥៥៦,០** | **៩៨,០%** |
| -ចំណូលចរន្ត (មិនមែនសារពើពន្ធ) | ៣០ ៦៦១,០* | ២៨ ៧០៣,០ | ៩៣,៦% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៥៤៨ ០៦៧,៥ | ៥៤៦ ៤០៥,៥ | ៩៩,៧% |
| • ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក | ៤១០ ៥១១,០** | ៤១០ ២៥៣,២** | ៩៩,៩% |
| • ការប្រគល់មុខងារអប់រំ | ១៣៧ ៥៥៦,៥*** | ១៣៦ ១៥២,៣ | ៩៩,០% |
| -ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៨ ៩៩៥,០ | ១០ ៤៤៧,៥ | ៥៥,០% |
| **II. សរុបចំណាយថវិកា** | **៥៩៧ ៧២៣,៥** | **៥៧៤ ១៥៩,២** | **៩៦,១%** |
| -ចំណាយចរន្ត | ៥៩៧ ៦២៣,៥**** | ៥៧៤ ០៦១,២ | ៩៦,១% |
| -ចំណាយមូលធន | ១០០,០***** | ៩៨,០ | ៩៨,០% |

<u>កំណត់សំគាល់:</u> កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២២ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

(*) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមដល់រដ្ឋបាលក្រុង ស្រុក ចំនួន១៨ ៤២១,០លានរៀល ក្នុងនោះ៖(១)- ឥណទានថវិកាចំនួន១៧៨,០លានរៀល ប្រភពពីចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ សម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត (២)-ឥណទានថវិកាចំនួន៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថានក្រុងគោលដៅទាំង២៨ (៣)-ឥណទានថវិកាចំនួន៩ ៨៣៣,០លានរៀល ចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលខេត្ត៤% ជូនរដ្ឋបាលក្រុង ស្រុក (៤)-ឥណទានថវិកាចំនួន៤១០,០លានរៀល ថវិកាពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ចំណាយអភិវឌ្ឍន៍។

(**) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន៨ ១២២,០លានរៀល ថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ចំណាយអភិវឌ្ឍន៍។

(***) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន៣ ១២៧,៥លានរៀល ថវិកាសម្រាប់អនុវត្តមុខងារអប់រំនៅខេត្តបាត់ដំបង។

(****) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកានិយ័តកម្មថ្នាក់ជាតិចំនួន២៩ ៤៩២,៥លានរៀល ក្នុងនោះ៖ (១)-ចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលខេត្ត៤%ជូនរដ្ឋបាលក្រុង ស្រុកចំនួន៩ ៨៣៣,០លានរៀល (២)-ថវិកាសេវាអនាម័យបរិស្ថានចំនួន៨ ០០០,០លានរៀល (៣)-ថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៨ ១២២,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍ (៤)-ថវិកាពីការផ្ទេរមុខងារ របស់ក្រសួងអភិវឌ្ឍន៍ជនបទចំនួន៤១០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍ (៥)-ថវិកាសម្រាប់ការផ្ទេរមុខងារអប់រំនៅខេត្តបាត់ដំបង ចំនួន៣ ១២៧,៥លានរៀល និង(៦)-ឥណទានថវិកាចំនួន១៧៨,០លានរៀល ប្រភពពីចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ សម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត។

(*****) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន៣៧ ១០០,០លានរៀល ប្រភពពីការផ្ទេរឥណទានថវិកាពីចំណាយចរន្តជំពូក៦៩ (ចំណាយមិនបានគ្រោងទុក)។

## ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២២ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **១ ០៨៦ ១៥២,៥** | **១ ១៣៣ ៧៩៣,៤** | **១០៤,៤%** |
| -ចំណូលមិនមែនសារពើពន្ធ | 0 | ៤៧ ៦៤១,0 | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិ | ៨៤៧ ៣៥៧,0 | ៨៤៧ ៣៥៧,0 | ១00,0% |
| -អតិរេកឆ្នាំ២០២១ | ២៣៨ ៧៩៥,៥* | ២៣៨ ៧៩៥,៤ | ១00,0% |
| **II. សរុបចំណាយថវិកា** | **១ ០៨៦ ១៥២,៥** | **៨៨១ ៨៨៣,៤** | **៨១,២%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ៦0 ៧៥៧,៤ | ៤៧ ៦៣៧,៩ | ៧៨,៤% |
| - ចំណាយសង្កាត់ចំណុះក្រុង | ៩៤ ៧៨៥,៩ | ៧៣ ១១៤,៣ | ៧៧,១% |
| -ចំណាយឃុំ | ៩៣0 ៦0៩,២ | ៧៦១ ១៣១,២ | ៨១,៨% |

<u>**កំណត់សំគាល់:**</u> កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២២ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន២៣៨ ៧៩៤,៤លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

# ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១. សហគ្រាសចុះបញ្ជីពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនពុំទាន់បានមកធ្វើបច្ចុប្បន្នភាព

ដើម្បីសម្រួលដល់ដំណើរការចុះបញ្ជីអាជីវកម្មឱ្យកាន់តែមានភាពងាយស្រួល និងរហ័សជាមុន រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ការចុះបញ្ជីអាជីវកម្មពីការចុះដោយផ្ទាល់មកចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយគ្រាន់តែផ្ដល់ព័ត៌មានពិតប្រាកដដែលតម្រូវដោយប្រព័ន្ធចុះបញ្ជី។ បន្ទាប់ពីសំណើចុះបញ្ជីត្រូវបានអនុម័តដោយប្រព័ន្ធ អ្នកស្នើសុំត្រូវអញ្ជើញមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីផ្ទៀងផ្ទាត់ឯកសារតម្រូវ ស្កេនមេដៃ និងថតរូប។ ក្នុងករណីដែលអ្នកស្នើសុំខកខាន អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិព្យួរ ឬដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់។

តាមការពិនិត្យស្ថិតិសហគ្រាសដែលចុះបញ្ជីពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន ១០ ៣២១ នៅក្នុងឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានសហគ្រាសមួយចំនួនធំ បានអញ្ជើញមកផ្ទៀងផ្ទាត់ឯកសារតម្រូវ ស្កេនមេដៃ ថតរូប និងធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធតាមការតម្រូវដោយអគ្គនាយកដ្ឋានពន្ធដាររួចរាល់ ចំណែកឯសហគ្រាសមួយចំនួនតូចទៀតពុំទាន់មកធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធនៅឡើយ។

ដោយសារការព្យួរ ឬការដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់មិនបានធ្វើឡើងទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារអាចជួបការលំបាកក្នុងការគ្រប់គ្រងព័ត៌មានរបស់អ្នកចុះបញ្ជីពន្ធ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគួរសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីជួយអគ្គនាយកដ្ឋានពន្ធដារមានវិធានការបន្ថែមទៀតចំពោះក្រុមហ៊ុនសហគ្រាស ដែលមិនមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសនៅអគ្គនាយកដ្ឋានពន្ធដារ បន្ទាប់ពីចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួចរាល់។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានពន្ធដារបានចាត់វិធានការជាបន្តបន្ទាប់ចំពោះសហគ្រាសទាំងនេះ មានដូចខាងក្រោម៖

គិតត្រឹមឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារបានចេញលិខិតរំលឹក និងអញ្ជើញម្ចាស់សហគ្រាសឱ្យមកធ្វើបច្ចុប្បន្នភាពព័ត៌មានចំនួន ១០ ៣៧៤។ ជាពិសេសក្នុងឆ្នាំ២០២៣ បានសម្របសម្រួល និងអភិវឌ្ឍមុខងារចេញលិខិតអញ្ជើញម្ចាស់សហគ្រាសដោយស្វ័យប្រវត្តិតាមថ្នាលCamDXរួចរាល់ ដើម្បីជូនដំណឹងទៅអ្នកជាប់ពន្ធឱ្យមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស បន្ទាប់ពីទទួលបានការសម្រេចឱ្យចុះបញ្ជី។

អគ្គនាយកដ្ឋានពន្ធដារបានជំរុញសហគ្រាសដែលស្នើសុំធ្វើការកែប្រែព័ត៌មានផ្សេងៗ ឱ្យធ្វើបច្ចុប្បន្នភាពព័ត៌មាន ថតរូប ស្កេនម្រាមដៃជាមុនសិន។

### ៣.១.២.ការចុះបញ្ជីអាជីវកម្មដ្ឋានតាមលទ្ធផលអង្កេត

អ្នកប្រកបអាជីវកម្ម ឬធ្វើសកម្មភាពសេដ្ឋកិច្ចមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។ ជាងនេះទៅទៀត បុគ្គលទាំងឡាយដែលចុះបញ្ជីពន្ធដោយស្ម័គ្រចិត្តនឹងទទួលបានការអនុគ្រោះពន្ធលើប្រាក់ចំណូល១% ប្រសិនបើបុគ្គលទាំងនោះបំពេញបានគ្រប់ជ្រុងជ្រោយតាមលក្ខខណ្ឌរបស់រដ្ឋបាលសារពើពន្ធ។

តាមការពិនិត្យលិខិតជំរុញការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធចំពោះសហគ្រាសដែលពុំទាន់ចុះបញ្ជីពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារជូនទៅសាខាពន្ធដារខណ្ឌចំនួន៥ ក្នុងចំណោមសាខាពន្ធដារខណ្ឌចំនួន៩ ក្នុងរាជធានីភ្នំពេញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ សាខាពន្ធដារខណ្ឌចំនួន៥ មានសហគ្រាស (អាជីវកម្មដ្ឋាន) ចំនួន១២ ៩៧៣ ពុំទាន់បានបំពេញកាតព្វកិច្ចចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធនៅឡើយ។ ករណីនេះសាខាពន្ធដារខណ្ឌទាំង៥ខាងលើបាននិងកំពុងចាត់វិធានការដោយបានចេញលិខិតអញ្ជើញសហគ្រាសចំនួន២ ៥០១ និងចុះបញ្ជីបានចំនួន៦៥៧ សហគ្រាសជាបណ្តើរៗផងដែរ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងសូមបំភ្លឺបន្ថែមថា ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារបានជំរុញការងារចុះបញ្ជីនេះយ៉ាងខ្លាំង ដោយបានតម្រូវឱ្យអង្គភាពទទួលបន្ទុកធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះបញ្ជីពន្ធដាររៀងរាល់ខែបញ្ជូនមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យតាមដាន ប៉ុន្តែកិច្ចការនេះនៅមានបញ្ហាប្រឈមមួយចំនួនដូចជា អ្នកជាប់ពន្ធមិនសហការ និងកិច្ចសន្យាជួលទីតាំងអាជីវកម្មមិនពេញលេញធ្វើឱ្យមិនអាចចុះបញ្ជីបាន។

### ៣.១.៣.វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញាតប័ណ្ណមួយចំនួនមានលក្ខណៈពុំទាន់សមស្របនៅឡើយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបញ្ជាក់ថា នាយកដ្ឋានផែនការ និងបច្ចេកទេសមានតួនាទី និងភារកិច្ចដូចជា៖ ស្រាវជ្រាវ និងចងក្រងនូវទិន្នន័យតម្លៃគិតពន្ធគយលើទំនិញនាំចេញ-នាំចូលតម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់ឱ្យបានសមស្របតាមភាពជាក់ស្តែង សម្រាប់ជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពគយ និងរដ្ឋាករពាក់ព័ន្ធ។ លិខិតស្តីពីការកែសម្រួលតារាងទិន្នន័យតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញនាំចូលនាំចេញមួយចំនួនរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រង់សេចក្តីណែនាំបន្ថែម បានបញ្ជាក់ថាចំពោះឯកតាគិតតម្លៃគិតពន្ធគយ ជាទម្ងន់ត្រូវផ្អែកលើមូលដ្ឋានទម្ងន់ទាំងសំបកវេចខ្ចប់

(Gross Weight) ដោយឡែកចំពោះមុខទំនិញដែលមានសំបកវេចខ្ចប់ជាប្រភេទកែវ និងខ្សែកាបអុកទិកត្រូវផ្អែកលើមូលដ្ឋានទម្ងន់សុទ្ធ (Net Weight)។

តាមការធ្វើសវនកម្មនៅអង្គភាពក្រោមចំណុះអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ឯកសារភ្ជាប់សម្រាប់កំណត់តម្លៃគិតតម្លៃពន្ធគយនាំចូលដូចជា៖ វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញាតប័ណ្ណមួយចំនួនមានលក្ខណៈពុំទាន់បានសមស្រប និងត្រឹមត្រូវនៅឡើយដូចជា៖ សំបកវេចខ្ចប់ទំនិញមួយចំនួនខុសទម្ងន់ ខុសបរិមាណ ខុសវិក្កយបត្រជាដើម។ កត្តានេះ នាំឱ្យការប្រកាសតម្លៃគិតពន្ធលើទំនិញនាំចូលមួយចំនួនមានលក្ខណៈពុំទាន់បានសមស្របនៅឡើយ និងអាចនាំឱ្យប៉ះពាល់ដល់ចំណូលប្រាក់ពន្ធដែលត្រូវប្រមូល។

ចំពោះករណីកំហុសដូចមានក្នុងលិខិតបញ្ជាក់ផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ដែលមន្ត្រីគយមានសមត្ថកិច្ចពិតជាខកខានមិនបានផ្ទៀងផ្ទាត់លម្អិត និងសូមបំភ្លឺបន្ថែមថា៖

- ករណីទឹកសុទ្ធ និង Pocari Sweat៖ បើប្រៀបធៀបរវាងទម្ងន់សុទ្ធ (N.W) ដែលបានប្រកាស និងទម្ងន់ទឹកតាមការ Convert ពីចំណុះលីត្រ ពិតជាមានគម្លាតធំគួរឱ្យកត់សម្គាល់មែន។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) ទទួលស្គាល់ថា បញ្ហានេះ មន្ត្រីគយមានសមត្ថកិច្ចពិតជាខកខានមិនបានផ្ទៀងផ្ទាត់បរិមាណជាលីត្រ ជាមួយទម្ងន់សរុបមែន ដោយសារតម្លៃជាមូលដ្ឋានពិចារណាគិតលើបរិមាណជាលីត្រ

- ករណីទឹក Pocari Sweat៖ បើផ្អែកលើទម្ងន់សុទ្ធ (N.W) ដែលបានប្រកាស និងចំណុះទឹកជាលីត្រ សង្កេតឃើញថាមានទម្ងន់ 1.045Kg/លីត្រ។ ជាទូទៅ ទឹកសុទ្ធធម្មតាមានទម្ងន់ 1Kg/លីត្រ។ អគរ នឹងធ្វើការផ្ទៀងផ្ទាត់បន្ថែមទៀត លើទម្ងន់ទឹកសុទ្ធប្រភេទ Pocari Sweat នេះ។ បើឃើញថាមានកំហុស នឹងតម្រូវឱ្យអ្នកនាំចូលធ្វើការកែតម្រូវ

- ករណី Chili Sauce និង Malt៖ ជាករណីឯកសារពាណិជ្ជកម្មគ្មានសង្គតិភាព បណ្ដាលមកពីការធ្វេសប្រហែសរបស់អ្នកនាំចូល ដែលបានបញ្ចូលតួលេខ ទម្ងន់ទំនិញក្នុង១កញ្ចប់ មិនត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ បើផ្ទៀងផ្ទាត់ជាមួយទម្ងន់សរុប ករណីនេះមិនធ្វើឱ្យប៉ះពាល់ដល់ប្រាក់ពន្ធអាករឡើយ ដោយហេតុថាការប្រកាសតម្លៃគិតពន្ធគយផ្អែកលើឯកតាចំនួនកេស

- ករណី Skin Care (FOC)៖ ជាករណីទំនិញ Free of Charge ប៉ុន្តែត្រូវជាប់កាតព្វកិច្ចពន្ធ និងអាករ អ្នកនាំចូលមានការធ្វេសប្រហែសបញ្ចូលខុសចំនួនក្នុងប្រព័ន្ធប្រតិវេទន៍តម្លៃគិតពន្ធគយ ដែលធ្វើឱ្យខ្វះប្រាក់ពន្ធ និងអាករប្រមាណ ៧៤២ដុល្លារអាមេរិក។ អគរនឹងកោះហៅម្ចាស់ទំនិញឱ្យមកបង់ពន្ធ និងអាករបន្ថែមឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន

- ករណី Aluminum Profile៖ ជាករណីដែលអ្នកនាំចូលធ្វេសប្រហែសប្រកាសបរិមាណទំនិញ (ឯកតាជា PC) នៅលើវិក្កយបត្រ តិចជាងបរិមាណនៅលើបញ្ជីវេចខ្ចប់។ ទោះជាយ៉ាងណាក៏ដោយ បើផ្អែកលើមូលដ្ឋានទម្ងន់ តម្លៃគិតពន្ធគយដែលបានប្រកាសមាន

ភាពសមស្របតាមតម្លៃជាមូលដ្ឋានពិចារណារបស់ អគរ ពោលគឺមិនប៉ះពាល់ដល់ប្រាក់ពន្ធអាករឡើយ។

ម្យ៉ាងទៀត ក្នុងន័យសម្រួលពាណិជ្ជកម្ម ដោយរក្សាបាននូវតុល្យភាពជាមួយការគ្រប់គ្រង អនុលោមភាព មន្ត្រីគយមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យឯកសារដោយផ្អែកលើគោលការណ៍ហានិភ័យ ពោលគឺមិនធ្វើការត្រួតពិនិត្យលម្អិតគ្រប់ឯកសារឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តកែលម្អយន្តការនៃការជ្រើសរើសមុខសញ្ញាហានិភ័យ ព្រមទាំងណែនាំដល់មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចឱ្យពង្រឹងការផ្ទៀងផ្ទាត់ឯកសារឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

### ៣.១.៤.ភាពយឺតយ៉ាវក្នុងការចុះបញ្ជីម៉ាក

ប្រកាសអន្តរក្រសួងរវាងក្រសួងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម លេខ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ស្តីពីការផ្តល់សេវារបស់ក្រសួងពាណិជ្ជកម្ម បានកំណត់រយៈពេលអតិបរមានៃការដាក់ពាក្យស្នើសុំចុះបញ្ជីការត្រួតពិនិត្យលម្អិត ការចុះបញ្ជីនិងបោះពុម្ពផ្សាយម៉ាកពី៩ខែ ទៅ៧ខែ។

តាមរយៈការត្រួតពិនិត្យលើតារាងនៃការចុះបញ្ជីម៉ាកដែលបានទាញចេញពីប្រព័ន្ធស្វ័យប្រវត្តិកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០២២ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានចុះបញ្ជីម៉ាកសរុបចំនួន ៣ ៥៩៥ក្រុមហ៊ុន ក្នុងនោះការចុះបញ្ជីម៉ាកចំនួន ២ ៣០៥ ក្រុមហ៊ុនមានភាពយឺតយ៉ាវក្នុងការផ្តល់ជូនដល់ក្រុមហ៊ុនដែលបានដាក់ពាក្យសុំចុះបញ្ជីម៉ាកពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១។

ភាពយឺតយ៉ាវនៃការផ្តល់សេវាសាធារណៈរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការផ្តល់សេវា។ អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្ម គួរណែនាំឱ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញាអនុវត្តការផ្តល់សេវាលើការចុះបញ្ជីម៉ាកឱ្យបានទាន់ពេលវេលាស្របតាមរយៈពេលកំណត់។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងពាណិជ្ជកម្មបានឯកភាព និងបំភ្លឺថា ចំណុចនេះ ក្រសួងពាណិជ្ជកម្មសូមធ្វើការបង្ហាញអំពីកត្តាដែលធ្វើឱ្យមានភាពយឺតយ៉ាវដូចជា៖ អ្នកដាក់ពាក្យស្នើសុំមិនបានបំពេញពាក្យស្នើសុំឱ្យបានត្រឹមត្រូវ និងឆ្លើយតបមកនាយកដ្ឋានជំនាញ ក្នុងការផ្តល់ឯកសារគាំទ្រឱ្យបានទាន់ពេលវេលា។ ម៉ាកដែលបានដាក់ពាក្យផ្ទុយនឹងមាត្រា៤នៃច្បាប់ម៉ាកដែលមានចែងពីម៉ាកដែលមិនអាចចុះបញ្ជីបាន ករណីនេះ យោងតាមនីតិវិធីនៃការត្រួតពិនិត្យម៉ាកលម្អិត នាយកដ្ឋានត្រូវធ្វើការបដិសេធជាបឋម និងទុករយៈពេលឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើសវនការ ឬផ្តល់ភស្តុតាងដើម្បីបង្ហាញភាពជាម្ចាស់ម៉ាក ឬកែសម្រួលម៉ាក។ បើមានការតវ៉ាណាមួយពីភាគីពាក់ព័ន្ធ អ្នកដាក់ពាក្យត្រូវដោះស្រាយវិវាទចំពោះម៉ាករបស់ខ្លួនដែលដូចឬស្រដៀង នាំឱ្យមានការភ័ន្តច្រឡំទៅនឹងម៉ាកដទៃទៀត ដែលកំពុងដាក់ពាក្យស្នើសុំ

ឬបានចុះបញ្ជីរួចហើយឱ្យបានចប់សព្វគ្រប់ ទើបនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចធ្វើការចុះបញ្ជីម៉ាក ដែលមានភាពញែកដាច់ជូនបាន។ អ្នកដាក់ពាក្យបានស្នើសុំធ្វើការផ្លាស់ប្តូរអាស័យដ្ឋានទំនាក់ទំនង ឬស្នើសុំពន្យាពេលក្នុងការផ្តល់ឯកសារគាំទ្រ ឬមានការយឺតយ៉ាវក្នុងការបង់កម្រៃសេវាសាធារណៈចុះបញ្ជីម៉ាក។ អ្នកដាក់ពាក្យនៅរង់ចាំសេចក្តីសម្រេចពីការប្តឹងមោឃភាពការចុះបញ្ជីម៉ាក ឬបណ្តឹងលុបម៉ាកចេញពីបញ្ជី។ អ្នកដាក់ពាក្យនៅរង់ចាំការសម្របសម្រួលពីការប្តឹងជំទាស់ក្នុងការចុះបញ្ជីម៉ាក (ត្រូវរង់ចាំការដោះស្រាយឱ្យបានចប់សិនដោយផ្អែកលើឯកសារគាំទ្រ) ឬមានការឯកភាពគ្នាពីភាគីទាំងសងខាងស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

### ៣.១.៥.ការមិនមានរបាយការណ៍ ឬកំណត់ហេតុក្នុងការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក

ប្រកាសលេខ១៨៩០សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានកំណត់ឱ្យមានការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងដោយអាណាប័ក ឬដោយអ្នកតំណាងត្រូវធ្វើឱ្យបានញឹកញាប់បំផុត។ គោលការណ៍នៃការទទួលស្គាល់មូលនិធិ និងតម្លៃត្រូវធ្វើឱ្យបានម្តងក្នុងមួយត្រីមាស។ ការផ្ទៀងផ្ទាត់របស់គណនេយ្យករសាធារណៈត្រូវធ្វើឡើងយ៉ាងហោចណាស់មួយឆ្នាំម្តង និងត្រូវមានរបាយការណ៍ ឬកំណត់ហេតុត្រឹមត្រូវច្បាស់លាស់ ដែលក្នុងនោះត្រូវកត់សម្គាល់នូវកិច្ចការដែលបានពិនិត្យឃើញ។ ឯកសារទាំងនោះត្រូវផ្តល់ឱ្យរដ្ឋទេយ្យករចំណូលធ្វើការកត់សម្គាល់ និងផ្តល់នូវចម្លើយ ហើយត្រូវធ្វើត្រឡប់ទៅអ្នកត្រួតពិនិត្យវិញ។ តាមការធ្វើសវនកម្មក្រសួងសាធារណការ និងដឹកជញ្ជូនសម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងពុំទាន់មានរបាយការណ៍ ឬកំណត់ហេតុស្តីពីការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក ឬអ្នកតំណាង ហើយក៏ពុំមានការផ្ទៀងផ្ទាត់ការគ្រប់គ្រងចំណូលពីគណនេយ្យករសាធារណៈឡើយ។

ការមិនមានរបាយការណ៍ ឬកំណត់ហេតុក្នុងការត្រួតពិនិត្យផ្ទាល់ដោយអាណាប័កជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការផ្ទៀងផ្ទាត់លើការគ្រប់គ្រងចំណូល។ អាស្រ័យហេតុនេះ ក្រសួងគួរសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុវត្តតាមប្រកាសខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានឯកភាព និងបំភ្លឺថានៅតាមអង្គភាពដែលមានកាតព្វកិច្ចប្រមូលចំណូល ក្រសួងបានធ្វើការតែងតាំងរដ្ឋទេយ្យករចំណូលរងជូនអង្គភាពរួចរាល់ហើយ ដូច្នេះរដ្ឋទេយ្យករចំណូលរងនៃអង្គភាពប្រមូលចំណូលនីមួយៗត្រូវរៀបចំរបាយការណ៍ត្រួតពិនិត្យផ្ទាល់ជូនរដ្ឋទេយ្យករចំណូលរបស់ក្រសួងឱ្យបាន

ទៀងទាត់។ ទន្ទឹមនេះ ក្រសួងសាធារណការ និងដឹកជញ្ជូននឹងសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តតាមប្រកាសខាងលើឱ្យមានប្រសិទ្ធភាពបន្ថែមទៀត។

### ៣.១.៦.ការប្រមូលចំណូលសេវាសាធារណៈរបស់ភ្នាក់ងារប្រមូលពុំមានលិខិតបង្គាប់ការច្បាស់លាស់

សារាចរណែនាំលេខ០០៥ សហវ. ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ ត្រង់ចំណុចទី៤ បានកំណត់ថា "មានតែអ្នកប្រមូលចំណូលជាអ្នកអនុវត្តហែកបង្កាន់ដៃបង់ប្រាក់ជូនអតិថិជន...។ ការបង្កើតរជ្ជទេយ្យចំណូល និងការតែងតាំងរជ្ជទេយ្យករចំណូល ឬរជ្ជទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូល ត្រូវអនុវត្តតាមនីតិវិធី និងតាមគំរូណែនាំដែលមានជាធរមាន។ ក្រសួង-ស្ថាប័នគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យចំណូល និងការតែងតាំងរជ្ជទេយ្យករចំណូល ឬរជ្ជទេយ្យករចំណូលរង ឬភ្នាក់ងារប្រមូលចំណូលចំនួនមួយច្បាប់មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ដើម្បីតម្កល់ទុកជាឯកសារ"។

តាមការធ្វើសម្ភាសន៍ជាមួយមន្ត្រីប្រមូលចំណូលផ្ទាល់ពីសេវាសាធារណៈ និងពិនិត្យបញ្ជិកាគណនេយ្យរបស់មន្ត្រីដែលជាភ្នាក់ងារប្រមូលចំណូលរបស់នាយកដ្ឋានសារមន្ទីរជាតិ (សារមន្ទីរជាតិ និងគុកទួលស្លែង) ក្នុងឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការអនុវត្តរបស់មន្ត្រីដែលជាភ្នាក់ងារប្រមូលចំណូលពីការចូលទស្សនាសារមន្ទីរជាតិ និងគុកទួលស្លែង ពុំមានលិខិតបង្គាប់ការប្រកាសជាផ្លូវការដើម្បីបញ្ជាក់ថា ពួកគាត់ជាភ្នាក់ងារប្រមូលចំណូលរបស់នាយកដ្ឋានសារមន្ទីរជាតិនោះទេ។

អាស្រ័យហេតុនេះ អង្គភាពប្រមូលចំណូលនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួររៀបចំលិខិតបង្គាប់ការសម្រាប់មន្ត្រីដែលជាភ្នាក់ងារប្រមូលចំណូលជាផ្លូវការឱ្យបានច្បាស់លាស់។

ត្រង់ចំណុចនេះ នាយកដ្ឋានសារមន្ទីរបានបំភ្លឺថា មានការខ្វះខាតលើការចេញលិខិតបង្គាប់ការចំពោះមន្ត្រីដែលជាភ្នាក់ងារប្រមូលចំណូលរបស់សារមន្ទីរជាតិ និងសារមន្ទីរទួលស្លែងពិតប្រាកដមែន។ បើទោះជាសារមន្ទីរទាំងពីរខ្វះខាតលើលិខិតផ្លូវការពីក្រសួងពិតមែន ប៉ុន្តែការអនុវត្តកន្លងមកនាយកដ្ឋានយល់ឃើញថា កិច្ចការនេះ នាយកដ្ឋានមានសិទ្ធិក្នុងការចេញលិខិតបង្គាប់ការជូនមន្ត្រីឱ្យអនុវត្តការងារផ្សេងៗបានដូចកិច្ចការរដ្ឋដទៃទៀត ទើបនាយកដ្ឋានសម្រេចចិត្តចេញលិខិតបង្គាប់ការផ្ទៃក្នុងចាត់មន្ត្រីបំរើការនៅសារមន្ទីរទាំងពីរ ដើម្បីប្រមូលចំណូលពីការលក់សំបុត្រ ប៉ុន្តែលិខិតនោះពុំបានចម្លងជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ដោយហេតុថា កន្លងមកការអនុវត្តយន្តការផ្ទៃក្នុងនេះពុំដែលទទួលបានអនុសាសន៍ណែនាំអំពីក្រុមការងារជំនាញទើបនាយកដ្ឋានបន្តប្រើប្រាស់យន្តការមួយនេះរហូតដល់ពេលបច្ចុប្បន្ន។ ការណែនាំពីប្រតិភូសវនកម្មជាតិ និងតាមការណែនាំរបស់លោកប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៅឆ្នាំ២០២២ នាយកដ្ឋានសារមន្ទីរបានទទួលយកអនុសាសន៍ណែនាំចំពោះ

ចំណុចខ្វះខាត ហើយបច្ចុប្បន្ននាយកដ្ឋានបានរៀបចំធ្វើលិខិតបង្គាប់ការថ្មីមួយទៀតស្រប តាមខ្លឹមសារនៃការណែនាំរបស់ជំនាញ ពោលគឺលិខិតថ្មីនេះបានចម្លងជូនក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

**៣.១.៧.ការរៀបចំបញ្ជីបេឡាថវិការជ្ជទេយ្យបុរេប្រទានកម្មវិធី**

ប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ បានកំណត់ថា "បញ្ជីបេឡាសម្រាប់កត់ត្រាចំនួនទឹកប្រាក់រជ្ជទេយ្យបុរេប្រទានដែលបានទទួល ពីគណនេយ្យករសាធារណៈ ទឹកប្រាក់ដែលបានចំណាយ និងទឹកប្រាក់ដែលនៅសល់"។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រជ្ជទេយ្យករបុរេប្រទាន របស់អង្គភាពថវិកានាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុនៃក្រសួងអភិវឌ្ឍន៍ជនបទពុំបានកត់ត្រា បញ្ចូលប្រតិបត្តិការចំណាយថវិការជ្ជទេយ្យបុរេប្រទាន (ប័ណ្ណចំណាយ) ក្នុងឆ្នាំ២០២២ ចូល ក្នុងបញ្ជីបេឡាថវិការជ្ជទេយ្យបុរេប្រទានកម្មវិធីនៅឡើយ។

ដើម្បីធានាដល់ការគ្រប់គ្រងថវិការជ្ជទេយ្យបុរេប្រទានមានតម្លាភាព ក្រសួងអភិវឌ្ឍន៍ ជនបទ គួរធ្វើការណែនាំដល់រជ្ជទេយ្យករបុរេប្រទាននៃអង្គភាពថវិកាខាងលើអនុវត្តការកត់ត្រា ចំណូល-ចំណាយថវិការជ្ជទេយ្យបុរេប្រទានចូលក្នុងបញ្ជីបេឡាឱ្យបានពេញលេញ និងត្រឹមត្រូវ ស្របតាមប្រកាសខាងលើ។ តាមរយៈការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួង អភិវឌ្ឍន៍ជនបទសូមទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ហើយក្រសួងនឹង ធ្វើការណែនាំដល់មន្ត្រីជំនាញកុំឱ្យមានការភ័ន្តច្រឡំបន្តទៀតសម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់។

**៣.១.៨.ភាពយឺតយ៉ាវក្នុងការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង**

បទបញ្ជាលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១១ បន្ទាត់ទី៥ បានចែង ថា "ចំពោះក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុង និងមន្ទីរជំនាញខេត្ត-ក្រុងទាំងឡាយណាដែល កំពុងអនុវត្តចំណូលតែមិនទាន់បានបង្កើតរជ្ជទេយ្យចំណូល និងតែងតាំងរជ្ជទេយ្យចំណូលរង ត្រូវរួសរាន់រៀបចំបង្កើតរជ្ជទេយ្យករចំណូល រជ្ជទេយ្យករចំណូលរងដោយប្រកាសអន្តរក្រសួង ឬដោយដីការបស់អភិបាលខេត្ត-ក្រុង ហាមដាច់ខាតការប្រគល់ភារកិច្ចប្រមូល ឬទទួល ចំណូល និងការទទួលខុសត្រូវប្រាក់កាសឱ្យទៅមន្ត្រីដែលពុំមែនជារជ្ជទេយ្យករចំណូល"។

ប្រកាសលេខ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ ត្រង់ជំពូកទី២ ផ្នែកទី២ ប្រការ៦ បានចែងថា "រជ្ជទេយ្យករចំណូលអាចមានរជ្ជ ទេយ្យករចំណូលរងមួយចំនួនជាជំនួយការ តាមការចាំបាច់។ ចំពោះរដ្ឋបាលថ្នាក់ជាតិ រជ្ជ ទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង ត្រូវតែងតាំងឡើងដោយប្រកាសអន្តរក្រសួង

រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈសាមីតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ"។

តាមការពិនិត្យនៅអង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ នៅពុំទាន់មានរដ្ឋទេយ្យករចំណូលថ្មីជំនួសរដ្ឋទេយ្យករចំណូលចាស់ដែលត្រូវផ្ទេរភារកិច្ចទៅបម្រើការងារនៅក្រសួងផ្សេង។ ឯចំណែកនាយកដ្ឋាននីតិកម្មកសិកម្មនៅពុំទាន់មានរដ្ឋទេយ្យករចំណូលរងថ្មី ជំនួសរដ្ឋទេយ្យករចំណូលរងចាស់ដែលបានចូលនិវត្តន៍។ លើសពីនេះទៀត មន្ត្រីនៃនាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ នាយកដ្ឋានសត្វព្រៃ និងជីវៈចម្រុះ នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិនៃរដ្ឋបាលព្រៃឈើ និងការិយាល័យផែនការសហប្រតិបត្តិការ និងពាណិជ្ជកម្មនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាពុំទាន់មានប្រកាសអន្តរក្រសួងតែងតាំងជាផ្លូវការជារដ្ឋទេយ្យករចំណូលរង ឬជាភ្នាក់ងារប្រមូលចំណូលទេ ប៉ុន្តែមន្ត្រីនេះជាអ្នកប្រមូលចំណូល និងជាអ្នករក្សាទុកសាច់ប្រាក់។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគួរស្នើសុំរៀបចំតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ឬជាភ្នាក់ងារប្រមូលចំណូលឱ្យបានទាន់ពេលវេលា និងស្របតាមបទបញ្ញា និងប្រកាសណែនាំខាងលើ។

ចំពោះចំណុចនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមឯកភាពតាមខ្លឹមសារនៃរបាយការណ៍សវនកម្មនេះ និងខិតខំព្យាយាមកែលម្អនូវចំណុចខ្វះខាតទាំងឡាយដែលបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។

### ៣.១.៩.ប័ណ្ណប៉ាតង់ពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ

ប្រកាសលេខ១៩៨សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៨ បានតម្រូវឱ្យការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ និងសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាទាំងនោះ។

ក្នុងការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាៈ

- ក្រុមលទ្ធកម្មចំនួន៣នៃក្រសួងបរិស្ថានបានធ្វើការវាយតម្លៃ និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដែលមានប៉ាតង់ពុំស្របនឹងកម្មវត្ថុនៃពិគ្រោះថ្លៃលើការទិញស្បៀង (ទឹកសុទ្ធ កាហ្វេ តែ ស្ករ) គឺក្រុមហ៊ុនមានប៉ាតង់ (លក់សម្ភារសម្អាត គ្រឿងសង្ហារឹម សម្ភារការិយាល័យ .....)។
- អង្គភាពលទ្ធកម្មមួយរបស់ក្រសួងពាណិជ្ជកម្មបានជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃ ពិគ្រោះថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាដែលមានប័ណ្ណប៉ាតង់មិនស្រប

តាមកម្មវត្ថុនៃការដេញថ្លៃចំនួន២គម្រោង១.ទិញឧបករណ៍ត្រួតពិនិត្យប្រេងឥន្ធនៈ និងសម្ភារបរិក្ខារក្នុងមន្ទីរពិសោធន៍អស់ទឹកប្រាក់ចំនួន ៧៤០ ៧២០ ០០០រៀល និង ២.ទិញប្រតិករគីមី និងសម្ភារការពារសុវត្ថិភាពប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ អស់ទឹកប្រាក់ចំនួន ៣ ៥៩៧ ៦២២ ០០០រៀល។ ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុនចូលរួមគឺ ១.សេវាជួសជុល និងតុបតែងអគារ ២.អាហារ៍ណ នីហរ៍ណ (សម្ភារការិយាល័យ) ៣.សេវាជួសជុលអគារ គ្រឿងអេឡិចត្រូនិក និងរថយន្ត។

- មន្ទីរចំនួន៦នៃខេត្តត្បូងឃ្មុំបានវាយតម្លៃ និងទទួលយកសំណុំឯកសារពិគ្រោះថ្លៃ ឬស្ទង់តម្លៃនៃគម្រោងនីមួយៗដែលមានអ្នកផ្គត់ផ្គង់ចំនួន៣ ចូលរួម ក្នុងនោះមានសហគ្រាសចំនួន១ ឬ២ បានភ្ជាប់ប័ណ្ណប៉ាតង់ពុំស្របតាមកម្មវត្ថុនៃការពិគ្រោះថ្លៃ ឬស្ទង់តម្លៃ។

ដោយហេតុនេះហើយ ដើម្បីឱ្យការអនុវត្តកិច្ចលទ្ធកម្មបានត្រឹមត្រូវ និងស្របតាមបទប្បញ្ញត្តិ ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម និងមន្ទីរនានានៃខេត្តត្បូងឃ្មុំ គួរខិតខំអនុវត្តតាមប្រកាសខាងលើឱ្យបានត្រឹមត្រូវ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ៖

- ក្រុមការងារលទ្ធកម្មនៃក្រសួងបរិស្ថាន បានឯកភាពទទួលយកលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។
- ក្រសួងពាណិជ្ជកម្មបានឯកភាពនិងបំភ្លឺថា អង្គភាពលទ្ធកម្មរបស់ក្រសួងពាណិជ្ជកម្មបានជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃ ពិគ្រោះថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាដែលមានផលរបរអាជីវកម្មក្នុងប័ណ្ណប៉ាតង់មិនស្របតាមកម្មវត្ថុនៃការដេញថ្លៃ។ ក្រសួងពាណិជ្ជកម្ម សង្កេតឃើញថា កត្តាទាំងនេះមកពីការរៀបចំទុកដាក់ឯកសារឡើងវិញរបស់មន្ត្រីជំនាញ ដែលបានរៀបចំប័ណ្ណប៉ាតង់ខុសមុខសញ្ញាចូលក្នុងដុំឯកសារដេញថ្លៃ
- មន្ទីរមួយចំនួននៃខេត្តត្បូងឃ្មុំ បានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ទន្ទឹមនឹងនេះ មន្ទីរមួយចំនួននៃខេត្តត្បូងឃ្មុំនឹងខិតខំពង្រឹង និងកែលម្អនូវចំណុចខ្វះខាតទាំងឡាយពាក់ព័ន្ធដែលមិនទាន់ស្របតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិ។ មន្ទីរមួយចំនួនទៀតនៃខេត្តត្បូងឃ្មុំនឹងអនុវត្តឆ្នាំបន្តបន្ទាប់ឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។

### ៣.១.១០.ការពុំដាក់ការផ្គត់ផ្គង់ឯកសណ្ឋាន និងសញ្ញាស័ក្តិបញ្ចូលក្នុងផែនការលទ្ធកម្ម

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី បានបញ្ជាក់ថា ប្រភេទចំណាយតម្រូវអនុវត្តនីតិវិធីលទ្ធកម្មសម្រាប់មុខចំណាយសម្លៀកបំពាក់

និងការតុបតែង រួមមានៈ ចំណាយលើឯកសណ្ឋាន សម្លៀកបំពាក់ការពារសុវត្ថិភាព មេដាយ សញ្ញាស័ក្តិ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ជូនមន្ត្រីមានសមត្ថកិច្ច និងមន្ត្រីរាជការ ដែលតម្រូវឱ្យមានឯកសណ្ឋានតាមច្បាប់កំណត់ ត្រូវអនុវត្តនីតិវិធីហិរញ្ញវត្ថុជាធរមាន ក្នុង នោះរួមមាន ការស្នើសុំគោលការណ៍ធានាចំណាយ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការទូទាត់ និងប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្ម បានតម្រូវឱ្យអង្គភាពប្រើ ប្រាស់នីមួយៗនៃស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពប្រើប្រាស់នីមួយៗនៃអង្គភាពថវិកាត្រូវ រៀបចំគម្រោងតម្រូវការប្រើប្រាស់ប្រចាំឆ្នាំតាមប្រភេទលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និង សេវាទីប្រឹក្សា ដោយបញ្ជាក់អំពីបរិមាណ តម្លៃ លក្ខណៈបច្ចេកទេស និងពេលវេលាប្រើប្រាស់ រួចបញ្ជូនទៅអង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្ម។

តាមការត្រួតពិនិត្យលើផែនការលទ្ធកម្ម និងឯកសារទូទាត់ពាក់ព័ន្ធនឹងចំណាយ ការ ផ្គត់ផ្គង់ឯកសណ្ឋាន និងសញ្ញាស័ក្តិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងពាណិជ្ជ កម្ម និងអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ បានចំណាយសម្រាប់ការផ្គត់ផ្គង់ឯកសណ្ឋាន និងសញ្ញាស័ក្តិជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម អស់ទឹកប្រាក់សរុបចំនួន ៧៨០ ៥៧៥ ០០០រៀល ដោយពុំបានដាក់ បញ្ចូលទៅក្នុងផែនការលទ្ធកម្ម។

ការអនុវត្តខាងលើ អាចនាំឱ្យចំណាយលើការផ្គត់ផ្គងឯកសណ្ឋាន និងសញ្ញាស័ក្តិពុំ ទាន់អនុវត្តប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងការសន្សំសំចៃ។ អាស្រ័យហេតុនេះ ក្រសួង ពាណិជ្ជកម្ម គួរប្រមូលផ្តុំតម្រូវការផ្គត់ផ្គងឯកសណ្ឋាន និងសញ្ញាស័ក្តិដាក់បញ្ចូលទៅក្នុង គម្រោងផែនការលទ្ធកម្ម ដើម្បីអនុវត្តនីតិវិធីកិច្ចលទ្ធកម្មឱ្យបានសមស្រប។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងពាណិជ្ជកម្មបានឯកភាព និងបំភ្លឺថា ដោយការអនុវត្ត កន្លងមកមានលក្ខណៈដូចៗគ្នា និងមានការអនុញ្ញាតក្នុងការធានាចំណាយក្នុងការជ្រើសរើស អ្នកផ្គត់ផ្គង់ ក្រសួងពាណិជ្ជកម្មបានអនុវត្តនីតិវិធីនេះ។ ទោះជាយ៉ាងនេះក្តី ក្នុងឆ្នាំ២០២៣នេះ ក្រសួងពាណិជ្ជកម្មបានធ្វើការបញ្ចូលការផ្គត់ផ្គង់ឯកសណ្ឋាននិងសញ្ញាស័ក្តិដាក់បញ្ចូលទៅ ក្នុងគម្រោងផែនការលទ្ធកម្ម ដើម្បីអនុវត្តនីតិវិធីលទ្ធកម្មក្នុងឆ្នាំ២០២៤ឱ្យបានសមស្របតាម នីតិវិធីជាធរមាន។

### ៣.១.១១.កង្វះខាតក្នុងការបិទផ្សាយរបាយការណ៍ជាសាធារណៈស្តីពីវត្តមានរបស់មន្ត្រីរាជ ការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យានៅតាមអង្គភាព

អនុក្រឹត្យរបស់រាជរដ្ឋាភិបាលស្តីពីការគ្រងគ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រី ជាប់កិច្ចសន្យា បានបញ្ជាក់ថា ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ត្រូវបូកសរុប និងចុះហត្ថលេខា លើរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍ និងប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់

កិច្ចសន្យារបស់អង្គភាពខ្លួនឱ្យបានត្រឹមត្រូវ និងតម្លាភាព ដោយត្រូវបិទផ្សាយជាសាធារណៈ ក្នុងអង្គភាពរបស់ខ្លួនរាល់ដំណាច់សប្តាហ៍។ របាយការណ៍ និងឯកសារពាក់ព័ន្ធត្រូវរក្សាទុកនៅតាមអង្គភាពសាមីនីមួយៗ។ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាមានសិទ្ធិពិនិត្យមើលឯកសារពាក់ព័ន្ធនឹងវត្តមាននៅក្នុងអង្គភាពរបស់ខ្លួន។

តាមការធ្វើសវនកម្មនៅក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពមួយចំនួននៅពុំទាន់បានបិទផ្សាយជាសាធារណៈ ក្នុងអង្គភាពរបស់ខ្លួនរាល់ដំណាច់សប្តាហ៍អំពីរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍ និងប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន គួរជំរុញអង្គភាពជំនាញអនុវត្តគ្រប់គ្រងផ្ទាល់ ត្រូវបិទផ្សាយជាសាធារណៈក្នុងអង្គភាពរបស់ខ្លួន រាល់ដំណាច់សប្តាហ៍អំពីរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍ និងប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាឱ្យមានប្រសិទ្ធភាព។

ចំពោះចំណុចនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍សវនកម្ម។

### ៣.១.១២.កង្វះខាតក្នុងការបំពេញព្រឹត្តិបត្រការងារប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល

អនុក្រឹត្យរបស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា បានបញ្ជាក់ថា មន្ត្រីរាជការស៊ីវិលមានសិទ្ធិសុំច្បាប់ឈប់សម្រាកតាមនីតិវិធី និងរយៈពេល ដូចមានចែងនៅក្នុងបទប្បញ្ញត្តិជាធរមាន។ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ត្រូវមានព្រឹត្តិបត្រការងារប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល។ មន្ត្រីមានសមត្ថកិច្ចក្នុងការអនុញ្ញាតឱ្យមានការឈប់សម្រាកលើសរយៈពេលកំណត់របស់រដ្ឋាភិបាលឡើយ។ ការឈប់សម្រាកដែលទទួលបានការអនុញ្ញាតលើសរយៈពេលកំណត់នេះ ត្រូវចាត់ទុកថាអវត្តមានគ្មានច្បាប់អនុញ្ញាត។ រាល់អវត្តមានមានច្បាប់ និងអវត្តមានគ្មានច្បាប់អនុញ្ញាត ត្រូវតែចុះក្នុងព្រឹត្តិបត្រការងារប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសាធារណការ និងដឹកជញ្ជូននៅមិនទាន់បានរៀបចំអនុវត្តឱ្យមានព្រឹត្តិបត្រការងាររបស់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន គួរជំរុញអង្គភាពជំនាញត្រូវរៀបចំអនុវត្តឱ្យមានព្រឹត្តិបត្រការងាររបស់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំឱ្យមានប្រសិទ្ធភាព។

ចំពោះចំណុចនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានឯកភាព និងសន្យាអនុវត្តតាមអនុសាសន៍សវនកម្ម។

### ៣.១.១៣.ការទូទាត់ចំណាយឆ្លងឆ្នាំ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ត្រង់មាត្រា១១ ចែងថា "ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ហើយបញ្ចប់វិញថ្ងៃទី៣១ ខែធ្នូ"។

សារាចរណែនាំលេខ០១០ សហវ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២២ ត្រង់ ចំណុចខ បានបញ្ជាក់ថា "ការបិទបញ្ជីចំណាយ (មាត្រា១០៧នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥) ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយ និងពេលវេលាដូចតទៅៈ

"រាល់ការសន្យាចំណាយក្រៅពីចំណាយបៀវត្ស ចំណាយក្រៅបន្ទុកបុគ្គលិកផ្សេងៗទៀតដែលមានគោលការណ៍កំណត់ច្បាស់លាស់ និងចំណាយសម្រាប់គោលនយោបាយសង្គមកិច្ច មិនអាចអនុវត្តក្រោយថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ បានទេ (មាត្រា១០៨ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥) លើកលែងតែមុខចំណាយទាំងឡាយណាដែលប្រញាប់ និងចាំបាច់បំផុតមិនអាចខកខានបាននឹងត្រូវតែមានឥណទានថវិកានៅសល់ទំនេរគ្រប់គ្រាន់ ហើយមានសេចក្តីបញ្ជាក់សមស្រប និងទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(មាត្រា២០នៃអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥) តែក៏មិនឱ្យលើសពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ដែរ"។

តាមរយៈការធ្វើសវនកម្មនៅអង្គភាពថវិកាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលបានយកវិក្កយបត្រប្រើប្រាស់ថាមពលអគ្គិសនី វិក្កយបត្រប្រើប្រាស់ទឹកស្អាត និងវិក្កយបត្រប្រើប្រាស់ទូរស័ព្ទក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ មកធ្វើការទូទាត់ក្នុងប្រតិបត្តិការចំណាយឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន ២១០ ៨៨៩ ៩៦៦រៀល។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរធ្វើការណែនាំដល់រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលឱ្យរួសរាន់ធ្វើការទូទាត់ចំណាយឱ្យបានទាន់ពេលវេលាស្របតាមបទប្បញ្ញត្តិនៃច្បាប់ និងសារាចរណែនាំខាងលើ។

ចំពោះចំណុចនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមឯកភាពតាមខ្លឹមសារនៃរបាយការណ៍សវនកម្មនេះ និងខិតខំព្យាយាមកែលម្អនូវចំណុចខ្វះខាតទាំងឡាយដែលបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។

### ៣.១.១៤.ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការ

សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងទៀងទាត់តាមវិធីសាស្រ្ត និងពេលវេលានៃដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មដូចមានចែងក្នុងផែនការលទ្ធកម្មដែលបានអនុម័ត"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មនៃក្រសួងអភិវឌ្ឍន៍ជនបទមានភាពយឺតយ៉ាវក្នុងការស្នើសុំគោលការណ៍ធានាចំណាយលើគម្រោងលទ្ធកម្មទំនិញ សេវា និងសំណង់មួយចំនួនទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាហេតុនាំឱ្យមានការ

យឺតយ៉ាវដល់ការអនុវត្តដំណាក់កាលជាបន្តបន្ទាប់រហូតដល់ការប្រគល់-ទទួល ទំនិញ សេវា និងសំណង់មិនស្របតាមពេលវេលាដែលបានកំណត់នៅក្នុងផែនការលទ្ធកម្មឡើយ។

ក្រសួងអភិវឌ្ឍន៍ជនបទ គួរធ្វើការណែនាំដល់អង្គភាពលទ្ធកម្មខាងលើអនុវត្តឱ្យបានត្រឹមត្រូវ និងស្របតាមពេលវេលាដែលបានកំណត់នៅក្នុងផែនការលទ្ធប្រចាំឆ្នាំដែលបានអនុម័ត។

ក្រសួងអភិវឌ្ឍន៍ជនបទសូមឯកភាពទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងរៀបចំកិច្ចប្រជុំជាមួយអង្គភាពក្រោមឱវាទទាំងអស់ឱ្យផ្តល់ទិន្នន័យឱ្យបានទាន់ពេលវេលាសម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់។

**៣.១.១៥.អង្គភាពអនុវត្តគម្រោងពុំមានឧបករណ៍បំពេញការងារគ្រប់គ្រាន់**

អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីលទ្ធកម្មសាធារណៈ បានកំណត់ថា "ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបានប្រើប្រាស់សម្រាប់ស្ថាប័នអនុវត្តលទ្ធកម្មណាដែលមានស្រាប់នូវបច្ចេកទេសជំនាញ កំលាំងពលកម្ម និងឧបករណ៍សម្រាប់បំពេញការងារក្នុងគម្រោងនោះ"។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០២២ នាយកដ្ឋានផ្លូវលំជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងនាមជាអ្នកទទួលការបានអនុវត្តគម្រោងស្ថាបនាសាងសង់ស្ពាន និងផ្លូវលំជនបទមួយចំនួនដោយពុំមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់ដំណើរការងារនោះឡើយ។ ក្រសួងអភិវឌ្ឍន៍ជនបទ គួរស្វែងរកការពិភាក្សាជាមួយភាគីពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាពការងារស្ថាបនាសាងសង់ស្ពាន និងផ្លូវលំជនបទឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ករណីនេះ ក្រសួងសូមធ្វើការបំភ្លឺថា កន្លងមកក្រសួងអភិវឌ្ឍន៍ជនបទបានចុះកិច្ចសន្យាជាមួយអង្គភាពរដ្ឋ ទាំងនាយកដ្ឋានផ្លូវលំជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ដើម្បីអនុវត្តការងារស្ថាបនា ថែទាំ និងជួសជុលផ្លូវជនបទឱ្យបានទាន់ពេលវេលា។ អង្គភាពទាំងនោះមានគ្រឿងចក្រដែលទទួលបានពីគម្រោងនានា និងបានជួលគ្រឿងចក្រពីខាងក្រៅខ្លះ ដើម្បីបំពេញបន្ថែមក្នុងការអនុវត្តការងារឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងគោលដៅបំពេញទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅជនបទ។ ក្រសួងសូមឯកភាពទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិក្នុងការពង្រឹងគុណភាព ភាពសន្សំសំចៃ និងប្រសិទ្ធភាពនៃការអនុវត្តការងារ។

**៣.១.១៦.ភាពយឺតយ៉ាវក្នុងការចេញលិខិតដកប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនក្រុមហ៊ុន**

ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ច

សន្យា បានកំណត់ថា "ក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរបន្ទាប់ពីអ្នកដេញថ្លៃឈ្នះបានចុះកិច្ចសន្យា និងកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ព្រមទាំងក្នុងរយៈពេល៥(ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរបន្ទាប់ពីការប្រគល់-ទទួលទំនិញ សំណង់ ឬសេវាគ្រប់ចំនួន ឬបន្ទាប់ពីផុតសុពលភាពធានាគុណភាពទំនិញ សំណង់ ឬសេវា ស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម ឬអង្គភាពថវិកាត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ និងលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី-ខេត្ត ឬធនាគារពាណិជ្ជដៃគូ ដើម្បីបង្វិលប្រាក់កក់ធានាការដេញថ្លៃជូនអ្នកដេញថ្លៃចាញ់វិញ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការវិញ"។ តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គណៈកម្មាធិការលទ្ធកម្មនៃក្រសួងអភិវឌ្ឍន៍ជនបទមានភាពយឺតយ៉ាវក្នុងការចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ២%ជូនក្រុមហ៊ុនដេញថ្លៃចាញ់ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា១០%ជូនក្រុមហ៊ុនដែលបានផ្គត់ផ្គង់ទំនិញ និងសេវារួចរាល់វិញនោះទេ។

ដើម្បីធានាឱ្យការអនុវត្តកិច្ចលទ្ធកម្មបានត្រឹមត្រូវ និងមានតម្លាភាព ក្រសួងអភិវឌ្ឍន៍ជនបទគួរធ្វើការណែនាំដល់គណៈកម្មាធិការលទ្ធកម្មខាងលើអនុវត្តឱ្យបានត្រឹមត្រូវ និងស្របតាមប្រកាសខាងលើ។

តាមរយៈការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអភិវឌ្ឍន៍ជនបទសូមឯកភាពទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ សម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់ ក្រសួងបានណែនាំដល់អង្គភាពលទ្ធកម្មត្រូវចេញលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជូនទៅក្រុមហ៊ុន/អ្នកផ្គត់ផ្គង់ឱ្យបានទាន់ពេលវេលាដែលបានកំណត់នៅក្នុងប្រកាសខាងលើ។

### ៣.១.១៧.ការចំណាយថវិការជ្ជទេយ្យបុរេប្រទានពុំទាន់បានត្រឹមត្រូវតាមនីតិវិធី

ប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ប្រការ៥ រជ្ជទេយ្យបុរេប្រទានគឺជាចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំបន្ទាន់ និងមានចំនួនតិចតួច ដែលពុំអាចរង់ចាំបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីទូទាត់ត្រង់បាន ជាអាទិ៍រួមមាន ចំណាយលើការទិញសម្ភារតិចតួច និងសេវាកម្មតូចតាចជាដើម។

តាមការចុះពិនិត្យថវិកាដំណើរការរបស់អង្គភាពនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងបរិស្ថានសម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានមួយចំនួនក្រោមចំណុះអង្គភាពថវិកានៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុបានធ្វើការស្នើសុំការចំណាយថវិការជ្ជទេយ្យបុរេប្រទាន ដោយបានយកថវិការជ្ជទេយ្យបុរេប្រទានទាំងនោះទៅរក្សាទុកនៅអង្គភាពរបស់ខ្លួនចន្លោះពីដប់ថ្ងៃទៅមួយខែ ទើបអង្គភាពទាំង

នោះធ្វើការចំណាយ។ ក្រសួងបរិស្ថាន គួរណែនាំដល់នាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុអនុវត្តឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបចំពោះករណីខាងលើនេះ ក្រសួងបរិស្ថានបានបញ្ជាក់ថា សម្រាប់ខ្ទង់ចំណាយរដ្ឋទេយ្យបុរេប្រទានមានការបោះពុម្ព ការរៀបចំពិធីបុណ្យជាតិ-អន្តរជាតិ និងការជួសជុលបរិក្ខារបច្ចេកវិទ្យាព័ត៌មាន ការថែទាំនិងការជួសជុលមធ្យោបាយដឹកជញ្ជូន ការថែទាំបណ្តាញផ្សេងៗក្នុងខ្ទង់ទាំងអស់នេះ គឺជាការចំណាយដែលត្រូវការបុរេប្រទានថវិកាមុនការអនុវត្តសម្រាប់យកទៅកក់ប្រាក់មុន លុះដល់ថ្ងៃអនុវត្តទើបធ្វើការទូទាត់ចេញវិក្កយបត្រដែលជាកត្តាតម្រូវឱ្យការិយាល័យរដ្ឋទេយ្យបុរេប្រទានបើកថវិកាទៅមុន ហើយរៀបចំរបាយការណ៍ទូទាត់មកវិញយឺតដោយត្រូវរង់ចាំថ្ងៃអនុវត្ត។

**៣.១.១៨.ការផ្សព្វផ្សាយតាមរយៈសារព័ត៌មានលើការងារបោះពុម្ពពុំទាន់បានពេញលេញ**

សារាចរណែនាំលេខ០០២ សហវ អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី៧ បានតម្រូវឱ្យការផ្សព្វផ្សាយតាមរយៈសារព័ត៌មានត្រូវធ្វើឡើងឱ្យបានយ៉ាងតិចចំនួនពីរលើក និងត្រូវមានទំហំមិនតូចជាង ១១ ស.ម x ១៥ ស.ម។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុវត្តការងារលទ្ធកម្មបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំស្តីពីវិស័យអគ្គិសនី ដែលមានទឹកប្រាក់ ២១ ៩៩៩ ០០០រៀល ដោយបានធ្វើការផ្សព្វផ្សាយកាសែតបានតែមួយលើកប៉ុណ្ណោះ។ អាជ្ញាធរអគ្គិសនីកម្ពុជា គួរផ្សព្វផ្សាយតាមរយៈសារព័ត៌មានឱ្យបានត្រឹមត្រូវតាមសារាចរណែនាំខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ អាជ្ញាធរអគ្គិសនីកម្ពុជាសូមទទួលយក និងកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

**៣.១.១៩.កង្វះខាតក្នុងការភ្ជាប់ប៉ាន់គំរូ ឬកាតាឡុក**

ប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្រាប់លទ្ធកម្មទំនិញ និងសំណង់ ផ្នែកសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ ពិគ្រោះថ្លៃ ត្រង់ចំណុចទី៤ បានចែងថា "សមាសធាតុនៃឯកសារដេញថ្លៃ ពិគ្រោះថ្លៃ រួមមាន៖

- សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
- សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ
- លក្ខខណ្ឌនៃកិច្ចសន្យា
- ពាក្យសុំដេញថ្លៃ
- តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស
- ប៉ាន់គំរូ កាតាឡុក

- ទម្រង់លិខិតធានាប្រាក់កក់ការដេញថ្លៃ
- ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តនិងមន្ទីរមួយចំនួននៃខេត្តត្បូងឃ្មុំ និងមន្ទីរមួយចំនួននៃខេត្តមណ្ឌលគិរីបានចុះកិច្ចសន្យាស្តីពីការផ្គត់ផ្គង់ឯកសណ្ឋាន សង្ហារិម សម្ភារព័ត៌មានវិទ្យា សម្ភារមិនមែនព័ត៌មានវិទ្យា និងសំបកកង់រថយន្ត ដោយពុំបានភ្ជាប់ប៉ាន់គំរូ ឬកាតាឡុកឡើយ។ ហេតុដូចនេះ រដ្ឋបាលខេត្ត និងមន្ទីរនានានៃខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី គួរខិតខំអនុវត្តតាមប្រកាសខាងលើឱ្យបានត្រឹមត្រូវ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ រដ្ឋបាលខេត្ត និងមន្ទីរនានានៃខេត្តត្បូងឃ្មុំ និងមន្ទីរមួយចំនួននៃខេត្តមណ្ឌលគិរីសូមទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ នឹងធ្វើការភ្ជាប់នូវកាតាឡុកឱ្យបានត្រឹមត្រូវនៅឆ្នាំក្រោយ។

### ៣.១.២០.ការវាយតម្លៃ និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដេញថ្លៃឈ្នះដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

ប្រកាសលេខ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្រាប់លទ្ធកម្មសំណង់។ កម្រងគំរូឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈស្តីពីការងារសាងសង់ ជួសជុល បានកំណត់ពីលក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃមានដូចជា៖

- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន(ចម្លងត្រឹមត្រូវតាមច្បាប់ដើម)ចំនួន០៣ច្បាប់
- ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ(ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម(ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- វិញ្ញាបនបត្រប្រកបអាជីវកម្មចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- វិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស និងបទពិសោធន៍(ចម្លងត្រឹមត្រូវតាមច្បាប់ដើម)

តាមការពិនិត្យសំណុំឯកសារកិច្ចលទ្ធកម្មក្នុងឆ្នាំ២០២២របស់ក្រុមលទ្ធកម្មនៃសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគខេត្តស្ទឹងត្រែង និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគខេត្តកំពង់ចាម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមលទ្ធកម្មរបស់អង្គភាពទាំងពីរខាងលើបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ដើម្បីធ្វើការជួសជុលអគារដែលមានទឹកប្រាក់សរុបចំនួន១ ៦៩៩ ៩៩៤ ០០០រៀល ក្នុងនោះកិច្ចសន្យាលេខ៦០ស.ម.ស.ភ/សត.កល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ស្តីពីការជួសជុលអគារជូនសាលាមធ្យមសិក្សាសុខាភិបាល

ភូមិភាគខេត្តស្ទឹងត្រែង ដែលមានទឹកប្រាក់ចំនួន ៧៩៥ ៩៩៤ ០០០រៀល និងកិច្ចសន្យាលេខ៤០ ស.ម.ស.ភ.កច/អ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ស្តីពីការជួសជុលអគារជូនសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគខេត្តកំពង់ចាម ដែលមានទឹកប្រាក់ចំនួន៩០៤ ០០០ ០០០រៀល ដោយក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃទាំងនោះមិនមានភ្ជាប់មកជាមួយនូវឯកសារអំណះអំណាងស្តីពីសមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស និងបទពិសោធន៍របស់ខ្លួននោះឡើយ។

កត្តានេះ នាំឱ្យការវាយតម្លៃ និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដេញថ្លៃឈ្នះដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

អាស្រ័យហេតុនេះ ក្រសួងសុខាភិបាល គួរណែនាំសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាមឱ្យអនុវត្តខ្ជាប់ខ្ជួនតាមខ្លឹមសារនៃប្រកាសខាងលើ។

ក្រសួងសុខាភិបាលបានទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងជំរុញឱ្យសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែងយកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គម្រូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ។

**៣.១.២១.ការពុំមានវិធានការលើក្រុមហ៊ុនដែលបំពានកិច្ចសន្យា**

សារាចរណែនាំលេខ០០២ សហវ.អលរសចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី១៩ បានចែងថា ការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារត្រូវប្រព្រឹត្តទៅតាមទីកន្លែង ពេលវេលា បរិមាណទំហំ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានចែងក្នុងកិច្ចសន្យា។ ការប្រគល់ទទួល ឬវាយតម្លៃលទ្ធផលការងារខ្យល់ (គ្មានទំនិញសំណង់ឬសេវា) ឬបរិមាណទំនិញ ទំហំការងារ ឬសេវាមិនគ្រប់ចំនួន ឬមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស គឺជាអំពើឃុបឃិតដែលត្រូវជៀសវាងឱ្យបានដាច់ខាត។

តាមការពិនិត្យលើកិច្ចសន្យា និងកំណត់ហេតុប្រគល់ទទួលនៅអង្គភាពលទ្ធកម្មរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងបរិស្ថានសម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មខាងលើបានធ្វើការយល់ព្រមប្រគល់ទទួលទំនិញ និងសេវា៣គម្រោងបានធ្វើការប្រគល់ទទួលទំនិញ និងសេវា យឺតជាងរយៈពេលដែលបានកំណត់ក្នុងកិច្ចសន្យា។ ក្រសួងបរិស្ថានគួរណែនាំដល់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរណែនាំ។

ឆ្លើយតបលើករណីនេះ ក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុសូមឯកភាពនិងទទួលយក ប៉ុន្តែសូមធ្វើការបញ្ជាក់ពីមូលហេតុដែលពុំមានវិធានការលើក្រុមហ៊ុន ដោយសារក្រុមហ៊ុនដែលទទួលបានកិច្ចសន្យាអនុវត្តការងារលទ្ធកម្មនេះ មានចំនួន៣គម្រោងរួមមាន ១)បោះពុម្ព ២)គម្រោងសេវាថែទាំសួនច្បារ និង ៣)គម្រោងសេវាថែទាំបណ្តាញ

អគ្គីសនី ក្រុមហ៊ុនបានបំពេញកិច្ចសន្យារហូតដល់២១ថ្ងៃ គិតមកដល់ថ្ងៃប្រគល់-ទទួល ប៉ុន្តែក្រុមហ៊ុនបានជូនដំណឹងមកក្រុមការងារលទ្ធកម្មរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុផងដែរ។ បន្ទាប់ពីទទួលបានព័ត៌មាន ក្រុមលទ្ធកម្មខាងលើក៏បានបើកកិច្ចប្រជុំពិភាក្សាលើករណីនេះ ដោយក្រុមហ៊ុនបានបញ្ជាក់អំពីមូលហេតុសមរម្យ និងអង្គប្រជុំបានឯកភាពលើការស្នើសុំពន្យារពេលរបស់ក្រុមហ៊ុនដែលបានស្នើ។

**៣.១.២២.ការបំបែកប័ណ្ណចំណាយដោយពុំធ្វើនីតិវិធីលទ្ធកម្ម**

ប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ បានបញ្ជាក់ថា រជ្ជទេយ្យករបុរេប្រទាន ឬរជ្ជទេយ្យករបុរេប្រទានរងត្រូវជៀសវាងដាច់ខាតនូវការបំបែកគោលការណ៍ចំណាយ ឬប័ណ្ណចំណាយទៅតាមទីកន្លែងគោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយ ក្នុងគោលបំណងគេចវេះការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងប្រកាសលេខ១៦៨៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់នីតិវិធីលទ្ធកម្ម បានបញ្ជាក់ថា ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្មនៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់លទ្ធកម្មទំនិញទឹកប្រាក់ក្រោម២០លានរៀលត្រូវអនុវត្តវិធីសាស្ត្រស្ទង់តម្លៃ ទឹកប្រាក់ចាប់ពី២០លានរៀល ដល់ក្រោម១០០លានរៀលត្រូវអនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃ ទឹកប្រាក់ចាប់ពី១០០លានរៀល ដល់ក្រោម ៥ ០០០លានរៀលត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក និងទឹកប្រាក់ចាប់ពី ៥ ០០០ លានរៀលឡើង ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។

តាមការពិនិត្យអាណត្តិបើកប្រាក់ និងសក្ខីបត្រទូទាត់ការចំណាយថវិការជ្ជទេយ្យបុរេប្រទានរបស់រដ្ឋបាលកណ្តាលក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសាធារណការ និងដឹកជញ្ជូនបានបំបែកប័ណ្ណចំណាយរជ្ជទេយ្យបុរេប្រទានដើម្បីគេចវេះនីតិវិធីលទ្ធកម្មដូចជាៈ ១.ការបោះពុម្ពដែលមានទឹកប្រាក់ចំនួន ៣២ ៦១៤ ០០០រៀល សម្រាប់ការចំណាយពីថ្ងៃទី២ ដល់ថ្ងៃទី១៨ខែមីនា ២.សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាដែលមានទឹកប្រាក់ចំនួន ២៧ ៣៣០ ០០០រៀល សម្រាប់ការចំណាយពីថ្ងៃទី៤ ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២។ ក្រសួងគួរធ្វើការណែនាំដល់អង្គភាពចំណាយថវិការជ្ជទេយ្យបុរេប្រទានឱ្យអនុវត្តស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានឯកភាព និងបំភ្លឺថា ក្រៅពីមុខចំណាយក្នុងផែនការលទ្ធកម្ម មានការបែងចែក ៣០% នៃឥណទានចរន្តប្រចាំឆ្នាំចូលក្នុងរជ្ជទេយ្យបុរេប្រទានសម្រាប់ចំណាយដែលមានលក្ខណៈចាំបាច់ តិចតួច និងបន្ទាន់។ ក្រសួងនឹងព្យាយាមប្រមូលផ្តុំមុខសញ្ញាចំណាយដែលមានប្រភេទដូចគ្នាបញ្ចូលក្នុងផែនការលទ្ធកម្មឱ្យស្របតាមខ្លឹមសារនៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៣.១.២៣.កង្វះខាតក្នុងការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម

ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ១៩ បានកំណត់ថា "អង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្មត្រូវប្រមូលផ្តុំបញ្ចូលក្នុងក្រុមលទ្ធកម្មតែមួយហៅថា (ឡូត៍លទ្ធកម្ម) នូវតម្រូវការទំនិញ សំណង់ និងសេវាកម្មដែលស្ថិតនៅក្នុងប្រភេទដូចគ្នាហើយមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឱ្យការងារតែមួយដូចជាគ្រឿងសង្ហារឹម សម្ភារការិយាល័យ ឬប្រេងឥន្ធនៈសម្រាប់ទំនិញ ឬការងារសាងសង់តូចតាចមួយចំនួន ដែលស្ថិតនៅជិតគ្នាៗជាដើមសម្រាប់សំណង់" និងប្រការ២០នៃប្រកាសខាងលើបានកំណត់ថា "ឡូត៍លទ្ធកម្មដែលមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នាត្រូវបញ្ចូលជាក្រុមធំមួយហៅថា (កញ្ចប់លទ្ធកម្ម) សម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក ដើម្បីបង្កើនកម្រិតគុណភាពប្រកួតប្រជែង និងចំណេញពេលវេលាព្រមទាំងអាចកាត់បន្ថយសោហ៊ុយចំណាយ"។

តាមការពិនិត្យគម្រោងលទ្ធកម្មផ្គត់ផ្គង់ទំនិញក្នុងផែនការលទ្ធកម្ម ផែនការលទ្ធកម្មកែតម្រូវ របាយការណ៍អនុវត្តលទ្ធកម្ម កិច្ចសន្យាលទ្ធកម្មផ្គត់ផ្គង់ទំនិញ និងសេវាមួយចំនួនរបស់អង្គភាពលទ្ធកម្មនៃក្រសួងព័ត៌មានក្នុងឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មរបស់ក្រសួងព័ត៌មាននៅមិនទាន់បានធ្វើការប្រមូលផ្តុំគម្រោងលទ្ធកម្មដែលមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ដើម្បីធ្វើការបញ្ចូលជាកញ្ចប់លទ្ធកម្មតែមួយសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក ដើម្បីបង្កើនកម្រិតគុណភាពប្រកួតប្រជែង និងចំណេញពេលវេលា ព្រមទាំងអាចកាត់បន្ថយសោហ៊ុយចំណាយផ្សេងៗ។ ជាក់ស្តែង ក្រសួងបានអនុវត្តកិច្ចលទ្ធកម្មលើគម្រោងដែលមានលក្ខណៈដូចគ្នា និងស្រដៀងគ្នា សម្រាប់ការផ្គត់ផ្គង់បរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាចំនួន២គម្រោង រួមមានការផ្គត់ផ្គង់គ្រឿងសង្ហារឹមចំនួន២គម្រោង និងការជួសជុលមធ្យោបាយដឹកជញ្ជូន/រថយន្តចំនួន២គម្រោង។ ក្រសួងព័ត៌មាន គួរធ្វើការណែនាំដល់អង្គភាពលទ្ធកម្មឱ្យធ្វើការប្រមូលផ្តុំគម្រោងលទ្ធកម្មដែលមានតម្រូវការតែមួយ ឬមានលក្ខណៈបច្ចេកទេសដូចគ្នា ស្រដៀងគ្នា ដើម្បីធ្វើកិច្ចលទ្ធកម្មដេញថ្លៃតែមួយលើក។

ចំពោះចំណុចនេះ អង្គភាពលទ្ធកម្មនៃក្រសួងព័ត៌មានបានឆ្លើយបំភ្លឺថា ការមិនបានធ្វើការប្រមូលផ្តុំលើគម្រោងលទ្ធកម្មដែលមានលក្ខណៈដូចគ្នា គឺដោយសារអង្គភាពលទ្ធកម្មអនុវត្តរួចតាមគម្រោងផែនការដើមឆ្នាំបន្ទាប់មកក្រសួងក៏ទទួលបានឥណទានបន្ថែម ដោយធ្វើផែនការកែតម្រូវតាមឥណទានបន្ថែមនោះលើមុខទំនិញដូចគ្នា។

### ៣.១.២៤.ការចំណាយ និងការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ

ប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៧របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ឧបសម្ព័ន្ធទី២ បានកំណត់ដូចខាងក្រោម៖

- អនុគណនី២១០៣១ ចំណាយ និងកត់ត្រាចំណាយលើការទិញ ឬសាងសង់អគារសាធារណៈ
- អនុគណនី២១០៣២ ចំណាយនិងកត់ត្រាចំណាយលើការរៀបចំកែលម្អអគារសាធារណៈក្នុងទ្រង់ទ្រាយធំ ហើយការងារនេះបានធ្វើឱ្យកើនឡើងនូវតម្លៃអគារនោះដូចជា៖ ការជួសជុលដំបូល ការជួសជុលរួមនៃប្រព័ន្ធអគ្គិសនី...។ល។
- អនុគណនី ៦០០១១ ចំណាយលើការទិញសម្ភារសម្រាប់សម្អាត និងអនាម័យដូចជា៖ អូសាវែល សាប៊ូ ទឹកលាងកញ្ចក់ ក្រដាសអនាម័យ ទឹកក្រអូបបាញ់បន្ទប់ ច្រាស កន្សែងដៃ ថ្នាំបាញ់មូស...។ល។
- អនុគណនី ៦០០១៤ ចំណាយលើការទិញសម្ភារផ្គត់ផ្គង់សម្រាប់ថែទាំ និងជួសជុលសម្ភារ និងឧបករណ៍
- អនុគណនី ៦០០២១ ចំណាយលើការទិញសម្ភារការិយាល័យ និងសម្ភារប្រឡង ដូចជា ក្រដាសរ៉ាម ខ្មៅដៃ ប៊ិច ហ្វឺត សីមី ទឹកថ្នាំម៉ាស៊ីនបោះពុម្ពឯកសារ ទឹកថ្នាំម៉ាស៊ីនថតចម្លង សៀវភៅមូលប្បទានបត្រ
- អនុគណនី៦០០២២ ចំណាយលើការទិញសៀវភៅមើលនិងឯកសារផ្សេងៗដែលបម្រើឱ្យការងាររដ្ឋបាល
- អនុគណនី ៦០០២៣ ចំណាយលើការបោះពុម្ពដូចជា៖ បោះពុម្ពសៀវភៅឯកសារ បង្កាន់ដៃបង់ប្រាក់ តែមប្រ៊ី ទិដ្ឋាការ លតាបត្រ។ល។
- អនុគណនី៦០០៤២ ចំណាយលើការទិញសំលៀកបំពាក់ការពារសុវត្ថិភាពជូនមន្ត្រីមានសមត្ថកិច្ច និងមន្ត្រីរាជការក្នុងពេលបំពេញការងារ
- អនុគណនី៦០០៥១ បានកំណត់ពីចំណាយសម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា
- អនុគណនី ៦០០៥៣ ចំណាយលើការទិញសម្ភារប្រើប្រាស់ដូចជា៖ សម្ភារកីឡាគ្រប់ប្រភេទ ថ្មពិលគ្រប់ប្រភេទ ហ្វីលថត(អង្គចងចាំ) កាសែតថតសម្លេង កាសែតវីដេអូ ញញួរ សោរចាក់ ម៉ាស៊ីនចោះឬខួង ម៉ាស៊ីនខាត់ ចប តង់កៅស៊ូ រណា រាំងននៈ។ល។
- អនុគណនី ៦០០៥៤ ចំណាយលើការទិញសម្ភារនិងឧបករណ៍ដឹកជញ្ជូនដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយមូលធនដូចជា៖រទេះដឹក រថយន្តម៉ូតូ កង់ ។ល។
- អនុគណនី៦០០៥៥ ត្រូវបានកំណត់ចំពោះចំណាយលើការទិញសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា

- អនុគណនី៦១០៥២ ចំណាយលើការជួសជុលអគារ របងអគារ ចំណតរថយន្ត បន្ទប់ទឹក ឃ្លាំង ប្រាសាទ អាកាសយានដ្ឋាន កំពង់ផែ ទីផ្សារ សត្វឃាតដ្ឋាន (សួនច្បារក្នុងទីធ្លា) ដែលមានសេវាផ្គត់ផ្គង់ពីខាងក្រៅ ព្រមទាំងចំណាយការលាបថ្នាំ ការរៀបចំបណ្តាញឡើងវិញដែលបណ្តាលមកពីការជួសជុលអគារ លើកលែងតែការចំណាយទិញឧបករណ៍ថ្មីបំពាក់បន្ថែមដែលត្រូវកត់ត្រាក្នុងជំពូក (៦០)។ល។
- អនុគណនី ៦១០៥៤ ចំណាយលើការជួសជុលថែទាំគ្រប់ប្រព័ន្ធបណ្តាញទាំងអស់ដែលមិនមែនជាផ្លូវចរាចរ ហើយមិនពាក់ព័ន្ធនឹងការជួសជុលអគារ ដូចជា៖ បណ្តាញលូ ទឹកស្អាត វារីអគ្គិសនី តបណ្តាញអគ្គិសនី បណ្តាញទូរសព្ទ ប្រព័ន្ធបណ្តាញព័ត៌មានវិទ្យា។ល។
- អនុគណនី ៦១០៥៦ ចំណាយដែលពាក់ព័ន្ធនឹងការងារថែទាំជួសជុលយានយន្ត និងជលយានដែលជាទ្រព្យសម្បត្តិរបស់អង្គភាព។
- អនុគណនី៦១០៥៧ ចំណាយលើការថែទាំជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេសដូចជា៖ សម្ភារសាធារណការ (គ្រឿងចក្រ) ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនថតចម្លង ទូរសព្ទ វិទ្យុទាក់ទង ម៉ាស៊ីនហ្វាក់ កុំព្យូទ័រ ម៉ាស៊ីនផ្សាយទូរទស្សន៍។ល។
- អនុគណនី៦១១០៣ ចំណាយលើការប្រជុំ សិក្ខាសាលា សម្ពោធសមិទ្ធផល សន្និសីទ សន្និបាទ ដូចជា៖ ការរៀបចំឯកសារនិងសម្ភារតូចតាច ការជួលទីតាំងនិងការរៀបចំទីកន្លែងអាហារ ការឧបត្ថម្ភគ្រូឧទ្ទេស និងអ្នកសម្របសម្រួល សន្តិសុខ និងចំណាយផ្សេងៗ
- អនុគណនី ៦១១៣៣ ចំណាយលើការស្នាក់នៅ និងហូបចុករបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដែលត្រូវចុះបេសកកម្មក្រៅប្រទេស

តាមការធ្វើសវនកម្មក្នុងឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងមួយចំនួន រួមមាន៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ បានអនុវត្ត និងកត់ត្រាការចំណាយមួយចំនួនដោយពុំទាន់បានត្រឹមត្រូវស្របទៅតាមខ្លឹមសារនៃប្រកាសខាងលើនៅឡើយ ដូចជា៖

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអនុវត្តនីតិវិធីចំណាយបុរេប្រទានសម្រាប់ការទទួលគណៈប្រតិភូវៀតណាមចំនួន៣៥រូប មកបំពេញទស្សកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នូវទឹកប្រាក់ចំនួន ១០០ ០០០ ០០០រៀល តាមរយៈអាណត្តិលេខ ០២០៣ ដែលក្នុងការកត់ត្រាចំណាយទាំងនោះ មានចំណាយស្នាក់នៅសរុបចំនួន ៤១ ៦៤៥ ៤៥០រៀល បានកត់ត្រាមិនត្រឹមត្រូវនៅក្នុងអនុគណនីលេខ៦១១០៣ ប៉ុន្តែក្រសួងគួរកត់ត្រាចំណាយទឹកប្រាក់ខាង

លើនៅក្នុងអនុគណនីលេខ៦១១៣៣ ឱ្យស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចមាតិកាថវិការបស់រដ្ឋដែលបានកំណត់។

- ក្រសួងក្រសួងអប់រំ យុវជន និងកីឡា ក៏បានអនុវត្ត និងកត់ត្រាចំណាយមិនត្រឹមត្រូវផងដែរចំពោះការទូទាត់ចំណាយលើការជួសជុលអគារសិក្សា០២ខ្នងនៅវិទ្យាស្ថានជាតិអប់រំជំហានទី២ ការជួសជុលកែលម្អអគាររដ្ឋបាលរបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០២២របស់អង្គភាពលទ្ធកម្ម និងចំណាយថវិកាបុរេប្រទានលើការទិញសម្ភារ បរិក្ខារបច្ចេកទេសព័ត៌មានវិទ្យារបស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០២២ សរុបចំនួន ៥ ៩៧៣ ០៣១ ០០០រៀល ដែលក្នុងនោះមានចំណាយចំនួន ៦៣៣ ០៣១ ០០០រៀល ដែលបានកត់ត្រាមិនទាន់បានត្រឹមត្រូវទៅលើចំណាយក្នុងការទិញជណ្តើរយន្តចំនួន០២គ្រឿង ដើម្បីបំពាក់នៅអគាររដ្ឋបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងទឹកប្រាក់ចំនួន៤៦៤ ០០០ ០០០រៀល ដែលត្រូវកត់ត្រាក្នុងអនុគណនីលេខ៦០០៥១ ប៉ុន្តែក្រសួងបានកត់ត្រាចំណាយនេះមិនត្រឹមត្រូវក្នុងអនុគណនីលេខ ៦១០៥២ និងការទិញសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាមួយចំនួនដូចជា៖ ម៉ាស៊ីនPhotocopier (១គ្រឿង), Projector (2គ្រឿង), Samsung TV (១គ្រឿង), កុំព្យូទ័រម៉ាកDell PowerEdgeR340(២គ្រឿង), កុំព្យូទ័រម៉ាកMicrosoft Surface Pro8 (១គ្រឿង), Camera Canon (១គ្រឿង), កុំព្យូទ័រ(២គ្រឿង) ក្នុងទឹកប្រាក់សរុបចំនួន ១៦៩ ០៣១ ០០០រៀល ត្រូវកត់ត្រាក្នុងអនុគណនីលេខ៦០០៥៥ ប៉ុន្តែក្រសួងបានកត់ត្រាចំណាយខាងលើនេះមិនត្រឹមត្រូវក្នុងអនុគណនីលេខ៦០០៥១។

- អង្គភាពថវិកាក្រោមឱវាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមួយចំនួនដូចជា៖ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប រដ្ឋបាលព្រៃឈើ និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានអនុវត្តការចំណាយ និងកត់ត្រាចំណាយថវិកាមួយចំនួនមិនទាន់ត្រឹមត្រូវ ដែលមានទឹកប្រាក់សរុបចំនួន៦១៨ ៧៤៣ ៣០០រៀល ដែល រួមមាន ចំណាយទៅលើការសាងសង់របង និងសាងសង់ផ្ទះសំណាញ់នៅស្ថានីយ៍កោះកេរ្តិ៍ ចំនួន ៥៥៤ ១០០ ០០០រៀល ដែលត្រូវកត់ត្រាក្នុងអនុគណនី២១០៣៨ ចំណាយបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំ២០២០-២០២១ ចំនួន៣៦ ០០០ ០០០រៀល ដែលត្រូវកត់ត្រាក្នុងអនុគណនីលេខ ៦០០២៣ ចំណាយលើការជួសជុលពិដាន និងបន្ទប់ទឹក ប្តូរសំបកកង់ឡាន ប្តូរdrum និងទឹកថ្នាំ និងទិញម៉ាស និងអាល់កុល ចំនួន៩ ២១៥ ៨០០រៀល និងចំណាយលើការទិញទឹកថ្នាំអាល់ប៉ិច ទឹកថ្នាំព្រីន ចំនួន១៩ ៤២៧ ៥០០រៀល ត្រូវកត់ត្រាក្នុងអនុគណនីលេខ ៦០០១១។

- ក្រសួងអភិវឌ្ឍន៍ជនបទក៏បានអនុវត្តចំណាយ និងកត់ត្រាចំណាយលើការទិញឧបករណ៍ផ្ទុកទិន្នន័យ(External Hard disc 2T) មួយចំនួន ដោយបានកត់ត្រាចំណាយថវិកាមិនត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៅឡើយផងដែរ។

ក្រសួងខាងលើគួរធ្វើការណែនាំដល់មន្ត្រីហិរញ្ញវត្ថុនៃអង្គភាពថវិការបស់ខ្លួនឱ្យអនុវត្តការចំណាយ និងការកត់ត្រាឱ្យមានប្រសិទ្ធភាពស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងខាងលើបានឯកភាពទទួលយកចំពោះការរកឃើញខាងលើ និងខិតខំកែលម្អចំណុចខ្វះខាតទាំងនោះតាមអនុសាសន៍សវនកម្មនៅឆ្នាំបន្ទាប់ទៀត។

**៣.១.២៥.ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត**

សារាចរណែនាំលេខ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ ត្រង់ទំព័រទី២ ចំណុចទី៥ ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តត្រូវធ្វើការទូទាត់ប្រចាំខែ(ម្តងក្នុងមួយខែ) លើកលែងតែក្នុងខែនោះមិនមានការប្រមូលចំណូល។

តាមការចុះធ្វើសវនកម្មនៅច្រកចេញចូលតែមួយរបស់ក្រសួងបរិស្ថាន សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងបរិស្ថានបានប្រមូលចំណូលពីកម្រងសេវាសាធារណៈជារៀងរាល់ខែ ប៉ុន្តែក្រសួងពុំទាន់បានទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តតាមខែដែលប្រមូលបាននោះទេ ដោយការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តក្នុងឆ្នាំ២០២២ បានធ្វើការទូទាត់ដោយការបូកសរុបជារៀងរាល់ពីរខែ ទៅបីខែម្តង។ ក្រសួងបរិស្ថាន គួរអនុវត្តឱ្យស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ក្រសួងបានទទួលយកនូវអនុសាសន៍ខាងលើនឹងធ្វើការកែលម្អ ព្រមទាំងខិតខំពង្រឹងការអនុវត្តឱ្យស្របតាមច្បាប់ និងបទបញ្ញត្តិដែលបានចែង។

**៣.១.២៦.ការទូទាត់ប្រាក់រង្វាន់ឆ្លងឆ្នាំ**

សារាចរណែនាំលេខ០១០ សហវ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ ជាតិឆ្នាំ២០២២ ត្រង់ចំណុចទី I យ បានចែងថា "ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរួសរាន់ធ្វើសលាកបត្របង្វែរចំណូលចូលថវិកាថ្នាក់ជាតិ និងបោះផ្សាយអាណត្តិនិយ័តកម្មសម្រាប់ការអនុវត្តនីតិវិធីទូទាត់ថវិការង្វាន់ដែលបានដកយកមុនពីចំណូលប្រមូលបាននៅក្នុងឆ្នាំ២០២២ និង២០២១ ដែលនៅសេសសល់ពុំទាន់បានទូទាត់ រួចបញ្ជូនទៅឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុយ៉ាងយូរត្រឹមវេលាម៉ោង១៧ និង៣០នាទី នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ និងត្រូវបញ្ជូនមករតនាគារថ្នាក់កណ្តាល ឬរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣"។

តាមការពិនិត្យអាណត្តិទូទាត់ប្រាក់រង្វាន់ និងរបាយការណ៍បែងចែកប្រាក់រង្វាន់ក្នុងឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបោះផ្សាយអាណត្តិទូទាត់ប្រាក់រង្វាន់ដែលដកពីការប្រមូលចំណូលសេវាសាធារណៈសម្រាប់ឆ្នាំ២០២២ មកទូទាត់នៅថ្ងៃទី២៧ ខែកុម្ភៈឆ្នាំ២០២៣ ដែលមានចំនួនទឹកប្រាក់សរុប

៤ ៧៥០ ៣១៨ ៧០៤រៀល ហើយទឹកប្រាក់នេះនឹងត្រូវកត់ត្រាចូលក្នុងរបាយការណ៍សម្រេចទូទាត់ថវិកាឆ្នាំ២០២៣។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួររួសរាន់រៀបចំបោះផ្សាយអាណត្តិទូទាត់ប្រាក់រង្វាន់ឱ្យបានទាន់ពេលវេលា ស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឆ្លើយបំភ្លឺថា ក្រសួងបានស្នើសុំបន្ថែមឥណទានចំនួន២លើករួចមកហើយ ក្នុងឆ្នាំ២០២២ ដើម្បីទូទាត់ប្រាក់រង្វាន់ ដោយលើកទី១នៅត្រីមាសទី៣ ប៉ុន្តែក្រោយពីក្រសួងបានសហការជាមួយក្រសួងមហាផ្ទៃ បង្កើតគណៈកម្មការអន្តរក្រសួង ពិនិត្យ តាមដាន និងជំរុញការងារអធិការកិច្ចហត្ថពលកម្មបរទេសតាមរយៈប្រកាសអន្តរក្រសួង លិខិតលេខ៥១៧៥ប្រក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ មក បានជំរុញឱ្យមានកំណើននៃសេវាការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេសបន្ថែម។ ក្រសួងបានស្នើសុំឥណទានម្តងទៀតនៅពាក់កណ្តាលត្រីមាសទី៤ ប៉ុន្តែទំហំឥណទានដែលទទួលបាននៅតែមិនអាចទូទាត់គ្រប់។ ក្រសួងទទួលយកនូវអនុសាសន៍ខាងលើ និងខិតខំពង្រឹងការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

**៣.១.២៧.ភាពយឺតយ៉ាវក្នុងការរៀបចំគោលនយោបាយគណនេយ្យ**

ប្រកាសលេខ៥៤៥ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ត្រង់ចំណុច១.៣.២៨ បានបញ្ជាក់ថា គុណភាពព័ត៌មានដែលបានផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ បានកំណត់ពីសារៈប្រយោជន៍នៃរបាយការណ៍ទាំងនោះចំពោះអ្នកប្រើប្រាស់។ កថាខណ្ឌ១.៣.២៧ កំណត់ពីបុគ្គលិកលក្ខណៈបែប គុណភាព និងការដាក់កម្រិតលើព័ត៌មានដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ វាតម្រូវឱ្យមានការអភិវឌ្ឍគោលនយោបាយគណនេយ្យ ដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវព័ត៌មានដែលអាចបំពេញតាមបុគ្គលិកលក្ខណៈបែបគុណភាពដូចមានកំណត់ក្នុងកថាខណ្ឌ ១.៣.២៧ (ក) ទៅ ១.៣.២៧ (ច) និងអាចបំពេញតាមការដាក់កម្រិតលើព័ត៌មានដែលបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០២២ កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំសេចក្តីព្រាងគោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់ធ្វើជាមូលដ្ឋានក្នុងការអនុវត្តកិច្ចប្រតិបត្តិការគណនេយ្យហិរញ្ញវត្ថុ ប៉ុន្តែសេចក្តីព្រាងគោលនយោបាយគណនេយ្យនេះពុំទាន់បានទទួលការអនុម័តយល់ព្រមជាផ្លូវការពីក្រុមប្រឹក្សាភិបាលនៅឡើយ។

អាស្រ័យហេតុនេះ ដើម្បីងាយស្រួលក្នុងការអនុវត្តកិច្ចបញ្ជិកាគណនេយ្យ កំពង់ផែស្វយ័តភ្នំពេញ គួររួសរាន់រៀបចំគោលនយោបាយគណនេយ្យ និងស្នើសុំការអនុម័តជាផ្លូវការពីក្រុមប្រឹក្សាភិបាល។

ឆ្លើយតបនឹងការលើកឡើង កំពង់ផែស្វយ័តភ្នំពេញ សូមទទួលយកនូវការពិនិត្យឃើញរបស់អាជ្ញាធរសវនកម្មជាតិ។

### ៣.១.២៨.កង្វះខាតក្នុងការអនុវត្តគម្រោងតាមផែនការលទ្ធកម្ម

ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ជំពូកទី៩ ប្រការ៣២ បានបញ្ជាក់ថា "គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមផែនការលទ្ធកម្ម ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០២២ កំពង់ផែស្វយ័តភ្នំពេញបានលើកគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២២ សរុបចំនួន៣១គម្រោង ក្នុងនោះមានចំនួន១៥គម្រោង ដែលកំពង់ផែស្វយ័តភ្នំពេញមិនបានអនុវត្ត។

អាស្រ័យហេតុនេះ ដើម្បីងាយស្រួលក្នុងការអនុវត្តកិច្ចលទ្ធកម្ម កំពង់ផែស្វយ័តភ្នំពេញគួរអនុវត្តឱ្យស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ។

ឆ្លើយតបនឹងការលើកឡើង កំពង់ផែស្វយ័តភ្នំពេញ សូមទទួលយកនូវការពិនិត្យឃើញរបស់អាជ្ញាធរសវនកម្មជាតិ។

ផ្អែកតាមការបំភ្លឺនេះ កំពង់ផែស្វយ័តភ្នំពេញ បានឯកភាពតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

### ៣.១.២៩.ការមិនបានបែងចែកភារកិច្ចរវាងអធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

អនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលស្តីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ត្រង់ជំពូកទី២ ផ្នែកទី៦ មាត្រា១១ បានចែងថា "រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់គ្រងស្ថាប័នត្រូវបែងចែកភារកិច្ចរបៀបរបបបំពេញការងាររវាងសវនកម្មផ្ទៃក្នុង អគ្គាធិការដ្ឋាន ឬអធិការដ្ឋាន ព្រមទាំងអង្គភាពផ្សេងទៀត ដែលមានសមត្ថកិច្ចត្រួតពិនិត្យឱ្យបានសមស្របជៀសវាងការត្រួតពិនិត្យស្ទួនគ្នា និងស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០២២ ក្រសួងធម្មការ និងសាសនាពុំទាន់ធ្វើការបែងចែកការងាររវាងភារកិច្ចអធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងឱ្យបានសមស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើនៅឡើយ។

ឆ្លើយតបនឹងការលើកឡើង ក្រសួងធម្មការ និងសាសនាឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

ផ្អែកតាមការបំភ្លឺនេះ ក្រសួងធម្មការ និងសាសនាបានឯកភាពតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

### ៣.១.៣០.ការពុំទាន់រៀបចំគម្រោងជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ

ប្រកាសលេខ០០២ សហវ.ប្រក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីវិធាន និងនីតិវិធីលម្អិតនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ប្រការ៥ បានតម្រូវឱ្យគ្រប់ស្ថាប័ន អង្គភាពសាធារណៈ

ប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈ ត្រូវរៀបចំគម្រោងជម្រះបញ្ជីប្រចាំឆ្នាំនូវទ្រព្យសម្បត្តិរដ្ឋទាំងឡាយណាដែលជាកម្មវត្ថុនៃការស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

ហើយត្រូវបានអនុញ្ញាតឱ្យជម្រះបានតែមួយដងគត់ក្នុងមួយឆ្នាំ។ ប្រតិទិននៃការលើកគម្រោងជម្រះបញ្ជីប្រចាំឆ្នាំត្រូវបានកំណត់ដូចខាងក្រោម៖ គ្រប់អង្គភាពប្រើប្រាស់ត្រូវរៀបចំគម្រោងជម្រះបញ្ជីប្រចាំឆ្នាំ (N+1) មកអាជ្ញាធរកាន់កាប់យ៉ាងយូរត្រឹមត្រីមាស១ នៃឆ្នាំ (N)។ បន្ទាប់មកអាជ្ញាធរកាន់កាប់ ត្រូវផ្ញើគម្រោងជម្រះបញ្ជីប្រចាំឆ្នាំ (N+1) នេះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងយ៉ាងយូរត្រឹមខែឧសភានៃឆ្នាំ (N) ដើម្បីរៀបចំកិច្ចដំណើរការនីតិវិធីជម្រះទ្រព្យសម្បត្តិរដ្ឋនេះ។ អាជ្ញាធរគ្រប់គ្រងត្រូវពិនិត្យ និងសម្រេចជាគោលការណ៍លើគម្រោងស្នើសុំជម្រះទ្រព្យសម្បត្តិរដ្ឋយ៉ាងយូរត្រឹមខែមិថុនា នៃឆ្នាំ (N)។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០២២ គ្រឹះស្ថានអង្គរបានដំណើរការនីតិវិធីជម្រះទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិនូវរថយន្តចំនួន៥គ្រឿង ស៊ីទែនរថយន្តបូមលូចំនួន១ និងសម្ភារឧបករណ៍បរិក្ខារចំនួន៦៨មុខ ដោយពុំបានរៀបចំគម្រោងជម្រះផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានមួយឆ្នាំមុនឡើយ។ គ្រឹះស្ថានអង្គរគួរអនុវត្តឱ្យបានត្រឹមត្រូវ និងស្របតាមប្រកាសខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ គ្រឹះស្ថានអង្គរ នឹងពិនិត្យការងារនេះឡើងវិញទៅតាមអនុសាសន៍ណែនាំរបស់អាជ្ញាធរសវនកម្មជាតិ។

## ៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១.ការពុំបានធ្វើការត្រួតពិនិត្យលើការងាររបស់រជ្ជទេយ្យករចំណូល

ប្រកាសលេខ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ប្រការ២៣ ចែងថា ការផ្ទៀងផ្ទាត់របស់គណនេយ្យករសាធារណៈត្រូវធ្វើឡើងយ៉ាងហោចណាស់មួយឆ្នាំម្តង។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងការិយបរិច្ឆេទ២០២២ រតនាគារខេត្តប៉ៃលិនពុំធ្លាប់បានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងាររបស់រជ្ជទេយ្យករចំណូលនៅតាមបណ្តាអង្គភាពមន្ទីរជំនាញម្តងណាឡើយ។ អាស្រ័យហេតុនេះ ដើម្បីឱ្យការអនុវត្តកិច្ចបញ្ជិកាគ្រប់គ្រងរជ្ជទេយ្យករចំណូលបានល្អប្រសើរ រដ្ឋបាលខេត្តប៉ៃលិនគួរណែនាំរតនាគារខេត្តធ្វើការត្រួតពិនិត្យលើការងាររជ្ជទេយ្យករចំណូលនៅតាមបណ្តាអង្គភាពមន្ទីរជំនាញ ឱ្យបានទៀងទាត់តាមប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រតនាគារខេត្តប៉ៃលិនសូមឯកភាពតាមការសង្កេតរបស់អាជ្ញាធរសវនកម្មជាតិដោយធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងាររបស់រជ្ជទេយ្យករ

ចំណូលនៅតាមបណ្ដាអង្គភាពមន្ទីរជំនាញឱ្យបានល្អប្រសើរបានទូលំទូលាយតាមការណែនាំរបស់សវនកម្មជាតិ។

### ៣.២.២.ការពុំបានអនុវត្តតាមសៀវភៅបន្ទុកឱ្យបានពេញលេញ

ដើម្បីគ្រប់គ្រងការវិនិយោគនៅក្នុងរដ្ឋបាលខេត្តឱ្យបានល្អប្រសើរ រដ្ឋបាលខេត្តប៉ៃលិនបានកំណត់យ៉ាងច្បាស់នៅក្នុងសៀវភៅបន្ទុកស្ដីពីការវិនិយោគ និងការធ្វើអាជីវកម្មភាស៊ីសត្វឃាតស្រុកសាលាក្រៅខេត្តប៉ៃលិន ដែលមានរយៈពេល១៥ឆ្នាំ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ត្រង់ប្រការ៩ កំណត់ថា "អ្នកវិនិយោគត្រូវបង្កើតទីស្នាក់ការ និងចាត់តាំងភ្នាក់ងារប្រមូលភាស៊ីដោយត្រូវស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវ មានពាក់ស្លាកឈ្មោះលើហោប៉ៅខាងឆ្វេង ព្រមទាំងកាន់ប័ណ្ណសំគាល់ខ្លួនដែលចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ដើម្បីដើរប្រមូលភាស៊ីរៀបចំសណ្ដាប់ធ្នាប់ សន្តិសុខ និងអនាម័យក្នុងបរិវេណកន្លែងធ្វើអាជីវកម្មឱ្យបានស្អាតល្អ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមខែមេសា ឆ្នាំ២០២៣ ភ្នាក់ងារប្រមូលភាស៊ីពុំបានស្លៀកពាក់ឯកសណ្ឋានត្រឹមត្រូវ ជាពិសេសពុំបានកាន់ប័ណ្ណសំគាល់ខ្លួនដែលចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ដើម្បីដើរប្រមូលភាស៊ីនោះទេ។ អាស្រ័យហេតុ ដើម្បីឱ្យការអនុវត្តលើការគ្រប់គ្រងការ វិនិយោគបានល្អប្រសើរ រដ្ឋបាលខេត្តប៉ៃលិនគួរជំរុញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់គ្រង និងតាមដានការងាររបស់អ្នកដេញថ្លៃឈ្នះអនុវត្តតាមសៀវភៅបន្ទុកឱ្យបានពេញលេញ។

ឆ្លើយតបនឹងការលើកឡើង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមទទួលយកតាមអនុសាសន៍លើចំណុចខ្វះខាត និងកំណត់សម្គាល់ដែលសវនករជាតិបានរកឃើញ ដែលភ្នាក់ងារប្រមូលភាស៊ីពុំបានស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ ជាពិសេសពុំបានកាន់ប័ណ្ណសម្គាល់ខ្លួនដែលចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីប្រមូលភាស៊ី។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានណែនាំដល់អ្នកវិនិយោគឱ្យរៀបចំបំពេញនូវចំណុចខ្វះខាតខាងលើតាមអនុសាសន៍សវនកម្មជាតិបានរួចរាល់ហើយ។

### ៣.២.៣.ការទូទាត់ពុំសមស្របតាមកិច្ចសន្យា

សារាចរណែនាំលេខ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុច១៤ បានបញ្ជាក់ថា នៅក្នុងប្រការទូទាត់តម្លៃកិច្ចសន្យាត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគម្លាតពេលវេលានៃការទូទាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត និងត្រង់ចំណុច២១ បានចែងថា ការទូទាត់តម្លៃកិច្ចសន្យាត្រូវធ្វើឡើងជាដំណាក់ៗ ដោយត្រូវបង្វែរត្រង់ទៅគណនីរបស់អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការស្របតាមលក្ខខណ្ឌទូទាត់ដូចមានចែងក្នុងកិច្ចសន្យា។

តាមការធ្វើសវនកម្មនៅខេត្តចំនួន៦ សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការទូទាត់ចំពោះកិច្ចសន្យាលទ្ធកម្មជូនអ្នកផ្គត់ផ្គង់/អ្នកទទួលការ

ដោយសរុបរួមតែមួយលើកប៉ុណ្ណោះ មិនសមស្របតាមខ្លឹមសារនៃកិច្ចសន្យាដែលត្រូវទូទាត់ជា២ដំណាក់កាលផ្សេងគ្នា រួមមាន៖ ១.ខេត្តស្វាយរៀងមានចំនួន០២កិច្ចសន្យា ២.ខេត្តកំពង់ស្ពឺមានចំនួន៥កិច្ចសន្យា ៣.ខេត្តរតនគិរីមានចំនួន៨កិច្ចសន្យា ៤.ខេត្តកំពង់ចាមមានចំនួន៣កិច្ចសន្យា ៥.ខេត្តកំពង់ធំមានចំនួន៦កិច្ចសន្យា ៦.ខេត្តស្ទឹងត្រែងមានចំនួន៥កិច្ចសន្យា។

អាស្រ័យហេតុនេះ សូមររដ្ឋបាលខេត្តទាំងអស់ គួរណែនាំការអនុវត្តការងារទូទាត់កិច្ចសន្យាលទ្ធកម្មឱ្យបានសមស្រប។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តមួយចំនួនបានសន្យាថានឹងណែនាំអនុវត្តការងារនេះឱ្យបានត្រឹមត្រូវ និងរដ្ឋបាលខេត្តខ្លះទៀតបានលើកឡើងថា មកពីក្រុមហ៊ុនទទួលការផ្គត់ផ្គង់មិនបានធ្វើលិខិតស្នើសុំទូទាត់ទៅតាមដំណាក់កាលនៃកិច្ចសន្យា ម្យ៉ាងជាគម្រោងឥណទានបន្ថែមចុងឆ្នាំ។

**៣.២.៤.កង្វះខាតក្នុងការចេញវិញ្ញាបនបត្របញ្ចប់ការងារជូនអ្នកទទួលការ**

ប្រកាសលេខ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្រាប់លទ្ធកម្មទំនិញ និងសំណង់បានដាក់ឱ្យប្រើប្រាស់នូវកម្រងឯកសារដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈស្តីពីការងារសាងសង់/ជួសជុល ត្រង់ចំណុច១៤នៃលក្ខខណ្ឌកិច្ចសន្យា បានបញ្ជាក់ថា "ការងារ" ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថា អនុវត្តចប់គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់ទទួលសំណង់។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំ "អ្នកម្ចាស់ការ" នូវលិខិតបញ្ជាក់ពីការបញ្ចប់ការងារ។ "អ្នកម្ចាស់ការ" នឹងចេញលិខិតបញ្ជាក់ពីការបញ្ចប់ការងារនៅក្នុងរយៈពេលដប់បួន (១៤)ថ្ងៃ បន្ទាប់ពីបានទទួលសំណើពី "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់។

ប្រកាសលេខ១៦១៣ សហវ.ប្រក ចុះ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ផ្នែកទី៣ ប្រការ៧ បានបញ្ជាក់ថា អ្នកផ្គត់ផ្គង់ និងអ្នកទទួលការមានភារកិច្ចអនុវត្តកិច្ចសន្យាលទ្ធកម្មសំខាន់ៗជាអាទិ៍ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររហូតដល់ការប្រគល់ទទួលចប់ជាស្ថាពរជូនស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា។

តាមការធ្វើសវនកម្មនៅខេត្តចំនួន៨ សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្ត និងបណ្តាមន្ទីរមួយចំនួនបានអនុវត្តកិច្ចលទ្ធកម្មសំណង់លើការងារជួសជុល និងសាងសង់ ហើយនៅពេលបញ្ចប់ការងារ អ្នកទទួលការពុំបានធ្វើការស្នើសុំលិខិតបញ្ជាក់បញ្ចប់ការងារពីអ្នកម្ចាស់ការទេ។ ជាមួយនេះអ្នកម្ចាស់ការ

ក៏ពុំបានចេញវិញ្ញាបនបត្របញ្ចប់ការងារជូនដែរ ករណីនេះមាននៅៈ ១-ខេត្តកណ្តាលមានចំនួន១២អង្គភាព ២-ខេត្តពោធិ៍សាត់មានចំនួន៥អង្គភាព ៣-ខេត្តរតនគិរីមានចំនួន១៨អង្គភាព ៤-ខេត្តកោះកុងមានចំនួន១អង្គភាព ៥-ខេត្តកំពង់ឆ្នាំងមានចំនួន៩អង្គភាព ៦-ខេត្តក្រចេះមានចំនួន១៥អង្គភាព ៧-ខេត្តកែបមានចំនួន១៤អង្គភាព ៨-ខេត្តស្ទឹងត្រែងមានចំនួន៣អង្គភាព។ ដោយសារអ្នកទទួលការមិនបានស្នើសុំវិញ្ញាបនបត្របញ្ចប់ការងារពីម្ចាស់ការ អាចនាំឱ្យអ្នកម្ចាស់ការពុំមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យ និងប្រគល់ទទួលសំណង់។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ព្រមទាំងក្រុមលទ្ធកម្មតាមបណ្តាមន្ទីរខាងលើ អនុវត្តឱ្យបានសមស្របតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តបានឯកភាព និងបានសន្យាថា កែលម្អតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

**៣.២.៥.ការរក្សាទុកឯកសារដែលអង្គភាពរដ្ឋទទួលការមិនបានពេញលេញ**

សារាចរណែនាំលេខ០១៤ សហវ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការផ្តល់ប្រាក់បុរេប្រទានសម្រាប់ការចំណាយថវិកាវិនិយោគសាធារណៈ និងជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋាន អនុវត្តដោយអង្គភាពរដ្ឋ ត្រង់ចំណុច៥ ស្តីពីការទូទាត់ប្រាក់បុរេប្រទាន បានបញ្ជាក់ថា ឯកសារពាក់ព័ន្ធទាំងអស់នៃការអនុវត្តគម្រោងវិនិយោគសាធារណៈ គម្រោងជួសជុល និងកម្មវិធីថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានត្រូវរក្សាទុកនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអាណាប័ក និងនៅអង្គភាពរបស់ខ្លួនផ្ទាល់។ ឯកសារពាក់ព័ន្ធ រួមមាន៖ លិខិតស្នើសុំបើកផ្តល់ និងទូទាត់ប្រាក់បុរេប្រទាន កិច្ចសន្យាអនុវត្តគម្រោង របាយការណ៍ចំណាយប្រាក់បុរេប្រទាន (របាយការណ៍ហិរញ្ញវត្ថុ) របាយការណ៍វឌ្ឍនភាពការងារដែលបានពិនិត្យ និងបញ្ជាក់ពីអ្នកត្រួតពិនិត្យបច្ចេកទេសនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាអាណាប័ក ឬពីគណៈកម្មការអន្តរក្រសួងប្រគល់-ទទួល ឬវាយតម្លៃការងារ សលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ សលាកបត្រគណនេយ្យភាពហិរញ្ញវត្ថុ និងលិខិតយុត្តការពាក់ព័ន្ធផ្សេងៗ។

តាមការធ្វើសវនកម្មនៅខេត្តចំនួន៦ សម្រាប់ការិយបរិច្ឆេទ២០២២ ឃើញថា អង្គភាពរដ្ឋដែលទទួលការពីរដ្ឋបាលខេត្តពុំបានរក្សាទុកនូវឯកសារពាក់ព័ន្ធទាំងអស់នៃការអនុវត្តគម្រោងវិនិយោគសាធារណៈ គម្រោងជួសជុល និងកម្មវិធីថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានឱ្យបានពេញលេញនៅរដ្ឋបាលខេត្តឡើយ រួមមាន៖ ១-រដ្ឋបាលខេត្តកោះកុងមានចំនួន៦កិច្ចសន្យា មានទឹកប្រាក់សរុបចំនួន ២៦ ៥២២ លានរៀល បានរក្សាទុក (i)-លិខិតស្នើសុំបើកផ្តល់ និងទូទាត់ប្រាក់បុរេប្រទាន (ii)-កិច្ចសន្យា និងសំណុំឯកសារប្រគល់ ទទួល ២-រដ្ឋបាលខេត្តកំពង់ចាមមានចំនួន៤កិច្ចសន្យា មានទឹកប្រាក់សរុប

ចំនួន ៤២ ១០០លានរៀល បានរក្សាទុក (i)-លិខិតស្នើសុំបើកផ្តល់ និងទូទាត់ប្រាក់បុរេប្រទាន (ii)-កិច្ចសន្យានិងសំណុំឯកសារប្រគល់ទទួល (iii)-អាណត្តិទូទាត់ប្រាក់ ៣-រដ្ឋបាលខេត្តកំពង់ធំមានចំនួន១កិច្ចសន្យា មានទឹកប្រាក់សរុបចំនួន ១០ ៩៨៣ លានរៀល បានរក្សាទុក (i)-លិខិតស្នើសុំបើកផ្តល់ និងទូទាត់ប្រាក់បុរេប្រទាន (ii)-កិច្ចសន្យានិងសំណុំឯកសារប្រគល់ ទទួល (iii)-អាណត្តិទូទាត់ប្រាក់ ៤-រដ្ឋបាលខេត្តព្រះសីហនុមានចំនួន៣កិច្ចសន្យាមានទឹកប្រាក់សរុបចំនួន ២៨ ៣៤១,៧ លានរៀល បានរក្សាទុក (i)-លិខិតស្នើសុំបើកផ្តល់ប្រាក់បុរេប្រទាន (ii)-កិច្ចសន្យា និងកំណត់ហេតុស្តីពីការប្រគល់ទទួល ៥-រដ្ឋបាលខេត្តកំពង់ឆ្នាំងមានចំនួន៤ កិច្ចសន្យា មានទឹកប្រាក់សរុបចំនួន ២០ ១១៤លានរៀល បានរក្សាទុក (i)-លិខិតស្នើសុំបើកផ្តល់ និងទូទាត់ប្រាក់បុរេប្រទាន (ii)-កិច្ចសន្យា និងសំណុំឯកសារប្រគល់ទទួល និង(iii)-អាណត្តិទូទាត់ប្រាក់ ៦-រដ្ឋបាលខេត្តកែបមានចំនួន៥ កិច្ចសន្យាមានទឹកប្រាក់សរុបចំនួន ២៥ ៩៣៩លានរៀល បានរក្សាទុក (i)-លិខិតស្នើសុំបើកផ្តល់ប្រាក់បុរេប្រទាន (ii)-កិច្ចសន្យា និងកំណត់ហេតុស្តីពីការប្រគល់ទទួល។

ដោយសារការមិនបានរក្សាទុកនូវឯកសារពាក់ព័ន្ធទាំងអស់នៃការអនុវត្តគម្រោងវិនិយោគសាធារណៈ គម្រោងជួសជុល និងកម្មវិធីថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានឱ្យបានពេញលេញ អាចធ្វើឱ្យប៉ះពាល់ដល់គោលការណ៍លទ្ធកម្ម និងគោលការណ៍ហិរញ្ញវត្ថុសាធារណៈ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តខាងលើ គួរណែនាំគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មអនុវត្តឱ្យបានសមស្របតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តខ្លះបានឯកភាព និងបានសន្យាថានឹងណែនាំអង្គភាពជំនាញអនុវត្តតាមសារាចរណែនាំខាងលើឱ្យបានល្អ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៦.កង្វះខាតក្នុងការទុកពេលវេលាសម្រាប់បណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម

ប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្រាប់លទ្ធកម្មទំនិញ និងសំណង់នៅក្នុងគំរូឯកសារពិគ្រោះថ្លៃ ស្ទង់តម្លៃ (ពិគ្រោះថ្លៃទំនិញ) ត្រង់ចំណុចទី២១ បានចែងថា បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកពិគ្រោះថ្លៃ គណៈកម្មាធិការលទ្ធកម្មនឹងចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាឱ្យអ្នកពិគ្រោះថ្លៃឈ្នះ ដោយចម្លងជូនគ្រប់អ្នកពិគ្រោះថ្លៃចាញ់ និងផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងទុករយៈពេលដប់ (១០) ថ្ងៃធ្វើការ ដើម្បីឱ្យអ្នកពិគ្រោះថ្លៃទាំងនោះជំទាស់តវ៉ាទៅនឹងលទ្ធផលនៃពិគ្រោះថ្លៃ មុននឹងអញ្ជើញអ្នកពិគ្រោះថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា។

តាមការធ្វើសវនកម្មនៅខេត្តចំនួន៥ សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្ត និងក្រុមលទ្ធកម្មរបស់មន្ទីរបានចុះកិច្ចសន្យាលទ្ធកម្មជាមួយអ្នកដេញថ្លៃឈ្នះ ដោយពុំបានទុករយៈពេលវេលាគ្រប់គ្រាន់សម្រាប់អ្នកដេញថ្លៃចាញ់មកដាក់ពាក្យបណ្ដឹងតវ៉ាតាមការកំណត់ចំនួន១០ថ្ងៃឡើយរួមមាន៖

១-ខេត្តឧត្តរមានជ័យចំនួនមាន៦គម្រោង (ទុកពេល១ថ្ងៃមាន១គម្រោង, ទុកពេល៦ថ្ងៃ មាន២គម្រោង, ទុកពេល៧ថ្ងៃ មាន១គម្រោង, ទុកពេល៨ថ្ងៃ មាន១គម្រោង និងទុកពេល៩ថ្ងៃ មាន១គម្រោង) ២-ខេត្តសៀមរាបចំនួនមាន៤គម្រោង (ទុកពេល២ថ្ងៃ មាន១គម្រោង, ទុកពេល៦ថ្ងៃ មាន១គម្រោង, ទុកពេល៧ថ្ងៃ មាន១គម្រោង និងទុកពេល៨ថ្ងៃ មាន១គម្រោង) ៣-ខេត្តពាធិសាត់ចំនួន២គម្រោង (ទុកពេល៧ថ្ងៃ មាន២គម្រោង) ៤-ខេត្តបន្ទាយមានជ័យចំនួន៤គម្រោង (ទុកពេល៧ថ្ងៃមាន២គម្រោង, ទុកពេល៨ថ្ងៃ មាន១គម្រោង និងទុកពេល៩ថ្ងៃ មាន១គម្រោង ៥-ខេត្តស្ទឹងត្រែងចំនួន២គម្រោង (ទុកពេល៧ថ្ងៃមាន២គម្រោង)។ ដោយសារការមិនបានទុករយៈគ្រប់គ្រាន់សម្រាប់ការដាក់បណ្ដឹងតវ៉ា អាចនាំឱ្យកើតមានកំហុសឆ្គង និងមានបណ្ដឹងតវ៉ាក្នុងពេលចុះកិច្ចសន្យា។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំគណៈកម្មាធិការលទ្ធកម្ម អង្គភាពលទ្ធកម្ម និងក្រុមលទ្ធកម្មបណ្ដាមន្ទីរពាក់ព័ន្ធអនុវត្តឱ្យបានសមស្របតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តបានឯកភាព និងទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ហើយសន្យាថានឹងជំរុញណែនាំបណ្ដាមន្ទីរឱ្យអនុវត្តត្រឹមត្រូវ។

### ៣.២.៧.កង្វះខាតក្នុងការបញ្ចូលទ្រព្យសម្បត្តិរដ្ឋទៅក្នុងបញ្ជីសារពើភណ្ឌ

អនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ត្រង់ជំពូកទី១ មាត្រា២ ចំណុច៣ បានបញ្ជាក់ថា "ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ នីតិបុគ្គលសាធារណៈត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋតាមបែបបទ និងនីតិវិធីដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

សារាចរលេខ០៧ ស.រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ចំណុច២ បានបញ្ជាក់ថា "អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវកត់ត្រាទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួននូវអចលនវត្ថុ និងចលនវត្ថុទាំងអស់...។ ទ្រព្យសម្បត្តិរដ្ឋទាងអស់នេះត្រូវចុះបញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ..."។

សារាចរណែនាំលេខ០០៤ សហវ ចុះ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មសេវាកម្មទ្រព្យសម្បត្តិរដ្ឋ

ត្រង់ចំណុច IV អំពីការបញ្ចប់សុពលភាព និងការពិន័យ បានបញ្ជាក់ថា "ការបញ្ចប់ដោយត្រឹមត្រូវក្នុងការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យារបស់ភាគីឯកជនគឺ៖

- ករណីជាទ្រព្យសម្បត្តិរដ្ឋត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ករណីជាទ្រព្យសម្បត្តិឯកជនត្រូវទទួល និងចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា"។

តាមការធ្វើសវនកម្មនៅខេត្តចំនួន៤ សម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ទ្រព្យសម្បត្តិរដ្ឋមួយចំនួនរបស់រដ្ឋបាលខេត្ត និងមន្ទីរជំនាញមិនទាន់ត្រូវបានកត់ត្រាបញ្ចូលក្នុងបញ្ជីទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ នៅឡើយ ក្នុងនោះមាន៖

១-ខេត្តកណ្តាល៖ ដីរបស់រដ្ឋបាលខេត្តដែលបានទិញសម្រាប់សាងសង់សាលាសង្កាត់ព្រែកហូមានទំហំ៥៩៨ ម៉ែត្រក្រឡា និងដីសម្រាប់សាងសង់សាលាសង្កាត់តាក្ដុលទំហំ៥៩៨ម៉ែត្រក្រឡា។

២-ខេត្តតាកែវ៖ ដីទីសត្តឃាតដ្ឋានចំនួន១៧ ទីតាំងរបស់មន្ទីរកសិកម្ម

៣-ខេត្តព្រះសីហនុ៖ បន្ទប់ទឹកសាធារណៈចំនន០២ ដែលមានតម្លៃសរុប ១ ០៥០ លានរៀល របស់រដ្ឋបាលខេត្ត។

៤-ខេត្តក្រចេះ៖ តុឈើប្រណីតចំនួន១០គ្រឿង តម្លៃសរុប២៧លានរៀល។

៥-ខេត្តកែប៖ បង្គោលភ្លើង២៥០ដើម តម្លៃ ៤ ៩៨៨,១លានរៀល, សាលប្រជុំស្តង់ដារតម្លៃ៩ ៦៧២លានរៀល, ទីតាំងផ្សារក្តាម, ទីតាំងផ្សារកែប, អគារច្រកចេញចូលតែមួយ និងសាលប្រជុំសាលាក្រុងកែបមានតម្លៃ៣០១ លានរៀលរបស់រដ្ឋបាលខេត្ត។

ដោយសារការមិនបានកត់ត្រាបញ្ចូលទ្រព្យសម្បត្តិរដ្ឋទៅក្នុងបញ្ជីសារពើភណ្ឌ បណ្តាលឱ្យទ្រព្យសម្បត្តិរដ្ឋអាចបាត់បង់ជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំទីចាត់ការហិរញ្ញវត្ថុ និងបណ្តាមន្ទីរពាក់ព័ន្ធអនុវត្តឱ្យបានសមស្របតាមអនុក្រឹត្យខាងលើ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តខ្លះបំភ្លឺថា បានកត់ត្រារួចហើយ រដ្ឋបាលខេត្តខ្លះថា កំពុងដំណើរការអនុវត្ត និងខេត្តខ្លះទៀតសន្យាថានឹងណែនាំអនុវត្ត។

អាជ្ញាធរសវនកម្មជាតិនៅតែតាមដានការអនុវត្តការងារនេះបន្តទៀត។

## ៤. ការពិនិត្យនៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២១ នាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាបានខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

### ៤.១.ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២២

ដើម្បីប្រមូលពន្ធពីការខកខាន ឬការធ្វេសប្រហែលណាមួយពីអ្នកជាប់ពន្ធ ការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខេត្ត និងខណ្ឌមានភារកិច្ចរៀបចំកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើឯកសារ និងសវនកម្មមានកម្រិតលើអ្នកជាប់ពន្ធឱ្យបានទាន់ពេលប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព...។ តាមការពិនិត្យលើកម្មវិធីសវនកម្មរបស់សាខាពន្ធដារខណ្ឌ និងខេត្ត អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២២ សាខាពន្ធដារខណ្ឌ និងខេត្តបានលើកកម្មវិធីសវនកម្មសរុបចំនួន២ ៦១៩ សហគ្រាស ក្នុងនោះបានអនុវត្តការងារសវនកម្មសម្រេចបានលទ្ធផលចំនួន២ ០៣៩ សហគ្រាស ស្មើនឹង៧៨%នៃកម្មវិធី (គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣) ប៉ុន្តែនៅសល់សហគ្រាសមួយចំនួនទៀត មិនទាន់សម្រេចលទ្ធផលសវនកម្មក្នុងឆ្នាំ២០២២ នៅឡើយ។ សម្រាប់កម្មវិធីសវនកម្មមានកម្រិតឆ្នាំ២០២២ សាខាពន្ធដារខេត្តមួយចំនួនបានបញ្ចប់កម្មវិធីសវនកម្មទាន់ពេល១០០% ធៀបនឹងផែនការ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។ ដោយឡែក ការសម្រេចបានលទ្ធផលជារួម ៧៨% នៃកម្មវិធី (គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣) សម្រាប់សាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ដោយមូលហេតុថា (១) អ្នកជាប់ពន្ធមិនបានផ្តល់ឯកសារចាំបាច់ដែលតម្រូវឱ្យរក្សាទុក មិនបានកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ និងមិនបានផ្តល់ភស្តុតាងផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងការកំណត់ពន្ធ និង(២) ដោយសារវិបត្តិនៃការរីករាលដាលនៃជំងឺកូវីដ-១៩ សាខាពន្ធដារមួយចំនួន ជាពិសេសសាខាពន្ធដារខណ្ឌ មិនអាចបញ្ចប់សវនកម្មឆ្នាំចាស់បានទាន់ពេល និងបានបង្គរសម្រាប់កម្មវិធីឆ្នាំ២០២២។ ទោះយ៉ាងណា អគ្គនាយកដ្ឋានពន្ធដារនឹងបន្តពន្លឿនការធ្វើសវនកម្មប្រចាំឆ្នាំតាមកម្មវិធីឱ្យបានទាន់ពេល និងបង្កើនប្រសិទ្ធភាពក្នុងការរៀបចំកម្មវិធីសវនកម្ម។

### ៤.២.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួងស្ថាប័ន

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមួយចំនួន ក៏បានផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានពន្ធដារផងដែរ។ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារពុំទាន់បានប្រមូលព័ត៌មានសហគ្រាសនៅតាមបណ្តាក្រសួងស្ថាប័នមួយចំនួនផ្សេងទៀត ឱ្យបានពេញលេញ និងទាន់ពេលវេលានៅឡើយដោយសារក្រសួងមួយចំនួនពុំទាន់សហការ។ ចំពោះបញ្ហានេះកើតឡើងដោយសារស្ថាប័នពាក់ព័ន្ធមួយចំនួនពុំសហការផ្តល់ព័ត៌មាន។ ជាក់ស្តែងអ្នកលក់អនឡាញមួយចំនួនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារពុំបាន

ទទួលព័ត៌មានទាំងនោះពីក្រសួងពាណិជ្ជកម្មឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងជំរុញឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធផ្តល់ព័ត៌មានអំពីការចុះបញ្ជីរបស់សហគ្រាសមកអគ្គនាយកដ្ឋានពន្ធដារ និងសំណូមពរឱ្យអាជ្ញាធរសវនកម្មជាតិជួយណែនាំដល់ក្រសួងនានាចំពោះបញ្ហានេះផងដែរ។

## ៤.៣. វិធីសាស្ត្រសវនកម្ម

អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិធ្វើសវនកម្មលើក្រុមហ៊ុនសហគ្រាសដោយពិនិត្យសំណុំឯកសារឡើងវិញ ដើម្បីរកឱ្យឃើញនូវហានិភ័យដែលពាក់ព័ន្ធនឹងសំណុំឯកសាររបស់ក្រុមហ៊ុនសហគ្រាស។ តាមការពិនិត្យឯកសារសវនកម្មមានកម្រិតមួយចំនួនរបស់សាខាពន្ធដារខណ្ឌ និងខេត្តមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សវនករពន្ធដារបានគណនាប្រាក់អាករបំភ្លឺសាធារណៈខ្វះចំពោះសហគ្រាសអាហារដ្ឋាន និងសហគ្រាសដេប៉ូចែកចាយស្រាបៀរមួយចំនួន គណនាប្រាក់អាករបំភ្លឺសាធារណៈមួយចំនួនខ្វះ និងការកំណត់ចំណូលឡើងវិញផ្អែកមូលដ្ឋានចំណាយលើប្រតិបត្តិការសរុបប្រចាំឆ្នាំ នៅមិនទាន់ត្រឹមត្រូវ ដោយសវនករមិនបានដកចំណាយទាក់ទងនឹងការកំសាន្តសប្បាយចេញ។ ការធ្វើសវនកម្មមានកម្រិតរបស់សាខាពន្ធដារខេត្ត-ខណ្ឌ ក្នុងការពង្រឹងអនុលោមភាពសារពើពន្ធបានចូលរួមក្នុងការប្រមូលចំណូលពន្ធអាករលើសផែនការរៀងរាល់ឆ្នាំ។ ទន្ទឹមនឹងនេះ អ្នកជាប់ពន្ធមានការយល់ដឹងច្រើនអំពីសិទ្ធិ និងកាតព្វកិច្ចនៃការបង់ពន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារដែលឆ្លុះបញ្ចាំងតាមរយៈការប្រកាសបង់ពន្ធមានការកើនឡើង។

## ៤.៤.ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ផ្នែកទី៣ រដ្ឋបាលសារពើពន្ធ ត្រង់មាត្រា៩៨ បានចែងថា "អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់..." និងត្រង់មាត្រា១១៦ ចំណុច៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធនោះអ្នកជាប់ពន្ធ ត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ..."។ តាមការពិនិត្យសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន១៤៧ក្រុមហ៊ុនសហគ្រាស អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន១០៩ ក្រុមហ៊ុនសហគ្រាស (ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន៥០ និងសាខាពន្ធដារខេត្ត ខណ្ឌចំនួន៥៩) ពុំទាន់បានកាន់កាប់ កត់ត្រា និងថែរក្សាទុកកិច្ចបញ្ជិកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធនៅឡើយ។ កន្លងមកអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជានាយកដ្ឋានសវនកម្មសហ

គ្រាសតែងតែធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំអ្នកជាប់ពន្ធតាមរយៈការធ្វើសិក្ខាសាលា ក៏ដូចជាការផ្សព្វផ្សាយតាមរយៈបណ្ដាញសង្គម Facebook ជាដើម ដើម្បីជំរុញការអប់រំអ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ស្ដីពីសារពើពន្ធ និងការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ។ ប៉ុន្តែសហគ្រាសមួយចំនួននៅតែព្យាយាមគេចវេះមិនព្រមកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវនៅឡើយ ដែលសហគ្រាសទាំងនេះជាកម្មវត្ថុនៃការធ្វើសវនកម្មពន្ធដារ។

### ៤.៥.ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ

ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់សារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រង់មាត្រា១០៤ថ្មី ចំណុច១ បានចែងថា "អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់"។ ព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់មាត្រា១២៨ អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ ចំណុច១ "ករណីដែលបុគ្គលមិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់កំណត់" និងមាត្រា១២៩ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារបានចែងថា "ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេះពន្ធ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា១២៨នៃច្បាប់ខាងលើ ត្រូវបានចាត់ទុកថា បានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ"។ តាមការពិនិត្យស្ថិតិសហគ្រាសជាប់ពន្ធតូច និងមធ្យមប្រចាំខែនៅក្នុងឆ្នាំ២០២២ នៅសាខាពន្ធដារខណ្ឌ និងខេត្តមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្ត និងខណ្ឌខាងលើបានរៀបចំសិក្ខាសាលា ដើម្បីបណ្ដុះបណ្ដាល និងផ្សព្វផ្សាយកាតព្វកិច្ចសារពើពន្ធជូនអ្នកជាប់ពន្ធជារៀងរាល់ឆ្នាំ។ ជាងនេះទៀត សាខាពន្ធដារខាងលើបានក្រើនរំលឹកដល់អ្នកជាប់ពន្ធដែលខកខានក្នុងការដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែផងដែរ។ ទោះជាយ៉ាងនេះក្ដី សហគ្រាសជាប់ពន្ធតូចបានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំខែចន្លោះពី៤៨% ទៅ៥៩%នៃសហគ្រាសត្រូវដាក់លិខិតប្រកាស និងសហគ្រាសជាប់ពន្ធមធ្យមបានដាក់លិខិតប្រកាសប្រចាំខែចន្លោះពី៥២% ទៅ៦៣%នៃសហគ្រាសត្រូវដាក់លិខិតប្រកាស។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារបានជំរុញឱ្យរៀបចំធ្វើជាបញ្ជីសហគ្រាស ដែលខកខានមិនបានបំពេញកាតព្វកិច្ច និងចេញលិខិតរំលឹកស្ដីពីការមិនដាក់លិខិតប្រកាសដល់សហគ្រាសទាំងនោះជាប្រចាំ។

### ៤.៦.ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ

ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើតេស្តលើការត្រួតពិនិត្យលិខិតប្រកាសពន្ធប្រចាំខែ និងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមហ៊ុនចំនួន៦១៧ នៅអង្គភាពពន្ធចំនួន២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការបំពេញការងារត្រួតពិនិត្យលើភាពត្រឹមត្រូវនៃលិខិតប្រកាសសារពើពន្ធ ដើម្បីធានាថា លិខិតប្រកាសត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស គណនាឱ្យបានត្រឹមត្រូវ និងភាពមិនប្រក្រតីនៃលិខិតប្រកាស ពុំទាន់បានគ្រប់ជ្រុងជ្រោយទេ ដោយសារចំនួនមន្ត្រីនៅការិយាល័យចាត់ចែងលិខិតប្រកាសមួយចំនួនមានចំនួនតិច ប៉ុន្តែអ្នកជាប់ពន្ធមានចំនួនច្រើន រួមទាំងប្រតិបត្តិការច្រើនផង។ ជាលទ្ធផលនៃការខកខាននេះ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានលិខិតប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនមួយចំនួនមានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ គណនាអាករបំភ្លឺសាធារណៈមិនត្រឹមត្រូវ ប្រកាសចំណូលមិនប្រក្រតី (ចំណូលទាបជាងចំណាយ) គណនាអាករពិសេសមិនត្រឹមត្រូវ ប្រកាសចំណូលទាប ប្រកាសចំណូលថេរ មិនប្រកាសពន្ធកាត់ទុកលើសេវាកម្ម១៥% មិនប្រកាសពន្ធកាត់ទុកលើថ្លៃឈ្នួល និងកាន់កាប់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ។ ទោះជាយ៉ាងណា អគ្គនាយកដ្ឋានពន្ធដារក៏បានចាត់វិធានការដោយបានធ្វើសវនកម្មមានកម្រិត ហើយបានធ្វើការកំណត់ពន្ធឡើងវិញរួចរាល់ហើយថែមទាំងបានផ្តល់ជូននូវលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញទៀត និងបានអញ្ជើញសហគ្រាសទាំងនោះមកណែនាំឱ្យបំពេញលិខិតប្រកាសសារពើពន្ធឱ្យបានត្រឹមត្រូវឡើងវិញ។

### ៤.៧.ការរក្សាសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២២

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការបិទបញ្ជីចំណូលចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២២ អំពីការបិទបញ្ជីចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២២ បានបញ្ជាក់ថាប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ជាកំហិត។ តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករសម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករមានសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២២ចំនួន ៦ ៧១៨លានរៀល (ចំណូលភាគច្រើនបានមកពីយុទ្ធនាការប្រមូលពន្ធ និងអាករលើរថយន្តគ្មានពន្ធដែលមានស្រាប់ក្នុងប្រទេស និងការប្រមូលចំណូលចំថ្ងៃសៅរ៍អាទិត្យទើប

មិនអាចបង់ចូលរតនាគារទាន់ពេលវេលា) ដោយបានធ្វើការបង្វែរចំណូលទាំងនេះចូលថវិកាជាតិនៅដើមឆ្នាំ២០២៣។ កត្តានេះ នាំឱ្យការកត់ត្រាចំណូល ចំណាយថវិកាពុំបានឆ្លុះបញ្ចាំងតួលេខជាក់ស្តែងតាមឆ្នាំនៃថវិកា។ ថ្ងៃដំណាច់ឆ្នាំ២០២២ ត្រូវនឹងថ្ងៃសៅរ៍ អគ្គនាយកដ្ឋានរតនាគារជាតិ និងធនាគារជាតិនៃកម្ពុជាឈប់សម្រាក និងបិទប្រតិបត្តិការទទួលប្រាក់ចំណូល ចំណែកធនាគារពាណិជ្ជត្រូវបិទប្រតិបត្តិការផ្ទេរចំណូលទៅគណនីទោលរតនាគារនៅធនាគារជាតិនៃកម្ពុជាវេលាម៉ោង១៥:០០នាទីនៃថ្ងៃធ្វើការ ស្របតាមអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារសម្រាប់ប្រតិបត្តិការចំណូល ជាហេតុនាំឱ្យ អគរ មិនអាចបង្វែរចំណូលដែលបានបំពេញបែបបទគយរួចនៅថ្ងៃដំណាច់ឆ្នាំទាំងនេះចូលថវិកាជាតិក្នុងឆ្នាំសារពើពន្ធបាន។

**៤.៨.ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើមដែលទទួលបានការអនុគ្រោះព្យួរ ឬលើកលែងពន្ធអាករនៅមានកម្រិត**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ជាក់ថា នាយកដ្ឋានរបបគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា លើការងាររបបគយដោយមានតួនាទីនិងភារកិច្ចដូចជា៖ ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាតគយនាំចេញ នាំចូលទំនិញតាមរបបគយអនុគ្រោះនានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងមានភារកិច្ចតាមដានត្រួតពិនិត្យការប្រើប្រាស់សម្ភារបរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់។ តាមការធ្វើសវនកម្មនៅនាយកដ្ឋានរបបគយក្នុងឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថាមានមុខទំនិញនាំចូលដូចជា៖ វត្ថុធាតុដើមគ្រឿងបន្សំ សារធាតុគីមី គ្រឿងម៉ាស៊ីន គ្រឿងបន្លាស់ សម្ភារសំណង់ សម្ភារបរិក្ខារផ្សេងៗ និងទំនិញនាំចូលគ្រប់ប្រភេទដែលមានលក្ខណៈជាវិនិយោគកាត់ដេរ និងវិនិយោគមិនមែនកាត់ដេរ ដែលមានពន្ធអាករជាបន្ទុករដ្ឋសរុបទឹកប្រាក់ចំនួន ១១ ៨៨៨ ៦៣៨ លានរៀល ក្នុងនោះ វិនិយោគទុនកាត់ដេរ ចំនួន ៦ ៦៨៤ ៨០៤ ៩២៣ ៩០០ រៀល និងវិនិយោគទុនផ្សេងៗ ចំនួន ៥ ២០៣ ៨៣៣ ៤៣៧ ៤១១ រៀល ដោយទទួលបាននូវរបបអនុគ្រោះក្រោមរបបព្យួរពន្ធ ឬលើកពន្ធអាករខាងលើ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាការត្រួតពិនិត្យតាមដានអនុលោមភាពលើទិសដៅនៃការប្រើប្រាស់សម្ភារបរិក្ខារ វត្ថុធាតុដើម និងទំនិញគ្រប់ប្រភេទនៅមានកម្រិតនៅឡើយ។ កត្តានេះនាំឱ្យការគ្រប់គ្រងតាមដាន និងត្រួតពិនិត្យអនុលោមភាពលើទិសដៅនៃការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើម និងទំនិញដែលទទួលបានការអនុគ្រោះក្រោមរបបព្យួរ ឬលើកលែងពន្ធអាករពុំទាន់បានគ្រប់ជ្រុងជ្រោយ។ ផ្អែកតាមរបាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០២២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ របស់នាយកដ្ឋានរបបគយ និងអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ

២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៅក្នុងឆ្នាំ២០២២ នាយកដ្ឋានរបបគយបាន ចូលរួមជាមួយគណៈកម្មការអន្តរស្ថាប័ននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចុះត្រួតពិនិត្យការអនុវត្តគម្រោង សំណើបញ្ជប់ សំណើសុំផ្ទេរ-ទទួល សំណើសុំនាំចេញ សំណើសុំកម្ទេច និងសំណើសុំលក់គ្រឿងម៉ាស៊ីន សម្ភារបរិក្ខារ និងវត្ថុធាតុដើម សរុបចំនួន ៥០លើក និង ចូលរួមជាមួយអង្គភាពផ្សេងទៀតនៃ អគរ ចុះត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គលគ) សរុបចំនួន៩លើក គៀរគរចំណូលលើមុខទំនិញ នាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ មានទឹកប្រាក់ពន្ធអាករប្រមាណ១ ៤៩៩ ២៥៤,២៨ ដុល្លារអាមេរិក។

### ៤.៩.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ

នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈបំពេញមុខងារជាសេនាធិការឱ្យ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងារដូចជាៈ ពិនិត្យកំណត់ហេតុល្មើសគយ លើក សំណើសម្រុះសម្រួល និងសម្រេចវិនិច្ឆ័យលើបទល្មើសគយ និងវិវាទផ្សេងទៀតជូនអគ្គ នាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពិនិត្យ និងសម្រេច។ ប្រកាសលេខ ៦១៨ សហវ.ប្រក ចុះថ្ងៃ ទី២៤ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការសម្រុះសម្រួលបទល្មើសគយ ត្រង់ប្រការ៤ បានបញ្ជាក់ថា ប្រសិនបើក្នុងរយៈពេលកៅសិប(៩០)ថ្ងៃគិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្តីសម្រេចជាផ្លូវការស្តីពីការសម្រុះសម្រួលនូវបទល្មើស គយមិនអាចទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈបានទទួលកំណត់ហេតុល្មើសច្បាប់គយពីបណ្តា នាយកដ្ឋាន សាខា និងការិយាល័យគយ និងរដ្ឋាករទូទាំងប្រទេសចំនួន៩៨៧ (កំណត់ហេតុ នៅសល់ដើមឆ្នាំចំនួន១៧២) ក្នុងនោះមានកំណត់ហេតុល្មើសច្បាប់ចំនួន៨៤៨ ត្រូវបានធ្វើ សេចក្តីសម្រេចវិនិច្ឆ័យរួច (បូករួមបញ្ចូលកំណត់ហេតុនៅសល់ឆ្នាំចាស់ៗ) ចំណែកឯ កំណត់ហេតុចំនួន៤៨៣ ផ្សេងទៀតនៅពុំទាន់ត្រូវបានធ្វើការដោះស្រាយនៅឡើយ។ កត្តា នេះអាចនាំឱ្យទំនិញល្មើសច្បាប់គយខូចគុណភាពនិងហួសសុពលភាពកំណត់។ ជាការ ពិត រៀងរាល់ដំណាច់ឆ្នាំនីមួយៗ កំណត់ហេតុល្មើសច្បាប់គយរមែងមាននៅសល់ជាកត្តា សត្យានុម័តដែលនាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ ពុំអាចដោះស្រាយ សម្រុះសម្រួលបទល្មើសគយបានអស់។ ក្រៅពីយន្តការ និងវិធានការដោះស្រាយដែល មានចែងក្នុងច្បាប់និងបទប្បញ្ញត្តិគយ អគរ បានចាត់វិធានការចំពោះមុខដូចខាងក្រោមៈ

- ផ្តល់សិទ្ធិសម្រុះសម្រួលបទល្មើសគយបន្ថែមទៀតជូននាយកដ្ឋាន និងសាខាគយ និងរដ្ឋាករ សម្រាប់ទំនិញគ្រប់ប្រភេទដែលមានតម្លៃមិនលើសពី ៣ ០០០ ដុល្លារ អាមេរិក

- បានបង្កើតគណៈកម្មការចំពោះកិច្ច ដើម្បីដោះស្រាយទំនិញល្មើសនឹងច្បាប់ស្តីពីគយដែលមានយន្តការនិងនីតិវិធីដោះស្រាយដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចលេខ១៤៩១/២០ អគរ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ដោយនៅបន្តដោះស្រាយជាប្រចាំតាមសំណើរបស់អ្នកទិញ និង/ឬ អ្នកចូលរួមដេញថ្លៃ
- បានបន្តណែនាំម្ចាស់រថយន្តដែលបានចាប់ឃាត់កន្លងមក មិនទាន់ចូលខ្លួនដោះស្រាយឱ្យរួសរាន់ចូលខ្លួនមកសម្រុះសម្រួលឱ្យអស់លទ្ធភាព ដើម្បីបង់ពន្ធអាករ និងពិន័យតាមបញ្ញត្តិច្បាប់ជាធរមាន
- ជំរុញអង្គភាពក្រោមឱវាទឱ្យបន្តរៀបចំសំណុំរឿងទៅតុលាការ ចំពោះកំណត់ហេតុបទល្មើសគយណាដែលហួសរយៈពេលសម្រុះសម្រួល ឬលើកសំណើសុំចាត់វិធានការ ឬរកដំណោះស្រាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៤.១០.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២២ អំពីការបិទបញ្ជីចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២២ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយអាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ជាកំហិត។ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) មានសមតុល្យនៅសល់តួលេខចំណូលមិនមែនសារពើពន្ធ (រដ្ឋបាលកណ្តាលក្រសួង ស្ថាប័ន) ចុងឆ្នាំ២០២២ ចំនួន១ ៨០៦ លានរៀល ដោយមិនទាន់បានបង្វែរចូលថវិកាជាតិបានទាន់ពេលនៅឡើយ។ កត្តានេះនាំឱ្យការកត់ត្រាចំណូលចំណាយថវិកាមិនឆ្លុះបញ្ចាំងតាមឆ្នាំថវិកា។ តួលេខសមតុល្យនៅសល់ចំនួន ១ ៨០៦លានរៀលនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានជំរុញក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបង់រួចរាល់ និងត្រូវបានកត់ត្រានៅក្នុងឆ្នាំ២០២៣។

**៤.១១.ការទូទាត់ និងការកត់ត្រាចំណាយ**

ជាគោលការណ៍ ការសន្យាដែលអាណត្តិបើកប្រាក់មិនបានប្រតិបត្តិការនៅថ្ងៃទី៣១ ខែធ្នូ ត្រូវបានកត់ត្រាជាបន្តចូលក្នុងឥណទាននៃថវិកានៃឆ្នាំបន្ទាប់។ សារាចរណែនាំបន្ថែមលេខ០០៣ សហវ.សរណ.អរតន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២២ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ថវិកាថ្នាក់ជាតិ (រដ្ឋបាលថ្នាក់កណ្តាល) និងការរៀបចំ

របាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២២ ត្រង់ចំណុច៣នៃផ្នែក "ក" បានបញ្ជាក់ថា "ក្រោយកាលបរិច្ឆេទកំណត់វេលាម៉ោង១៧ និង៣០នាទី នាថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២៣ រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្តត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយ័តកម្មឆ្នាំ២០២២ ហើយប្រតិបត្តិការចំណាយ (Voucher) ក្នុងប្រព័ន្ធ FMIS ក៏មិនត្រូវបានអនុញ្ញាតឱ្យអនុម័តបញ្ជូនបន្តទៅរតនាគារថ្នាក់កណ្តាលទៀតទេ..."។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ (សម្រាប់រដ្ឋបាលកណ្តាល) មួយចំនួនត្រូវបានបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់នៅក្រោយថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២(អំឡុងពេលពីខែមករា ដល់ខែមីនា ឆ្នាំ២០២៣) ហើយបានកត់ត្រាជាចំណាយថវិកាប្រចាំឆ្នាំ២០២២ មានចំនួន៤ ០០៦អាណត្តិបើកប្រាក់។ នៅរៀងរាល់ដំណាច់ឆ្នាំថវិកានីមួយៗ មានការបញ្ជូនអាណត្តិបើកប្រាក់ក្នុងចំនួនច្រើននាដើមឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានរតនាគារជាតិដោយមានភាពយឺតយ៉ាវ ប៉ុន្តែសម្រាប់ឆ្នាំថវិកា២០២២ មានវឌ្ឍនភាពល្អប្រសើរបានលឿនជាងឆ្នាំកន្លងទៅ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០០៣ សហវ.សរណ.អរតន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយ័តកម្ម និងប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២២ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ថវិកាថ្នាក់ជាតិ (រដ្ឋបាលថ្នាក់កណ្តាល) និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២២។ ដោយឡែក បើពិនិត្យប្រភេទអាណត្តិទាំងនោះ គឺមានអាណត្តិនិយ័តកម្មមួយចំនួន (អាណត្តិបុរេប្រទាន នីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងរជ្ជទេយ្យបុរេប្រទាន) ដែលចាំបាច់ត្រូវទូទាត់ជម្រះបញ្ជីក្នុងឆ្នាំថវិកា២០២២ ដើម្បីបិទបញ្ជីចំណាយថវិកា។ ការទូទាត់ចំណាយខាងលើ គឺបានសម្រួលដល់ការទូទាត់ចំណាយចាំបាច់ និងបញ្ចៀសការបង្ករបន្ទុកចំណាយទៅឆ្នាំថវិកា២០២៣ និងឆ្នាំបន្តបន្ទាប់។ម្យ៉ាងទៀត រយៈពេលនេះ គឺស្ថិតក្នុងរយៈពេលបំពេញបន្ថែមសម្រាប់ប្រតិបត្តិការនិយ័តកម្មនៃរតនាគារ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តជំរុញក្រសួង ស្ថាប័នឱ្យរួសរាន់រៀបចំលិខិតយុត្តិការចំណាយ និងបោះផ្សាយអាណត្តិបើកប្រាក់ រួចបញ្ជូនទៅអភិបាលហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីអាចធ្វើការទូទាត់បានទាន់ពេល ជាពិសេសការទូទាត់ជម្រះបញ្ជីបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានឱ្យទាន់ក្នុងឆ្នាំថវិកា ជៀសវាងការបង្ករបំណុលទៅឆ្នាំថវិកាបន្ទាប់ ព្រមទាំងបន្តជំរុញ និងពង្រឹងការអនុវត្តការងារតាមប្រព័ន្ធ FMISដែលនឹងចូលរួមជំរុញការអនុវត្តចំណាយថវិកាតាមគោលការណ៍នៃកាលបរិច្ឆេទកំណត់។

**៤.១២.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់**

ដើម្បីធានាបាននូវការទទួលខុសត្រូវក្នុងការអនុវត្តចំណាយថវិការដ្ឋ អគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករសាធារណៈ មានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ។ ការអនុវត្តតួនាទីនេះបានគត់មុត ក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកា ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ចំណាយដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈដូចជា កិច្ចសន្យាលទ្ធកម្មដែលមានពន្ធប្រថាប់ត្រា និងប័ណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ជាដើម។ល។ តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់ឆ្នាំ២០២២ ចំនួន៥៧១របស់ក្រសួងមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ចំនួន២៥មិនបានភ្ជាប់នូវឯកសារគាំទ្រត្រឹមត្រូវដូចជាៈ ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនសមស្របតាមកម្មវត្ថុចំណាយ (ប្រភេទអាជីវកម្មមិនស្របតាមការផ្គត់ផ្គង់) មិនប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្ម និងប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្មក្រោយកាលបរិច្ឆេទ។ អាស្រ័យដោយនៅកៀកដំណាច់ឆ្នាំថវិកា២០២២ មានការបញ្ជូនអាណត្តិបើកប្រាក់គំហុកច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងនោះ អាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្មមួយចំនួនមានបញ្ហាខ្វះចន្លោះមិនត្រឹមត្រូវតាមនីតិវិធីនៃការទូទាត់។ ផ្អែកតាមសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តការយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្ម ដើម្បីមានមូលដ្ឋានក្នុងការទូទាត់ចំណាយថវិកាដោយផ្អែកលើកំណត់ហេតុប្រគល់ ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងាររបស់គណៈកម្មធិការលទ្ធកម្ម ដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងច្បាស់លាស់លើទំនិញ ឬសេវាដែលបានបំពេញរួច។ ប៉ុន្តែ អាស្រ័យដោយសារកត្តាពេលវេលា និងការមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ពីដើមទី បណ្តាលឱ្យមានបញ្ហាខ្វះចន្លោះមួយចំនួនដែលតម្រូវឱ្យមានកិច្ចសហការចូលរួមពង្រឹងបន្ថែមពីសាមីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចាប់ពីដើមទីនៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្ម និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តណែនាំដល់ក្រសួងស្ថាប័ន ក៏ដូចជាអ្នកផ្គត់ផ្គង់ឱ្យបំពេញបន្ថែមនូវសក្ខីប័ត្រចំណាយដូចជាការបង់ពន្ធប៉ាតង់បន្ថែមឱ្យស្របតាមប្រភេទអាជីវកម្ម និងការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្មមួយចំនួន ទើបនាំឱ្យមានករណីហួសកាលបរិច្ឆេទឆ្នាំ២០២២ជាដើម។ ករណីនេះក៏បានរួមចំណែកក្នុងការប្រមូលពន្ធបង់ចូលថវិការដ្ឋផងដែរ។ ម្យ៉ាងទៀត អគ្គនាយកដ្ឋានថវិកានឹងពង្រឹងបន្ថែមនូវវិធានការនៃការត្រួតពិនិត្យហិរញ្ញវត្ថុចំពោះប័ណ្ណប៉ាតង់អាជីវកម្មប្រចាំឆ្នាំដែលបានភ្ជាប់នឹងសំណុំអាណត្តិបើកប្រាក់ពេលទូទាត់។ ដោយឡែក ចំពោះកាលបរិច្ឆេទនៃពន្ធប្រថាប់ត្រាលើកិច្ចសន្យាដែលកើតឡើងក្រោយអាណត្តិ ដោយហេតុថាពេលស្នើសុំទូទាត់នាយកដ្ឋានហិរញ្ញកិច្ចបានពិនិត្យឃើញថា កិច្ចសន្យាមួយចំនួនមិនបានប្រថាប់ត្រាពីពន្ធដារ

នៅឡើយ ដូច្នេះបានណែនាំឱ្យក្រុមហ៊ុនយកទៅប្រថាប់ត្រា ដើម្បីឱ្យស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ គួរកត់សម្គាល់ថា ដំណាក់កាលអាណត្តិនេះ មិនទាន់បានឆ្លងការត្រួតពិនិត្យរបស់ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរបស់នាយកដ្ឋានហិរញ្ញកិច្ចនៅឡើយ ពោលគឺជាដំណាក់កាលដែលទទួលខុសត្រូវរបស់អាណាប័ក។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តពង្រឹងការត្រួតពិនិត្យលិខិតយុត្តិការចំណាយ និងទូទាត់ចំណាយថវិកាឱ្យបានត្រឹមត្រូវ និងទាន់ពេល ជាពិសេសបន្តជំរុញកិច្ចសហការរវាងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋាន រតនាគារជាតិ ព្រមទាំងសាមីក្រសួងស្ថាប័ន ដែលជាអង្គភាពពាក់ព័ន្ធពីដើមទីឱ្យចូលរួមក្នុងការពង្រឹង និងដោះស្រាយបញ្ហាប្រឈមទាំងនេះនៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។

**៤.១៣.អង្គភាពថវិកាមួយចំនួនពុំបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ**

រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ ដោយបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១នៃខែមេសា ខែកក្កដា ខែតុលា និងខែមករា។ ការខកខានដោយមិនបានផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មតាមកាលកំណត់នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិចារណាផ្អាកការផ្តល់ធានាចំណាយសម្រាប់គម្រោងលទ្ធកម្មបន្តបន្ទាប់។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០២២ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទាន់ពេលវេលា ប៉ុន្តែស្ថាប័នមួយចំនួនទៀតមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០២២ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទាន់ពេលវេលានោះទេ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | ស្ថាប័នអនុវត្តលទ្ធកម្ម | របាយការណ៍អនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០២២ | | |
|---|---|---|---|---|
| | | បានផ្ញើ | មិនបានផ្ញើ | សរុប |
| ១ | ក្រសួង ស្ថាប័ន | ៥៣ | ០ | **៥៣** |
| | អង្គភាពថវិកាក្រោមចំណុះ | ៥៣១ | ១១២ | **៦៤៣** |
| ២ | រាជធានី ខេត្ត | ២៥ | ០ | **២៥** |
| ៣ | សហគ្រាសសាធារណៈ និង គ្រឹះស្ថានសាធារណៈ | ៤១ | ០ | **៤១** |

កត្តានេះ នាំឱ្យការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មពុំទាន់បានគ្រប់ជ្រុងជ្រោយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំស្ថាប័នអនុវត្តកិច្ចលទ្ធកម្មទាំងនោះឱ្យរៀបចំរបាយការណ៍លទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់ និងទាន់ពេលវេលាឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យ និងសារាចរណែនាំខាងលើ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការណែនាំ និងក្រើនរំលឹក ព្រមទាំងបានរៀបចំផ្ញើលិខិតជូនស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា ដែលមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០២២ និងឧបសម្ព័ន្ធរបាយការណ៍របស់អង្គភាពថវិកាតាមរយៈលិខិតលេខ៣៦២, ៣៦៥, ៣៦៦ សហវ.លស.អលសា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣។

**៤.១៤.កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិ ដែលកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ មានកាតព្វកិច្ចថែរក្សា និងការពារទ្រព្យសម្បត្តិរដ្ឋ ដោយត្រូវចាត់វិធានការគ្រប់រូបភាព ដើម្បីទប់ស្កាត់ ឬបង្ក្រាបសកម្មភាពកេងប្រវ័ញ្ច ក្លែងបន្លំ រំលោភកាន់កាប់ទ្រព្យសម្បត្តិដោយខុសច្បាប់ ឬអំពើដែលបង្កអន្តរាយដល់ទ្រព្យសម្បត្តិរដ្ឋ។ តាមការពិនិត្យលើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង និងថយចុះឆ្នាំ២០២២ របស់នាយកដ្ឋានគ្រឿងចក្រ និងស្ពានផ្លូវរបស់ក្រសួងមួយ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានមានគ្រឿងចក្រសរុបចំនួន៦៦គ្រឿង ប៉ុន្តែនាយកដ្ឋាននៅពុំទាន់មានទីកន្លែងសមស្របសម្រាប់រក្សាទុកគ្រឿងចក្រទាំងនោះ ដោយបច្ចុប្បន្នគ្រឿងចក្រមួយចំនួនដែលកំពុងប្រើប្រាស់បានត្រូវបានរក្សាទុកនៅតាមការដ្ឋាន និងមួយចំនួនទៀតត្រូវបានថែរក្សាទុកនៅខាងក្រោយទីស្តីការក្រសួង និងនៅគល់ស្ពានព្រែកតាម៉ាក់។ល។ ក្រសួងបានបំភ្លឺថា គ្រឿងចក្រមួយចំនួនត្រូវបានចល័តទៅតាមបណ្តាការដ្ឋានដើម្បីប្រើប្រាស់ និងរក្សាទុកនៅទីនោះដោយមានមន្ត្រីថែរក្សាការពារ។ ក្រសួងនឹងខិតខំពិនិត្យលទ្ធភាពក្នុងការរៀបចំទីតាំង ដែលមានទីធ្លាសមស្របសម្រាប់រក្សាទុកគ្រឿងចក្រឱ្យឆ្លើយតបតាមស្ថានភាពជាក់ស្តែង។

**៤.១៥.ភាពមិនទាន់ពេញលេញនៃការបង្កើតរបាយការណ៍ចេញពីប្រព័ន្ធFMISសម្រាប់ប្រើប្រាស់**

សេចក្តីព្រាងលើកទី៣នៃគោលការណ៍ណែនាំរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបញ្ជាក់ថា ប្រព័ន្ធFMIS ត្រូវបានរៀបចំក្នុងគោលបំណងជំនួសជាជំហានៗនូវការអនុវត្តដោយដៃក្នុងការរៀបចំគម្រោងថវិកា ការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យ និងការធ្វើរបាយការណ៍។ តាមការសាកសួរមន្ត្រីបង្គោលដែលជាអ្នកប្រើប្រាស់ប្រព័ន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា របាយការណ៍មួយចំនួនដែលទាញចេញពីប្រព័ន្ធ FMIS ត្រូវការកែសម្រួលបន្ថែម ដើម្បីអាចប្រើប្រាស់បាន ដូចជា៖ របាយការណ៍ចំណាយដែលពាក់ព័ន្ធនឹងប្រតិបត្តិការចំណាយដែលមានការផ្តល់បុរេប្រទាន ឬគម្រោង

ចំណាយដែលមានការបែងចែករវាងអ្នកអនុវត្ត និងអ្នកត្រួតពិនិត្យ។ ការប្រើប្រាស់ប្រព័ន្ធ FMIS នៅមានកម្រិតនៅឡើយ។ ក្រសួងបានបំភ្លឺថា របាយការណ៍ដែលចេញពីប្រព័ន្ធ FMIS សម្រាប់ប្រើប្រាស់តម្រូវឱ្យមានការកែសម្រួលខ្លះមុននឹងអាចយកមកប្រើប្រាស់បាន ក្រសួងនឹងសហការជាមួយក្រុមការងារប្រព័ន្ធ FMIS ដើម្បីពិនិត្យ និងកែសម្រួលលើទម្រង់របាយការណ៍។

**៤.១៦.ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ**

ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រង់ប្រការ៤បាន កំណត់ថា "ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការ ដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់"។ តាមការពិនិត្យលើប្រព័ន្ធគ្រប់គ្រងប្រមូលចំណូលរបស់អង្គភាពប្រមូលចំណូល និងការពិនិត្យលើយន្តការនៃការប្រមូលចំណូលរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០២២ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈពុំទាន់បានរៀបចំបង្កើតទីតាំងច្រកចេញចូលតែមួយដើម្បីសម្រួលដល់ការផ្តល់សេវាសាធារណៈលើវិស័យសិល្បៈ វប្បធម៌ និងភាពយន្តជូនអតិថិជនឱ្យស្របទៅនឹងប្រកាសខាងលើនៅឡើយ។ ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសូមស្រាយបំភ្លឺថា ចំពោះភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ ផ្អែកតាមទិសដៅការងារ និងចំណារឯកភាពរបស់លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ដោយបានធ្វើការបែងចែកជាដំណាក់កាល ដូចខាងក្រោម៖

- ដំណាក់កាលទី១៖ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ និងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំអំពីបែបបទ និងនីតិវិធីសម្រាប់ការផ្តល់សេវាសាធារណៈរបស់ច្រកចេញចូលតែមួយនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានឯកភាព និងរង់ចាំចុះហត្ថលេខារបស់លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីនៅពេលបញ្ចប់នីតិវិធីជាមួយនាយកដ្ឋានពាក់ព័ន្ធ។

- ដំណាក់កាលទី២៖ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មការនីតិកម្ម បានប្រជុំត្រួតពិនិត្យ និងពិភាក្សាជាមួយនាយកដ្ឋានពាក់ព័ន្ធការផ្តល់សេវាសាធារណៈលើទម្រង់បែបបទសំណុំឯកសារភ្ជាប់ និងនីតិវិធីនៃការស្នើសុំសេវានិងផ្តល់លទ្ធផលសម្រេចជូនប្រជាពលរដ្ឋ។

- ដំណាក់កាលទី៣៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានស្នើសុំកញ្ចប់ថវិកាឆ្នាំ២០២៣សម្រាប់រៀបចំទីតាំងបំពាក់សម្ភារបរិក្ខារ និងរៀបចំបណ្តាញព័ត៌មានវិទ្យាសម្រាប់យន្តការច្រកចេញចូលតែមួយឱ្យបានសមស្របសម្រាប់ប្រជាពលរដ្ឋមកស្នើសុំសេវាសាធារណៈ។

- ដំណាក់កាលទី៤៖ រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីដែលបម្រើការងារនៅច្រកចេញចូលតែមួយ និងផ្សព្វផ្សាយខ្លឹមសារនៃលិខិតបទដ្ឋានទាំងនេះដល់ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការថ្នាក់ជាតិ និងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ។

- ដំណាក់កាលទី៥៖ រៀបចំសេចក្តីសម្រេចស្តីពីការចាត់មន្ត្រីមកបំរើការងារនៅយន្តការច្រកចេញចូលតែមួយ និងសេចក្តីសម្រេចស្តីពីសិទ្ធិចុះហត្ថលេខានិងសិទ្ធិចុះហត្ថលេខារបស់ថ្នាក់ដឹកនាំទទួលបន្ទុកដើម្បីចុះហត្ថលេខាលើលិខិតអនុញ្ញាតប័ណ្ណអនុញ្ញាតសម្រាប់ផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយ។ ហេតុដូចនេះ ទើបធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការបង្កើតយន្តការច្រកចេញចូលតែមួយរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

## ៤.១៧.កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងការងារជួសជុលថែទាំអគារ និងប្រាសាទ

ប្រកាសលេខ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ផ្នែកទី៣ បានចែងថា "អ្នកផ្គត់ផ្គង់ និងអ្នកទទួលការមានភារកិច្ចអនុវត្តកិច្ចសន្យាលទ្ធកម្មសំខាន់ៗជាអាទិ៍៖ រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររហូតដល់ការប្រគល់ទទួលចប់ជាស្ថាពរជូនស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា"។ តាមការពិនិត្យផែនការ និងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានអនុវត្តកិច្ចលទ្ធកម្មសាធារណៈសរុបចំនួន២៣គម្រោង ក្នុងនោះមានការអនុវត្តគម្រោងជួសជុលថែទាំអគារចំនួន៤ ដោយអ្នកទទួលការពុំបានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារជួសជុលថែទាំអគារ និងប្រាសាទជូនស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកាទេ។ ត្រង់ចំណុចនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានទទួលយកការផ្តល់អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងសូមធ្វើការកែលម្អនៅឆ្នាំបន្ទាប់។

## ៤.១៨.ការពុំបានគ្រោងក្នុងផែនការលទ្ធកម្ម

ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ១៧ បានចែងថា "មូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវមានលក្ខណៈច្បាស់លាស់គ្រប់ជ្រុងជ្រោយមានការទទួលខុសត្រូវ និងអាចជឿទុកចិត្តបាន ... តម្រូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្ត ឬអង្គភាពថវិកា" និងប្រការ៣៣ បានចែងថា "រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយដែលមិនបានកត់ត្រាក្នុងផែនការលទ្ធកម្មមិនអនុញ្ញាតឱ្យសុំ ឬផ្តល់ធានាចំណាយឡើយ"។ និយ័តករទូរគមនាគមន៍កម្ពុជាបានទូទាត់ចំណាយលើទិញផ្ទាល់ និងចុះកិច្ចសន្យាផ្ទាល់ចំពោះសង្ហារឹមសម្ភារការិយាល័យ សម្ភារព័ត៌មានវិទ្យា សម្ភារបច្ចេកទេស រថយន្ត រថយន្តអគ្គិសនី ឯកសណ្ឋាន ការជួសជុលអគារនិងប្រាសាទ ចំណតវ៉ែឆ្លាត និងសេវាផ្នែកច្បាប់សរុបចំនួន ១៣

៩១៥ ២២២ ៥៩៩រៀល ដោយពុំបានគ្រោងក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២២។ និយ័តករទូរគមនាគមន៍កម្ពុជាបានឯកភាពតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

**៤.១៩.ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនៅមានកម្រិត**

ប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ ត្រង់ប្រការ៣ បានចែងថា បុគ្គលដែលអាចបង្កើតស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈបាន ត្រូវមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេស សុវត្ថិភាពស្ថានីយពីក្រសួងរ៉ែ និងថាមពល។ បុគ្គលដែលអាចដំណើរការស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ ត្រូវមានលិខិតអនុញ្ញាតដំណើរការស្ថានីយពីក្រសួងរ៉ែ និងថាមពល។

ប្រកាសលេខ៣១៩ រថ.បល.ប្រក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤របស់ក្រសួងរ៉ែ និងថាមពលស្តីពីការកែសម្រួលប្រការ៥ ប្រការ៦ និងតារាងឧបសម្ព័ន្ធនៃប្រកាសលេខ ០៩២ រថ.បល.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រង់ប្រការ៦ថ្មី ចំណុច៤ ចែងអំពីតួនាទី និងភារកិច្ចរបស់ការិយាល័យថាមពល និងប្រេងកាត ក្នុងការចូលរួមវាយតម្លៃ និងផ្តល់អនុសាសន៍ទាក់ទងការគ្រប់គ្រងការបើកស្ថានីយ និងឃ្លាំងស្តុកប្រេង និងឧស្ម័នឥន្ធនៈ។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២២នៅមន្ទីររ៉ែ និងថាមពលនៃខេត្តចំនួន១២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់មន្ទីរទាំងនោះ ពុំទាន់បានល្អនៅឡើយ។ ជាក់ស្តែង មានស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈមួយចំនួនបាននឹងកំពុងដំណើរការអាជីវកម្ម ដោយពុំមានលិខិតអនុញ្ញាតឱ្យដំណើរការ និងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពនៅឡើយដូចខាងក្រោម៖

១.ខេត្តឧត្តរមានជ័យ មានស្ថានីយសរុបមានចំនួន១៣០ទីតាំង ដែលក្នុងនោះមានលិខិតអនុញ្ញាតដំណើរការចំនួន៦៩ និងមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន៣។

២.ខេត្តសៀមរាប មានស្ថានីយសរុបចំនួន៤០៩ទីតាំង ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងមានលិខិតអនុញ្ញាតឱ្យដំណើរការចំនួន៣០៦ ទីតាំង ។

៣.ខេត្តស្វាយរៀង មានស្ថានីយសរុបចំនួន១៦៤ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន១៤ និងមានលិខិតអនុញ្ញាតដំណើរការចំនួន៧២។

៤.ខេត្តកណ្តាល មានស្ថានីយសរុប ចំនួន៤១៩ទីតាំង ក្នុងនោះមានលិខិតអនុញ្ញាតដំណើរការចំនួន១១៧ និងកំពុងស្នើសុំលិខិតអនុញ្ញាតដំណើរការចំនួន១៧៥។

៥.ខេត្តរតនគិរី មានស្ថានីយសរុបចំនួន៩៨ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន៥ និងមានលិខិតអនុញ្ញាតដំណើរការចំនួន៦៨។

៦.ខេត្តកំពង់ចាម មានស្ថានីយសរុបចំនួន៣៨៤ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន៣២ និងមានលិខិតអនុញ្ញាតដំណើរការចំនួន១៣៨។

៧.ខេត្តកំពង់ធំ មានស្ថានីយសរុបចំនួន២៣៧ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន៤៧ និងមានលិខិតអនុញ្ញាតដំណើរការចំនួន១៣៣។

៨.ខេត្តកំពត មានស្ថានីយសរុបចំនួន៣០៣ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន២៣ និងមានលិខិតអនុញ្ញាតដំណើរការចំនួន៩២។

៩.ខេត្តតាកែវ មានស្ថានីយសរុបចំនួន៣៨៧ ក្នុងនោះមានវិញ្ញាបនបត្រអនុញ្ញាតចំនួន១៧៩។

១០.ខេត្តព្រះវិហារ មានស្ថានីយសរុបចំនួន១៤០ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន៩១។

១១.ខេត្តកំពង់ឆ្នាំង មានស្ថានីយសរុបចំនួន១៧២ ក្នុងនោះមានលិខិតអនុញ្ញាតដំណើរការចំនួន៧៦ និងកំពុងស្នើសុំលិខិតអនុញ្ញាតដំណើរការចំនួន៨១។

១២.ខេត្តស្ទឹងត្រែង មានស្ថានីយសរុបចំនួន៥៣ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងលិខិតអនុញ្ញាតដំណើរការចំនួន២៣។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តមួយចំនួនបានឯកភាព ដោយសន្យាថានឹងជំរុញមន្ទីរអនុវត្តការងារនេះឱ្យបានល្អ និងរដ្ឋបាលខេត្តខ្លះទៀតបានបង្ហាញថា ក្រោយពីទទួលបានអនុសាសន៍សវនកម្ម បានកំពុងនឹងជំរុញដល់ម្ចាស់អាជីកម្មឱ្យមកដាក់ពាក្យ និងអនុវត្តជាបណ្តើរៗហើយ។

## ៤.២០.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព

ប្រកាសអន្តរក្រសួងលេខ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់ឧបសម្ព័ន្ធ ខ.I.១.១៤ បានបញ្ជាក់ថា "លិខិតអនុញ្ញាតបើកការដ្ឋានចំពោះផ្ទៃក្រឡាសំណង់ចាប់ពី ៣ ០០០ម៉ែត្រក្រឡាចុះក្រោម គិតយក១០ភាគរយនៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់"។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២២ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តចំនួន០៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សំណង់ស្ថិតក្រោមសមត្ថកិច្ចប្រមូលចំណូលតាមការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលខេត្តដែលមន្ទីរជាអ្នកគ្រប់គ្រងលើបច្ចេកទេស មន្ទីរទាំងនោះបានផ្តល់លិខិតអនុញ្ញាតសាងសង់ជូនម្ចាស់សំណង់ និងបានប្រមូលចំណូលពីសេវានេះ។ ទន្ទឹមនឹងនេះ មន្ទីរទាំងនោះក៏មានការខកខានក្នុងការប្រមូលចំណូលពីសេវាបើក និងបិទការដ្ឋានឱ្យបានគ្រប់ចំនួន ដូចខាងក្រោម៖

១.ខេត្តស្វាយរៀង បានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន១៣គម្រោង និងបានផ្តល់លិខិតបើកការដ្ឋានចំនួន១៣គម្រោង ប៉ុន្តែពុំបានផ្តល់លិខិតបិទការដ្ឋានទេ

២.ខេត្តកណ្តាលបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន៣៧គម្រោង និងលិខិតបើកការដ្ឋានចំនួន១១គម្រោង និងលិខិតបិទការដ្ឋានចំនួន១៥គម្រោង

៣.ខេត្តកំពង់ស្ពឺ បានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន៤៣គម្រោង និងបើកការដ្ឋានចំនួន៥គម្រោង

៤.ខេត្តបន្ទាយមានជ័យ បានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន២៣៩គម្រោង លិខិតបើកការដ្ឋានចំនួន៣៨គម្រោង និងលិខិតបិទការដ្ឋានចំនួន០២គម្រោង

៥.ខេត្តព្រះវិហារចេញលិខិតអនុញ្ញាតបើកការដ្ឋានចំនួន០២គម្រោង និងលិខិតបិទការដ្ឋានចំនួន១គម្រោង

៦.ខេត្តស្ទឹងត្រែងបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន៤៧គម្រោង និងលិខិតបើកការដ្ឋានចំនួន២គម្រោង ប៉ុន្តែពុំមានលិខិតបិទការដ្ឋានទេ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះឯកភាពតាមការលើកឡើង និងសន្យាថាជួយជំរុញការងារនេះ។ រដ្ឋបាលខេត្តខ្លះទៀតបានលើកឡើងថា ម្ចាស់សំណង់មួយចំនួនមិនបានមកសុំបិទការដ្ឋានទេ និងសំណង់ខ្លះទៀតសង់មិនទាន់រួចនៅឡើយ។

### ៤.២១.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗក្នុងចន្លោះរយៈពេល០៥(ប្រាំ)ឆ្នាំនៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗ ដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំដែលរៀបចំរួចត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន២ (ពីរ) ច្បាប់ យ៉ាងយូរនៅដំណាច់ត្រីមាសទី១នៃឆ្នាំបន្ទាប់ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនបានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២២)។ គិតត្រឹមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣ អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ដែលបានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងមិនបានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យរដ្ឋសម្រាប់ឆ្នាំ២០២២ មានដូចជា៖

| ល.រ | អង្គភាព | បញ្ជីសារពើភណ្ឌឆ្នាំ២០២២ | | |
|---|---|---|---|---|
| | | បានធ្វើ | មិនបានធ្វើ | សរុប |
| ១ | ក្រសួង-ស្ថាប័ន (ថ្នាក់កណ្តាល) | ១៨០ | ១៧៤ | ៣៥៤ |
| ២ | សហគ្រាសាធារណៈ | ១១ | ០៤ | ១៥ |
| ៣ | គ្រឹះស្ថានសាធារណៈរដ្ឋបាល | ៣០ | ១៩ | ៤៩ |
| ៤ | រាជធានី ខេត្ត ក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ និងមន្ទីរជំនាញ(ថ្នាក់មូលដ្ឋាន) | ១ ៦១៣ | ១ ០៦០ | ២ ៦៧៣ |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

**៤.២២.ភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ**

សារាចរណែនាំលេខ០០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ចំណុចទី៥ បានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្រសួង ស្ថាប័នថ្នាក់កណ្តាលចំនួន៣៧ និងមន្ទីរ ជំនាញ អង្គភាពថ្នាក់មូលដ្ឋាននៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ ដូចមានតារាងខាងក្រោម៖

| ល.រ | បរិយាយ | អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ | |
|---|---|---|---|
| | | មានប័ណ្ណកម្មសិទ្ធ | គ្មានប័ណ្ណកម្មសិទ្ធ |
| ១ | ក្រសួងស្ថាប័ន ថ្នាក់កណ្តាល | ៧៥៨ | ១ ០៨៥ |
| ២ | មន្ទីរ អង្គភាពថ្នាក់មូលដ្ឋាននៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ១២ ៣៦៦ | ១២ ១៨១ |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យរៀបចំគ្រោងឥណទានចំណាយថវិកាប្រចាំឆ្នាំសម្រាប់ការធ្វើប័ណ្ណកម្មសិទ្ធិនូវទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកាន់កាប់នៅមិនទាន់មានប័ណ្ណកម្មសិទ្ធិតាមរយៈសារាចរណែនាំលេខ០០៥ សហវ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់ការណែនាំនិងបន្តការតាមដានដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តឱ្យបានត្រឹមត្រូវ តាមខ្លឹមសារនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល និងអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ បានបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងពុះពាររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើនបន្តប្តេជ្ញាជំរុញវឌ្ឍនភាពក្នុងការដ្ឋានកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ព្រមជាមួយនឹងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងវិស័យអាទិភាពផ្សេងទៀត ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ពិសេសដើម្បីគោលដៅនៃការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវ**កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣**របស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិ និងការកសាងជាតិមួយដ៏រស់រវើក មានអនាគតដ៏រុងរឿងភ្លឺស្វាងត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួនតាមគោលការណ៍ប្រជាធិបតេយ្យនិងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យយ៉ាងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាព ឯករាជ្យជាតិ និងអធិបតេយ្យភាព ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាលើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល

ចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្ដល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្ដល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។